**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**

Université Royale de Droit et des Seiences Economics

Royal University of law and Exconomics

# សារណាបញ្ចប់ការសិក្សា

# ការវិវត្តន៍រាជរដ្ឋាភិបាលកម្ពុជាឆ្នាំ១៩៩៣ ដល់បច្ចុប្បន្ន

ស្រាវជ្រាវចាប់ពីថ្ងៃទី ២៣-មីនា-២០២២ ដល់ថ្ងៃទី ២៣-ឧសភា-២០២២


ស្រាវជ្រាវដោយ

និស្សិតឈ្មោះ **កញ្ញា. គេន ឌុត្ថា**

**កញ្ញា. រ៉ាត់ សរ**

សាស្ត្រាចារ្យណែនាំ

**លោកស្រី សុខ ចិន្តា**


ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ជំនាន់ទី២២

ឆ្នាំចូលសិក្សា ២០១៨

ឆ្នាំសរសេរសារណា ២០២២

# **សេចក្តីថ្លែងអំណរគុណ**

យើងខ្ញុំឈ្មោះ **កេន វុត្ថា** និង **រ៉ាត់ សរ** ជានិស្សិតថ្នាក់បរិញ្ញាបត្រផ្នែកនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច ជំនាន់ទី២២ ឆ្នាំសិក្សា ២០១៨-២០២២ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។

ជាបឋមយើងខ្ញុំសូមគោរពទៅកាន់អ្នកមានគុណដែលចិញ្ចឹមបីបាច់ថែរក្សាកូនកន្លងមកតាំងពីតូចរហូតដល់ធំថែមទាំងផ្តល់នូវ ការអប់រំទូន្មាន ប្រៀនប្រដៅកូនឲ្យប្រព្រឹត្តទៅតាមគន្លងធម៌ ការស្រឡាញ់ ទំនុកបម្រុងការសិក្សា សម្លៀកបំពាក់ និងការផ្តល់អាហារូបត្ថម្ភបានគ្រប់គ្រាន់ផងដែរ។ ពួកកូនពិតជាមានសំណាងខ្លាំងណាស់ដែលបានកើតមកជាកូនរបស់លោកទាំងពីរ។

មួយវិញទៀត ក៏សូមអរគុណទៅកាន់ម្ចាស់ជំនួយ (CLEW) ដែលពួកគាត់បានផ្តល់ជាអាហារូបករណ៍មកកាន់ពួកខ្ញុំទាំងពីនាក់ក្នុងការបន្តការសិក្សាបរិញ្ញាបត្រនេះ។

យើងខ្ញុំសូមថ្លែងអំណរគុណចំពោះ **ឯកឧត្តមបណ្ឌិត លុយ ចណ្ណា** ជាសាកលវិទ្យាធិការនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច និងសាកលវិទ្យាធិការរង អស់លោក លោកស្រី ជាសាស្ត្រាចារ្យ នៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលបានចំណាយពេលវេលាដ៏មានតម្លៃខិតខំបង្ហាត់បង្រៀន យ៉ាងយកចិត្តទុកដាក់មកកាន់និស្សិតគ្រប់ៗគ្នាការចែករំលែកនូវចំណេះដឹង ក៏ដូចជាបទពិសោធន៍ជាច្រើនមកកាន់ខ្ញុំឲ្យចេះគិតពិចារណាយល់ដឹងអំពីខ្លឹមសារ មេរៀន និងអ្វីៗជាច្រើនដែលមិនអាចពិពណ៌នាអស់ក្នុងការរៀនសូត្រការស្រាវជ្រាវ ចំណេះដឹង និងទទួលបាននូវលទ្ធផលល្អតាំងពីដើមរហូតដល់សព្វថ្ងៃនេះ។

ជាពិសេស យើងខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅក្រៃលែងចំពោះសាស្ត្រាចារ្យណែនាំ **លោកស្រី សុខ ចិន្តា** ជាសាស្ត្រាចារ្យដឹកនាំក្នុងការសរសេរសារណានេះឡើងដោយលោកខំចំណាយពេលវេលាដ៏មាន តម្លៃធ្វើការណែនាំចំណុចគន្លឹះសំខាន់ៗជាច្រើន ការបែងចែកប្លង់ ការផ្តល់ជាគំនិតល្អៗខ្លឹមសារក្នុងការស្វែងរកឯកសារ និងការឆ្លើយតបបានរហ័សក្នុងការជួយកែតម្រូវយ៉ាងយកចិត្តទុកដាក់ផ្ចិតផ្ចង់នូវចំណុចខ្វះខាតមួយចំនួន។

ជាទីបញ្ចប់ យើងខ្ញុំសូមលើកម្រាមដៃដប់គោរពបួងសួងទៅដល់ទេវតាឆ្នាំថ្មី និង វត្ថុសាកសិទ្ធិនៅក្នុងលោកឲ្យប្រទានពរគ្រប់សព្វសាធុការជូនដល់អ្នកមានគុណ ឯកឧត្តមសាកលវិទ្យាធិការ សាកលវិទ្យាធិការរង អស់លោក លោកស្រី និងសាស្ត្រាចារ្យណែនាំ**លោកស្រី សុខ ចិន្តា** មានតែសុខភាពល្អ និងទទួលបាននូវពុទ្ធពរទាំងបួនប្រការ គឺអាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

# អារម្ភកថា

យើងខ្ញុំ សូមគោរពឯកឧត្តមសាកលវិទ្យាធិការសាកលវិទ្យាធិការរង អស់លោក លោកស្រី ជា សាស្ត្រាចារ្យ នៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច រួមទាំងមិត្តនិស្សិតគ្រប់រូបដោយសេចក្តីគោរព និង សេចក្តីស្រឡាញ់រាប់អាន។

យើងខ្ញុំ ជានិស្សិតថ្នាក់ L4B2 ឆ្នាំទី៤ ផ្នែកបរិញ្ញាបត្រនីតិសាស្ត្រនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ឆ្នាំសិក្សា ២០២១-២០២២ ដែលប្រធានការិយាល័យស្រាវជ្រាវបានអនុញ្ញាតឲ្យក្រុមយើងខ្ញុំ សិក្សាស្រាវជ្រាវ និង សរសេរសារណាបញ្ចប់ការសិក្សាលើប្រធានបទ ***"ការវិវត្តន៍រាជរដ្ឋាភិបាលកម្ពុជាឆ្នាំ ១៩៩៣ ដល់បច្ចុប្បន្ន"*** ។ យើងខ្ញុំ ពិតជាមានសេចក្តីសោមនស្សរីករាយក្រៃលែង និងការសិក្សាស្រាវជ្រាវ ក៏ដូចជាចងក្រងជាសៀវភៅអំពីប្រធានបទខាងលើនេះ។ ក្នុងការធ្វើកិច្ចការនេះ ឲ្យបានលេចចេញជារូបរាងឡើងក្រុមយើងខ្ញុំ បានយល់ដឹងអំពីការស្រាវជ្រាវ យល់ពីខ្លឹមសារដ៏មានអត្ថន័យនៅក្នុងប្រធានបទ រដ្ឋាភិបាល របបនយោបាយ និងការផ្លាស់ប្តូររដ្ឋាភិបាលកម្ពុជាទៅតាមដំណាក់កាលនីមួយៗផងដែរ។ យើងខ្ញុំ ពិតជាមានអារម្មណ៍រំភើបរីករាយក្នុងការធ្វើការចងក្រងជាសៀវភៅ និងបង្កើតគំនិតថ្មីៗ ក្នុងការធ្វើជាសារណាបញ្ចប់ការសិក្សា។

យើងខ្ញុំសូមអភ័យទោសរាល់ចំណុចខ្វះខាតណាមួយក្នុងការស្រាវជ្រាវចងក្រងជាសៀវភៅនេះ ឡើងបើ មានកំហុសខុសឆ្គងដោយអចេតនាក្នុងការស្រាវជ្រាវ ឬ ការសេរសេរឯកសារឬមួយក៏នៅមានចំណុចលើសលោះ យើងខ្ញុំពិតជាសុំទោសពីសំណាក់ឯកឧត្តមសាកលវិទ្យាធិការសាកលវិទ្យាធិការរង អស់លោក លោកស្រី អ្នកនាង កញ្ញា និង មិត្តនិស្សិតអ្នកដែលបានអានខ្លឹមសារនេះ។

ជាចុងក្រោយ យើងខ្ញុំពិតជាសូមអរគុណាគ្រប់បែបគ្រប់យ៉ាងដែលបានសិក្សាទៅលើប្រធានបទនេះដល់ សាស្ត្រាចារ្យណែនាំ **លោកស្រី សុខ ចិន្តា** ដែលជាគ្រូដឹកនាំល្អបំផុតនៅក្នុងការពន្យល់ណែនាំ និងផ្តល់ជាគំនិតក្នុងការត្រិះរិះពិចារណាក៏ដូចជាផ្តល់ជា យោបល់ក្នុងការធ្វើកិច្ចការមួយនេះការយកចិត្តទុកដាក់ការព្រួយបារម្ភតែងតែលើកទឹកចិត្តអោយប្រឹងប្រែងព្យាយាមធ្វើឲ្យបានល្អនិងជួយកែតម្រូវរាល់ចំណុចជាច្រើនដែលខ្វះខាត និងផ្តល់ជាមតិជាច្រើនក្នុងការចងក្រងធ្វើជាសៀវភៅនេះបាន។

# មាតិកា

ទំព័រ


## សេចក្តីផ្តើម

១. លំនាំបញ្ហានៃការស្រាវជ្រាវ........................................................................................................១

២. ចំណោទបញ្ហានៃការស្រាវជ្រាវ....................................................................................................២

៣. គោលបំណងនៃការស្រាវជ្រាវ.......................................................................................................៣

៤. ទំហំនិងដែនកំណត់នៃការស្រាវជ្រាវ.............................................................................................៣

៥. សារៈសំខាន់នៃការស្រាវជ្រាវ........................................................................................................៤

៦. វិធីសាស្ត្រនៃការស្រាវជ្រាវ.............................................................................................................៤

៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ..........................................................................................................៥

## ជំពូកទី១

## សញ្ញាណទូទៅនៃរដ្ឋាភិបាល

**១. និយមន័យនៃរដ្ឋាភិបាល**.................................................................................................................៦

**២. ការបង្កើតរដ្ឋាភិបាលតាមប្រព័ន្ធឯកសភា**..........................................................................................៦

**៣. ការបង្កើតរដ្ឋាភិបាលតាមរបបនយោបាយនីមួយៗ**............................................................................១០

៣.១ ការបង្កើតរដ្ឋាភិបាលតាមរបបកុំម្មុយនីស្ត......................................................................................១១

៣.២ ការបង្កើតរដ្ឋាភិបាលតាមរបបសេរី.............................................................................................១១

៣.២.១. ការបង្កើតរដ្ឋាភិបាលរបបប្រធានាធិបតីនិយម.....................................................................១៣

៣.២.២. ការបង្កើតរដ្ឋាភិបាលតាមរបបសភានិយម..........................................................................១៤

៣.២.៣. ការបង្កើតរដ្ឋាភិបាលតាមរបបចម្រុះ..................................................................................១៦

## ជំពូកទី២

## នីតិវិធីបង្កើតរាជរដ្ឋាភិបាលកម្ពុជាឆ្នាំ ១៩៩៣ ដល់បច្ចុប្បន្ន

**១. សាវតាស្ថាប័ននីតិប្រតិបត្តិនៃប្រទេសកម្ពុជាឆ្នាំ ១៩៤៧ ដល់ ១៩៩៣**.........................១៧

**ផ្នែកទី១. ការបង្កើតរាជរដ្ឋាភិបាលតាមអាណត្តិសភានីមួយៗ (១៩៩៣ ដល់បច្ចុប្បន្ន)**..១៩

**១.១ ការបង្កើតរាជរដ្ឋាភិបាលតាមអាណត្តិសភា ១៩៩៣-១៩៩៨** ..............................១៩

១.១.១ ការបង្កើតសភាធម្មនុញ្ញ១៩៩៣....................................................................១៩

១.១.២. ដំណើរការនៃសភាធម្មនុញ្ញ១៩៩៣....................................................................២០
១.១.៣.ការប្រែក្លាយពីសភាធម្មនុញ្ញទៅជាសភាជាតិឆ្នាំ១៩៩៣-១៩៩៨......................២១
១.១.៤. ការបង្កើតរាជរដ្ឋាភិបាល..........................................................................២១
១.១.៥. ក្រសួង និងស្ថាប័ននានា..........................................................................២៣
**ផ្នែកទី២. ការបង្កើតរាជរដ្ឋាភិបាលតាមអាណត្តិសភា១៩៩៨-២០០៣**.............................២៣
២.១. ការបង្កើតរដ្ឋសភា..........................................................................................២៤
២.២. ដំណើរការនៃរដ្ឋសភា......................................................................................២៤
២.៣. ការបង្កើតរាជរដ្ឋាភិបាល..................................................................................២៥
២.៤. ក្រសួង និងស្ថាប័ននានា..................................................................................២៦
**ផ្នែកទី៣. ការបង្កើតរាជរដ្ឋាភិបាលតាមអាណត្តិសភា២០០៣-២០០៨** ............................២៦
៣.១ ការបង្កើតរដ្ឋសភា...........................................................................................២៧
៣.២. ដំណើរការនៃរដ្ឋសភា......................................................................................២៧
៣.៣. ការបង្កើតរាជរដ្ឋាភិបាល..................................................................................២៨
៣.៤ ការបង្កើតច្បាប់ធម្មនុញ្ញបន្ថែម..........................................................................៣០
៣.៥ ការបង្កើតរាជរដ្ឋាភិបាលដោយការបោះឆ្នោតជាកញ្ចប់..........................................៣០
៣.៦ ក្រសួង និងស្ថាប័ននានា....................................................................................៣១
**ផ្នែកទី៤ ការបង្កើតរាជរដ្ឋាភិបាលតាមអាណត្តិសភា២០០៨-២០១៨** ..............................៣១
៤.១ ការបង្កើតរដ្ឋសភា...........................................................................................៣២
៤.២. ដំណើរការនៃរដ្ឋសភា......................................................................................៣២
៤.៣. ការបង្កើតរាជរដ្ឋាភិបាល..................................................................................៣៣
៤.៤. ក្រសួង និងស្ថាប័ននានា..................................................................................៣៣
**ផ្នែកទី៥. ការបង្កើតរាជរដ្ឋាភិបាលតាមអាណត្តិសភា២០១៣-២០១៨** ............................៣៤
៥.១. ការបង្កើតរដ្ឋសភា..........................................................................................៣៥
៥.២. ដំណើរការនៃរដ្ឋសភា......................................................................................៣៧
៥.៣. ការបង្កើតរាជរដ្ឋាភិបាល..................................................................................៣៨
៥.៤. ក្រសួង និងស្ថាប័ននានា..................................................................................៣៩
**ផ្នែកទី៦ ការទ្បើតរាជរដ្ឋាភិបាលតាមអាណាណត្តិសភា២០១៨-២០២៣**..........................៣៩

៦.១. ការបង្កើតរដ្ឋសភា......................................................................................................៤០
៦.២. ដំណើរការនៃរដ្ឋសភា....................................................................................................៤០
៦.៣. ការបង្កើតរាជរដ្ឋាភិបាល..................................................................................................៤១
៦.៤. ក្រសួង និងស្ថាប័ននានា..................................................................................................៤១
**ផ្នែកទី៧. បញ្ហាប្រឈមនិងដំណោះស្រាយ**.............................................................................៤២
៧.១ បញ្ហាប្រឈមមុខនៅពេលបង្កើតរាជរដ្ឋាភិបាល...........................................................៤២
៧.២ ដំណោះស្រាយតាមផ្លូវច្បាប់........................................................................................៤៤
**សេចក្ដីសន្និដ្ឋាន**..................................................................................................................៤៦
**អនុសាសន៍**...........................................................................................................................៤៨
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# សេចក្តីផ្តើម

# សេចក្តីផ្តើម

## ១. លំនាំបញ្ហា

តាំងពីអតីតកាលជាយូរឆ្នាំកន្លងមក ដែលប្រទេសកម្ពុជាយើងធ្លាប់បានជួបប្រទះនឹងសង្គ្រាមស៊ីវិលជាបន្តបន្ទាប់អស់រយៈពេលជាង ២០ (ម្ភៃ) ឆ្នាំទៅនេះ។ នៅក្នុងឆ្នាំ ១៩៩១ ភាគីនៅក្នុងជម្លោះបានឈានដល់ការចុះកិច្ចព្រមព្រៀងបញ្ចប់ការប្រយុទ្ធ។ ទោះបីជាយ៉ាងណាគេត្រូវរង់ចាំរហូតដល់ ឆ្នាំ ១៩៩៣ ទើបមានការបោះឆ្នោតជាតិមួយ ត្រូវបានរៀបចំទ្បើងដោយអាជ្ញាធរបណ្តោះអាសន្នអង្គការសហប្រជាជាតិនៅកម្ពុជា ហៅកាត់ថា (អ៊ុនតាក់) ក្រោយកិច្ចសហការជាមួយនិងក្រុមប្រឹក្សាជាតិជាន់ខ្ពស់នៃកម្ពុជាដែលគេឲ្យឈ្មោះថា (អេសអិនស៊ី)។ នៅក្នុងការបោះឆ្នោតជាតិលើកទីមួយត្រូវបានធ្វើឡើងនៅថ្ងៃ ទី២៣ ដល់២៨ ខែឧសភា ឆ្នាំ១៩៩៣។
បើទោះបីជាមានអស្ថេរភាព នៅតាមតំបន់ខ្លះគ្រប់គ្រងដោយខ្មែរក្រហមអ្នកបោះឆ្នោតមានចំនួនច្រើន ស្មើនិង ៨៦.៧៨% នៃអ្នកចុះឈ្មោះបោះឆ្នោតសរុបជិត ៥ លាននាក់។ គណបក្សនយោបាយចំនួន ៤ បានឈ្នះអាសនៈនៅក្នុងសភាធម្មនុញ្ញប៉ុន្តែគ្មានគណបក្សណាគ្រប់គ្រងអាសនៈភាគច្រើនលើសលប់ ២/៣ ដែលត្រូវការចាំបាច់សម្រាប់បង្កើតរដ្ឋាភិបាលថ្មីនោះទេដែលជាហេតុនាំឲ្យមានរដ្ឋាភិបាលចម្រុះ។

បន្ទាប់ពីការបោះឆ្នោតនៅ ឆ្នាំ ១៩៩៨ បានធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញដើម្បីបង្កើតសភាមួយថ្នាក់ទៀត គឺស្ថាប័នព្រឹទ្ធសភា ដែលជាផ្លែផ្កានៃការមូលមតិគ្នាខាងនយោបាយសំដៅ ដោះស្រាយភាពជាប់គាំងខាងនយោបាយដែល អង្គនីតិប្រតិបត្តិមិនអាចបង្កើតបានដោយសារលក្ខខណ្ឌសម្លេងភាគច្រើនលើសលប់ ២/៣ នៅក្នុងរដ្ឋសភា។ ដល់ឆ្នាំ ១៩៩៩ ស្ថាប័នព្រឹទ្ធសភាត្រូវបានបង្កើតឡើង។ សមាជិកព្រឹទ្ធសភាមានចំនួនស្មើនឹងពាក់កណ្តាលនៃសមាជិករដ្ឋសភាទាំងមូល។ (មាត្រា ៩៩ ថ្មី នៃរដ្ឋធម្មនុញ្ញ) សមាជិកព្រឹទ្ធសភាចំនួន ២ រូបត្រូវបានចាត់តាំងដោយព្រះមហាក្សត្រ និងសមាជិកព្រឹទ្ធសភា ២ រូបទៀតត្រូវបានជ្រើសតាំងដោយរដ្ឋសភាតាមមតិភាគច្រើនដោយប្រៀប។រីឯ សមាជិកព្រឹទ្ធសភាផ្សេងទៀតត្រូវបានជ្រើសតាំងដោយការបោះឆ្នោតអសកល។ នៅឆ្នាំ ២០០២ ការបោះឆ្នោតនៅរដ្ឋបាលក្រោមជាតិត្រូវបានធ្វើឡើងជាសកល និងដោយផ្ទាល់សម្រាប់ឃុំ និងសង្កាត់។ ក្រោយការប្រកាសឲ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងក្រុមប្រឹក្សាឃុំ-សង្កាត់ គ្រប់សមាជិកក្រុមប្រឹក្សាត្រូវបានបោះឆ្នោតជ្រើសតាំងដោយផ្ទាល់ពីប្រជាពលរដ្ឋខ្មែរស្របតាមប្រព័ន្ធបោះឆ្នោតសមាមាត្រ។

ក្រុមប្រឹក្សាដែលកើតចេញពីការបោះឆ្នោតនេះ និង គ្រប់គ្រងមូលនិធិនិងធនធានផ្ទាល់ខ្លួនព្រមទាំងដឹកនាំចាត់ចែងកិច្ចការក្នុងមូលដ្ឋានខ្លួនរាប់បញ្ចូលទាំងការអភិវឌ្ឍន៍និង សន្តិភាព។ ប៉ុន្តែគេត្រូវរង់ចាំរហូតដល់

ឆ្នាំ ២០០៩ ទើបរាជរដ្ឋាភិបាលនៃប្រទេសកម្ពុជាពង្រីកវិសាលភាពនៃកំណែទម្រង់រដ្ឋបាលរបស់ខ្លួនការបោះឆ្នោតត្រូវបានរៀបចំរហូតទៅដល់រដ្ឋបាលដែនដីថ្នាក់ខ្ពស់។

ជាលទ្ធផលនៃកំណែទម្រង់វិមជ្ឈការ និង វិសហមជ្ឈការ ការបោះឆ្នោតត្រូវបានរៀបចំឡើងសម្រាប់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ប៉ុន្តែការបោះឆ្នោតអសកល និងមិនផ្ទាល់។ រហូតមកទល់បច្ចុប្បន្ននេះ ការបោះឆ្នោតជាតិសម្រាប់រដ្ឋសភាត្រូវបានរៀបចំឡើងចំនួន ៦ ដំណាក់កាលរួចមកហើយ គឺនៅឆ្នាំ ១៩៩៣, ១៩៩៨, ២០០៣, ២០០៨, ២០១៣, និងឆ្នាំ ២០១៨។ ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភាទើបតែត្រូវបានធ្វើឡើងចំនួន ៣ លើកប៉ុណ្ណោះនៅឆ្នាំ ២០០៦ ,២០១២ និងឆ្នាំ ២០១៨ ។ នៅថ្នាក់មូលដ្ឋានការបោះឆ្នោតជ្រើសតាំងក្រុមប្រឹក្សាឃុំ-សង្កាត់ត្រូវបានរៀបចំឡើងចំនួន ៥ លើក គឺ នៅឆ្នាំ ២០០២ ឆ្នាំ ២០០៧, ២០១២,២០១៧ និងឆ្នាំ២០២២ ខណៈក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌទើបមានការបោះឆ្នោតជ្រើសតាំងចំនួន ៣ លើក គឺនៅឆ្នាំ ២០០៩ និងឆ្នាំ ២០១៤ និងឆ្នាំ២០១៩ (ការគ្រប់គ្រង, រដ្ឋបាលមូលដ្ឋាន)។ ចាប់តាំងពីការបោះឆ្នោតជាតិឆ្នាំ ១៩៩៣ មកកើតមាននូវភាពជាប់គាំងខាងនយោបាយបានក្លាយទៅជាប្រពៃណីទៅហើយ នៅក្រោយការប្រកាសលទ្ធផលនៃការបោះឆ្នោត។ គណបក្សនយោបាយខ្លះមិនទទួលយកលទ្ធផល នៃការបោះឆ្នោតដោយអះអាងពីភាពមិនប្រក្រតី។

គណបក្សឈ្នះឆ្នោតមិនអាចឈានទៅដល់ការបង្កើតរដ្ឋាភិបាលដោយខ្លួនឯង។ មានន័យថា ការបង្កើតរដ្ឋាភិបាលចម្រុះមិនអាចជៀសផុតហើយជាវិបាកការធ្វើសម្បទានខាងនយោបាយ គឺមិនអាចខ្វះបាន។ កំណែទម្រង់ ជាច្រើនបានកើតមានឡើងនៅក្រោយការបោះឆ្នោតឆ្នាំ ២០១៨ ជាពិសេសទាក់ទងនឹងច្បាប់បោះឆ្នោត នឹងគណៈកម្មាធិការរៀបចំការបោះឆ្នោត។ យោងទៅតាមកិច្ចព្រមព្រៀងនយោបាយ ថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០១៤ រវាង គណបក្សប្រជាជនកម្ពុជា និងគណបក្សសង្គ្រោះជាតិ គណៈកម្មាធិការពិសេសត្រូវបានដំឡើងពី ៩ គណៈកម្មាធិការមក១០ គណកម្មាធិការ ហើយគណបក្សនីមួយៗ ដឹកនាំម្នាក់ ៥ គណៈកម្មាធិការ។ លើសពីនេះដោយសារមានគណបក្សតែ ២ ប៉ុណ្ណោះនៅក្នុងរដ្ឋសភា។

## ២. ចំណោទបញ្ហា

តាមការសិក្សាពីប្រវត្តិសាស្ត្រកន្លងមក ទាក់ទងនិងរដ្ឋាភិបាលប្រទេសកម្ពុជាយើងសង្កេតឃើញថា រដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣កន្លងមកកើតមានការបោះឆ្នោតជាច្រើនដំណាក់កាលនៅក្នុងការបោះឆ្នោតជ្រើសរើសប្រធាន និងអនុប្រធានរដ្ឋសភា ក៏ដូចជាជ្រើសរើស នាយករដ្ឋមន្ត្រី ត្រូវការសម្លេងគាំទ្រ ២/៣ ទើបអាចជ្រើសតាំងបាន។ ដោយសារគណបក្សហ៊្វុនស៊ិនប៉ិច និង គណបក្ស សម រង្ស៊ី បានបង្កើតសម្ព័ន្ធភាពអ្នកប្រជាធិបតេយ្យដែលមិន

ព្រមឲ្យគណបក្សណាមួយចូលជាមួយគណបក្សប្រជាជនដើម្បីបង្កើតរដ្ឋាភិបាលបាន (បើចូល ចូលទាំងអស់គ្នា បើចេញ ចេញទាំងអស់គ្នា) ស្ថានភាពនយោបាយក៏ត្រូវបានកកស្ទះ។ ក្រោយពីកើតមានបញ្ហានេះ ឡើង ក៏មានដំណោះស្រាយចំពោះភាពទាល់ច្រកបានចេញរួចផងដែរ។ ក្នុងនោះមានគណបក្ស ហ្វ៊ុនស៊ិនប៉ិច ព្រមចូលរួមបង្កើតរដ្ឋាភិបាលចម្រុះ ជាមួយគណបក្សប្រជាជនការជាប់គាំងខាងនយោបាយត្រូវបានដោះស្រាយចេញបាន។ គណបក្សទាំងពីគណបក្ស ហ្វ៊ុនស៊ិនប៉ិច និង គណបក្ស សម រង្ស៊ី មិនចង់ចូលរួមក្នុងការបង្កើតរដ្ឋាភិបាលស្របច្បាប់នេះតាំងពីឆ្នាំ១៩៩៣ ដោយសារតែប្រទេសកម្ពុជាមានការបោះឆ្នោតទទួលបាននូវអាសនៈ និងសម្លេងស្មើគ្នាទើបកើតមាននូវបញ្ហាដែលមិនធ្លាប់មានពីមុនមកហើយ និង គណបក្សប្រឆាំងមិនចូលរួមប្រជុំក្នុងសភាដែលជាបញ្ហាដ៏ធំក្នុងការបង្កើតរដ្ឋាភិបាល។ ដូច្នេះ ហើយបានជាគេបង្កើតឲ្យមាននាយករដ្ឋមន្ត្រីពីរដែលគេហៅថា "**សហនាយករដ្ឋមន្ត្រី**"។ ដើម្បីដោះស្រាយនូវវិបត្តិជាប់គាំងខាងផ្នែកនយោបាយក្នុងការបង្កើតរដ្ឋាភិបាល ***តើប្រទេសកម្ពុជាគួរមានការដោះស្រាយបែបណា? តើនៅក្នុងខណៈនោះការរៀបចំបោះឆ្នោតប្រព្រឹត្តទៅបានដោយសុក្រឹត្យ យុត្តិធម៌ ដែលឬទេ? តើគណបក្សនយោបាយនីមួយៗពេញចិត្តនូវលទ្ធផលដែលខ្លួនទទួលបានដែល ឬយ៉ាងណា? តើការវិវត្តន៍នៃរាជរដ្ឋាភិបាលកម្ពុជាពី១៩៩៣ ដល់បច្ចុប្បន្ន មានការវិវត្តន៍យ៉ាងណាខ្លះ?***

## ៣. គោលបំណងនៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវប្រធានបទ "***ការវិវត្តន៍នៃរាជរដ្ឋាភិបាលកម្ពុជា ឆ្នាំ ១៩៩៣ ដល់បច្ចុប្បន្ន***" មានគោលបំណងដូចជា៖

- ✓ ការសិក្សាផ្តោតសំខាន់ទៅលើរាជរដ្ឋាភិបាលកម្ពុជាឆ្នាំ ១៩៩៣ ដល់បច្ចុប្បន្ន។
- ✓ ការសិក្សាទៅលើបញ្ហាប្រឈមនៅពេលបង្កើតរាជរដ្ឋាភិបាលកម្ពុជា និងដំណោះស្រាយតាមផ្លូវច្បាប់។
- ✓ ស្វែងយល់អំពីការបង្កើតរាជរដ្ឋាភិបាលទៅតាមអាណត្តិរដ្ឋសភានៃនីតិកាលនីមួយៗ
- ✓ រាជរដ្ឋាភិបាលកើតចេញពីការបោះឆ្នោតផ្តល់សេចក្តីទុកចិត្តពីរដ្ឋសភា។
- ✓ យល់ដឹងពីការផ្លាស់ប្តូរ និងការស្រាវជ្រាវពីឯកសារច្បាប់ក៏ដូចជាក្រសួងដែលពាក់ព័ន្ធនានា។

## ៤. ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវនេះ គឺផ្តោតសំខាន់ទៅលើការវិវត្តន៍រាជរដ្ឋាភិបាលកម្ពុជា ឆ្នាំ១៩៩៣ ដល់បច្ចុប្បន្ន។ ដែលប្រទេសយើងសព្វថ្ងៃប្រកាន់ភ្ជាប់នូវរបបកម្ពុជាប្រជាធិបតេយ្យសេរីពហុបក្ស។ ក្នុងនោះដែរ រាជរដ្ឋាភិបាលត្រូវបានបង្កើតឡើងដោយអាណត្តិរដ្ឋសភានីតិកាលនីមួយៗចាប់ពីឆ្នាំ១៩៩៣រហូតដល់បច្ចុប្បន្នមានការវិវត្តន៍ចំនួន ៦ លើករួចមកហើយលើកទី១ឆ្នាំ ១៩៩៣-១៩៩៨ លើកទី២ ឆ្នាំ ១៩៩៨-២០០៣ លើកទី៣ ឆ្នាំ ២០០៣-

២០០៨ លើកទី៤ ឆ្នាំ ២០០៨-២០១៣ លើកទី៥ ឆ្នាំ ២០១៣-២០១៨ និងលើកទី៦ ឆ្នាំ ២០១៨-២០២៣។ ការប្រែប្រួលទៅតាមការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនៃនីតិកាលរដ្ឋសភា។

ដូចនេះ រដ្ឋាភិបាលបានកើតឡើងដោយការបោះឆ្នោតទៅតាមអាណត្តិសភា។ សភាមានអាណត្តិ ៥ ឆ្នាំ រដ្ឋាភិបាលក៏ត្រូវមានអាណត្តិ៥ ឆ្នាំដូចគ្នា។

## ៥. សារៈសំខាន់នៃការស្រាវជ្រាវ

នៅក្នុងការជ្រើសរើសយកនូវប្រធានបទនេះ លើកយកមកសិក្សាក្រុមយើងខ្ញុំពិតជាសង្ឃឹមជឿជាក់ក្នុងចិត្តថានឹងទទួលបាននូវចំណេះដឹងក៏ដូចជាបទពិសោធន៍យ៉ាងច្រើនសម្រាប់អភិវឌ្ឍន៍បំណិនជីវិតរបស់ពួកយើងរួមទាំងយល់ដឹងអំពី រដ្ឋាភិបាល ដំណើការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ទៅតាមនីតិកាលរដ្ឋសភា ច្បាប់នានា ទាក់ទងនិងក្រសួងពាក់ព័ន្ធទៀតផង។ ចំណុចសំខាន់ក្នុងការសិក្សា ដែលក្រុមយើងខ្ញុំទទួលបាន គឺ ជាបទពិសោធន៍មួយដ៏ល្អដែលជាជំនួយនូវស្មារតី បណ្តុះគំនិត ការយល់ដឹងដ៏ជ្រាលជ្រៅក្រៃលែងក្នុងការសិក្សា។

## ៦. វិធីសាស្ត្រនៃការស្រាវជ្រាវ

វិធីសាស្ត្រនៃការស្រាវជ្រាវ គឺកំណត់បញ្ហាស្រាវជ្រាវ រៀបចំការស្រាវជ្រាវ ប្រមូលទិន្នន័យ វិភាគទិន្នន័យ បកស្រាយទិន្នន័យ ដើម្បីជួយដោះស្រាយបញ្ហាដែលបានកំណត់។

-**កំណត់បញ្ហាស្រាវជ្រាវ**: យើងត្រូវស្វែងយល់អំពីប្រធានបទដែលយកមកសិក្សា និងចំនុចសំខាន់ដែលមានបង្កប់នៅក្នុងអត្ថបទ និយាយពីរដ្ឋាភិបាល ថាមានអ្វីដែលកើតឡើងធ្វើឲ្យមានការផ្លាស់ប្តូរពីដំណាក់កាលមួយទៅមួយដំណាក់កាលមួយទៀត។

-**រៀបចំការស្រាវជ្រាវ**:ដើម្បីធ្វើការរៀបចំការស្រាវជ្រាវ បានក៏ដូចជាការចងក្រងសៀវភៅមួយឲ្យមានភាពទាក់ទាញចំណាប់អារម្មណ៍ដល់អ្នកដែលបានអានមិនមានភាពធុញទ្រាន់ យើងត្រូវរៀបចំនូវឃ្លានីមួយៗឲ្យបានល្អ និង រំលេចចេញជារូបរាងឡើងឲ្យឃើញពីភាពពិតជាក់ស្តែង នូវក្នុងសង្គមដែលជាគន្លឹះក្នុងការធ្វើជាបទពិសោធន៍ល្អៗ សម្រាប់ជួយណែនាំការពន្យល់អំពីចំណុច ជាច្រើនថែមទាំងបកស្រាយ នូវខ្លឹមសារមួយចំនួនសម្រាប់កំណត់គោលដៅ។

ជាក់ស្តែងដែលក្រុមយើងខ្ញុំបានលើកយកនូវប្រធានបទ *"ការវិវត្តន៍រាជរដ្ឋាភិបាលកម្ពុជាឆ្នាំ ១៩៩៣ ដល់បច្ចុប្បន្ន"* លើកមកធ្វើជាសៀវភៅសម្រាប់ទុកជាស្នាដៃ។

-**ប្រមូលទិន្នន័យ**: ការស្រាវជ្រាវពីប្រភពឯកសារមួយចំនួនមានដូចជា សៀវភៅឯកសារច្បាប់មួយចំនួនទាក់ទងនិងប្រធានបទ និងសម្រាប់យកមកធ្វើការចងក្រងបាន។

**-វិភាគទិន្នន័យ:** ក្រោយពីការសិក្សារៀបរៀងរួចមកយើងអាចយកមកវិភាគផ្ទៀងផ្ទាត់បាន។

**-បកស្រាយទិន្នន័យ:** នៅពេលដែលយើងរកបានឯកសារមួយចំនួនដែលពាក់ព័ន្ធយើង និង ធ្វើការវិភាគទៅលើចំណុចមួយចំនួនដែលជាទិន្នន័យដែលបានអាចទទួលយកបានក្នុងការស្រាវជ្រាវ។ ដូច្នេះ យើងត្រូវយកទៅវាយតម្លៃតាមភាពជាក់ស្តែងដែលមាននៅក្នុងចំណុចនីមួយៗមានស្រាប់ហើយនេះ។

## ៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

ក្រោយពីយើងខ្ញុំ បានសិក្សាជាមួយគ្នាក៏ដូចជាការផ្តល់ជា គំនិតយោបល់ដ៏មានអត្ថន័យពីសាស្ត្រាចារ្យណែនាំរួចមក ទាក់ទងនិង ការស្វែងរកឯកសារពាក់ព័ន្ធ ក៏ដូចជាការផ្តល់ជាគន្លឹះក្នុងការបែងចែកបានជារចនាសម្ព័ន្ធដូចខាងក្រោម៖

**១. សេចក្តីផ្តើម៖** សិក្សាទៅលើចំណុចសំខាន់ៗមានដូចជា លំនាំបញ្ហានៃការស្រាវជ្រាវ ចំណោទបញ្ហានៃការស្រាវជ្រាវ គោលបំណងនៃការស្រាវជ្រាវ ទំហំនិងដែនកំណត់នៃការស្រាវជ្រាវ សារៈសំខាន់នៃការស្រាវជ្រាវ វិធីសាស្ត្រនៃការស្រាវជ្រាវ និងរចនាសម្ព័ន្ធនៃការស្រាវជ្រាវ។

**ជំពូកទី១៖ សញ្ញាណទូទៅនៃរដ្ឋាភិបាល**

**ជំពូកទី២៖ នីតិវិធីបង្កើតរាជរដ្ឋាភិបាលកម្ពុជាឆ្នាំ ១៩៩៣ ដល់បច្ចុប្បន្ន**

**សេចក្តីសន្និដ្ឋាន**

**អនុសាសន៍**

**ឯកសារយោង**

**ឧបសម្ព័ន្ធ**

# ជំពូកទី១
# សញ្ញាណទូទៅនៃរដ្ឋាភិបាល

# ជំពូកទី១

# សញ្ញាណទូទៅនៃរដ្ឋាភិបាល

## ១. និយមន័យរដ្ឋាភិបាល

រដ្ឋាភិបាលគឺជាធាតុផ្សំដ៏សំខាន់របស់រដ្ឋ ដែលចាំបាច់ត្រូវបង្កើតដើម្បីគ្រប់គ្រងចាត់ចែង និងអភិវឌ្ឍន៍ប្រកបដោយចេរភាព។ រដ្ឋាភិបាល ត្រូវតែជារដ្ឋាភិបាលស្របច្បាប់និងមានសមត្ថភាពគ្រប់គ្រាន់ក្នុងការធ្វើទំនាក់ទំនងអន្តរជាតិផងដែរ។ ម្យ៉ាងវិញទៀតការបង្កើតរដ្ឋាភិបាល ត្រូវធ្វើឡើងស្រប.ទៅនឹងគោលការណ៍ច្បាប់ និងរបបគ្រប់គ្រងរដ្ឋ។ រដ្ឋាភិបាលត្រូវបានគេឲ្យនិយមន័យជាពីរ៖ ក្នុងន័យទូលាយ រដ្ឋាភិបាល គឺ ក្រសោបស្ថាប័នកំពូលទាំងបីរបស់រដ្ឋដែលរួមមានស្ថាប័ននីតិប្បញ្ញត្តិ នីតិប្រតិបត្តិ និងតុលាការ។ ស្ថាប័នទាំងបីថ្វីត្បិតតែមានការបែងចែកអំណាច និងតួនាទីដាច់ចេញពីគ្នាក៏ដោយក៏ស្ថាប័នទាំងបី នេះបានបំពេញនិងមានទំនាក់ទំនង និងគ្នាជានិច្ច។ ចំណែកឯក្នុងន័យចង្អៀតរដ្ឋាភិបាលសំដៅត្រឹមតែ ស្ថាប័ននីតិប្រតិបត្តិ ដែលមានតួនាទីជាអ្នកអនុវត្តច្បាប់ និងធ្វើឲ្យប្រជាពលរដ្ឋ មានសុវត្ថិភាព ព្រមទាំងជាអ្នកផ្តល់សេវា នានាជូន សង្គមប៉ុណ្ណោះ។ រដ្ឋាភិបាលកម្ពុជាគ្រប់គ្រងប្រទេស ដោយផ្ទាល់ដឹកនាំកសាងនិងពង្រឹងសេដ្ឋកិច្ច សំដៅអភិវឌ្ឍន៍ប្រទេសជាតិទាំងមូលលើគ្រប់វិស័យ[1]។

## ២. ការបង្កើតរដ្ឋាភិបាលតាមប្រព័ន្ធឯកសភា

នាសតវត្សទី២០ ប្រព័ន្ធឯកសភា មានប្រជាប្រិយភាពជាងមុនដែលធ្វើឲ្យប្រទេសមួយចំនួនបានប្រែក្លាយពី ប្រទេសប្រព័ន្ធទ្វិសភាទៅជាប្រព័ន្ធឯកសភាវិញដូចជា៖ ប្រទេសក្រិច ប្រទេសញ៉ូស៊ីឡេន និង ប្រទេសប៉េរូ ជាដើម។ ហើយប្រទេសតូចៗជាច្រើនទៀតដែលប្រកាន់របបប្រជាធិបតេយ្យសេរីពហុបក្សដ៏យូរលុងមកហើយ នឹងអាចប្រែក្លាយទៅជាប្រទេសដែលមានប្រព័ន្ធឯកសភា ដោយឡែកប្រទេសធំៗភាគច្រើនអាចនឹងមានប្រព័ន្ធឯកសភា ឬប្រព័ន្ធទ្វិសភា។

### ក.និយមន័យឯកសភា

**ឯកសភា** គឺសំដៅដល់រដ្ឋដែលមានសភាតែមួយជាន់គឺមានតែសភាជាន់ទាបប៉ុណ្ណោះ។

[1] ដកស្រង់ចេញពី សៀវភៅកិច្ចការស្រាវជ្រាវ តួនាទីសមាជិករាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា រៀបរៀងដោយនិស្សិត ខេន គីមស្រ៊ុន

**គុណសម្បត្តិ**

- ជាប្រជាធិបតេយ្យផ្ទាល់
- មិនអនុញ្ញាតឲ្យមានយុទ្ធសាស្ត្រពន្យាពេលទេ។
- ងាយស្រួលក្នុងការថែរក្សា និងដំណើរការសភាពីព្រោះចំណាយថវិកាតិច។
- រក្សាទស្សន និងគំនិតឯកភាពរដ្ឋ ពោលគឺទស្សនៈ និងគំនិតដូចគ្នាជាមួយរដ្ឋាភិបាល ឬរដ្ឋ។
- ជៀស ផុតពីការរើសអើង ឬជម្លោះរវាងសភាទាំងពីរដែលជាទូទៅតែងតែកើតមានឡើងនៅក្នុងបណ្តាប្រទេសដែលមានសភាពីរជាន់។
- ធ្វើច្បាប់ មានការងាយស្រួល លឿន ទាន់ពេលវេលា។

**គុណវិបត្តិ**

- អាចបង្កើតឲ្យមានភាពផ្តាច់ការ ពីព្រោះសភា និង រដ្ឋាភិបាលគឺតែ១។
- ទទួលឥទ្ធិពលពីរដ្ឋាភិបាល។
- សេចក្តីព្រាងច្បាប់មិនបានពិភាក្សា ផ្តល់យោបល់បានល្អិតល្អន់ល្អមុននឹងត្រូវបានសភាអនុម័ត។
- គ្មានការជួយគាំទ្រ ជួយត្រួតពិនិត្យពីសភា១ទៀត។

ប្រទេសដែលប្រកាន់ ប្រព័ន្ធឯកសភា នៅលើពិភពលោកមានប្រទេសមួយចំនួនដែលប្រកាន់យកនូវប្រព័ន្ធឯកសភានេះផងដែរដូចជា៖ ប្រទេសអាមេនី ប្រទេសប៊ុលហ្គារី ប្រទេសដាណឺម៉ាក់ ប្រទេសហុងហ្គារី ប្រទេសម៉ូណាកូ ប្រទេសអ៊ុយក្រែន ប្រទេសស៊ែបប៊ី ប្រទេសទួកគី និង ប្រទេសស៊ុីសជាដើម។ ម្យ៉ាងទៀត ប្រទេសស៊ុីស(SWEDEN) មានប្រព័ន្ធឯកសភា ដែលព្រះមហាក្សត្រជា ប្រមុខរដ្ឋ និង ជានាយករដ្ឋមន្ត្រីដែលកាន់អំណាចនីតិប្រតិបត្តិ។ នៅក្នុងសភា មានអសនៈចំនួន ៣៤៩កៅអី ទទួលបានសម្លេងថ្នាក់ជាតិគាំទ្រចំនួន ៤%ទើបបាន១កៅអី។ ចំនួនអាសនៈដែលគណបក្សនីមួយៗដែលទទួលបានអាស្រ័យលើចំនួនសន្លឹកឆ្នោតគាំទ្រជាផ្លូវការតាមមណ្ឌលបោះឆ្នោតនិងតាមប្រព័ន្ធសមាមាត្រ។ នៅឆ្នាំ២០២០ សភាប្រទេសស៊ុីស មានគណបក្សនយោបាយចំនួន៩គណបក្សគឺ៖

.សង្គមប្រជាធិបតេយ្យមាន១០០ អាសនៈ២៨.៧%

.ប្រជាធិបតេយ្យ មាន៧0 អាសនៈ ២១.១%

.គណបក្សប៉េតង មាន១ អាសន ៤.៦%

.គណបក្សឯករាជ មាន១ អាសនៈ 0.៦% ។

## ខ. និយមន័យទ្វិកសភា

**ទ្វិកសភា** គឺសំដៅដល់រដ្ឋដែលមានសភាពីរជាន់ពោលគឺព្រឹទ្ធសភានិងរដ្ឋសភា ឬ សភាជាន់ខ្ពស់ និង សភាជាន់ទាប។ សេចក្តីព្រាងច្បាប់ ត្រូវស្នើដោយ សមាជិកសភា ឬ សមាជិកព្រឹទ្ធសភា ឬ ដោយរដ្ឋាភិបាល។ រាល់សេចក្តីព្រាងទាំងអស់ត្រូវអនុម័តផ្តល់សេចក្តីទុកចិត្តតាមសម្លេងធម្មតា៥០%បូក១ លើកលែងតែច្បាប់ថវិកា និងច្បាប់វិសោធនកម្មរដ្ឋធម្មនុញ្ញ។ សភា មានសមត្ថកិច្ចអនុម័តផ្តល់សេចក្តីទុកចិត្តលើនាយករដ្ឋមន្ត្រី ហើយ មានការកំណត់អាណត្តិច្បាស់លាស់ពោលគឺចប់អាណត្តិត្រូវបានបោះតឆ្នោតជ្រើសតាំងជាថ្មី។ សមាជិកសភា និងនាយករដ្ឋមន្ត្រី មិនមាន កំណត់ដងនៃការឈរឈ្មោះទេពេលចប់អាណត្តិអាចបន្ត ឈរឈ្មោះ នៅអាណត្តិ ក្រោយៗទៀតបាន។

**គុណសម្បត្តិ**

- ផ្តល់ឲ្យមានតុល្យភាពអំណាចរវាងសភា ទាំងពីរការពារការរំលោភអំណាចដែលនាំឲ្យមានការលំបាក ក្នុងការធ្វើច្បាប់។
- ច្បាប់មានភាពល្អប្រសើរដោយសារសេចក្តីព្រាងច្បាប់ត្រូវបានពិភាក្សាពិគ្រោះយោបល់បានយ៉ាងល្អិត ល្អន់ត្រឹមត្រូវ។
- អ្នកដឹកនាំកិច្ចប្រជុំសភាពិបាកអូសទាញបញ្ចុះបញ្ចូលសមាជិកសភាទាំងពីរឲ្យមានភាពលម្អៀងមក តាមអ្នកដឹកនាំប្រជុំបានឡើយ។
- សភាជាន់ខ្ពស់ ជួយកាត់បន្ថយការងាររបស់សភាជាន់ទាប។
- ចំពោះសហព័ន្ធ BICAMERAL បានធ្វើឲ្យមានអ្នកតំណាងប្រជាពលរដ្ឋគ្រប់គ្រាន់ និងស្មើភាពក្នុង សហព័ន្ធ។
- សភាជាន់ខ្ពស់ បានត្រួតពិនិត្យសេចក្តីព្រាងច្បាប់ម្តងទៀតដើម្បីជៀសវាងកំហុស ការធ្វេសប្រហែស និងចេតនាមិនល្អនានា។
- ការពារអត្ថប្រយោជន៏ជនជាតិភាគតិច។
- ធ្វើឲ្យមានការបញ្ចេញមតិសាធារណទៅលើបញ្ហាប្រឈមមុននឹងសេចក្តីព្រាងច្បាប់ត្រូវបានអនុម័ត តាមរយៈការពន្យាពេលសេចក្តីព្រាងច្បាប់ក្នុងសភាទាំងពីរ។

**គុណវិបត្តិ**

- សភាជាន់ខ្ពស់អាចក្លាយជាឧបករណ៏នយោបាយក្នុងការបដិសេធ ឬ ក្នុងការស្ទង់មតិប្រសិនបើសមាជិកសភាជាន់ខ្ពស់ជា អ្នកនយោបាយប្រកាន់ទស្សនៈ តាមគណបក្សនយោបាយរបស់ប្រធានាធិបតី។
- សភាទាំងពីរមានមុខងារ និង តួនាទីត្រួតគ្នាដោយសារជាអំណាចនីតិប្បញ្ញត្តិតែមួយ។
- ខាតបង់ថវិការដ្ឋច្រើន។
- ក្នុងករណីគ្រាអាសន្នការអនុម័តសេចក្តីព្រាងច្បាប់មានការយឺតយ៉ាវមិនទាន់ពេលវេលា។
- សមាជិកសភាជាន់ខ្ពស់ភាគច្រើនមានវ័យចាស់ជរា ឬ មានអាយុច្រើន  សកម្មភាពអសកម្ម។
- សមាជិកសភាជាន់ខ្ពស់ភាគច្រើនមិនបានធ្វើការបោះឆ្នោតដោយផ្ទាល់នោះទេ ពោលគឺភាគច្រើនធ្វើការជ្រើសតាំងដូច្នេះមិនស្របទៅនឹងគោលការណ៏ប្រជាធិបតេយ្យសេរីពហុបក្ស។

ប្រទេសដែលប្រកាន់ប្រព័ន្ធទ្វិកសភានៅលើពិភពលោកមានប្រទេសភាគច្រើន ដែលប្រកាន់យកនូវប្រព័ន្ធទ្វិកសភាដូចជា៖ ប្រទេសអ៊ីតាលី ប្រទេសជប៉ុន ប្រទេសប៊ែហ្ស៊ិច ប្រទេសកាណាដា ប្រទេសអូស្ត្រាលី ប្រទេសអាស្សង់ទីន ប្រទេសប្រេស៊ីល ប្រទេសអូទ្រីស ប្រទេសអាល្លឺម៉ង់ ប្រទេសឥណ្ឌា ប្រទេសម៉េកស៊ិកូ ប្រទេសនេប៉ាល់ .ប្រទេសបារាំង ប្រទេសសហព័ន្ធរុស្ស៊ី ចក្រភពអង់គ្លេស សហរដ្ឋអាមេរិច សាធារណរដ្ឋប្រជាមានិតចិន ព្រះរាជាណាចក្រថៃឡង់ ព្រះរាជាណាចក្រកម្ពុជា និង សាធារណរដ្ឋសង្គមនិយមវៀតណាម ជាដើម។

ជាក់ស្តែងនៅប្រទេសបារាំង(REPUBLIC OF FRANCE) នៅសាធារណរដ្ឋបារាំង បានប្រកាន់យកនូវប្រព័ន្ធទ្វិកសភាគឺ សភាពីរជាន់មានរដ្ឋសភា និងព្រឹទ្ធសភា។

- **រដ្ឋសភា**

រដ្ឋសភាមាន អាណត្តិ ៥ ឆ្នាំ

ចំនួនសមាជិក   ៥៧៧ នាក់

ចំនួនសមាជិក   ១១នាក់តំណាងពលរដ្ឋនៅបរទេស

ប្រព័ន្ធ   ឯកត្តនាម ពីរជុំ

១ អាសនៈ   ១៤ រូប ប្រកួតប្រជែង នៅជុំទី១

២ រូប ឬ ៣ ៤រូប   នៅជុំទី២ និង បោះឆ្នោតដោយផ្ទាល់។

ការបោះឆ្នោតជ្រើសរើសសមាជិករដ្ឋសភាបារាំង ត្រូវធ្វើឡើងតាមប្រព័ន្ធឯកត្តនាមពីរជុំ មានន័យថាៈ នៅជុំទី១បើពុំមានបេក្ខជនណាទទួលបានសម្លេងឆ្នោតគាំទ្រ៥០%+១ទេនោះ គេត្រូវបន្តបោះឆ្នោតនៅជុំទី២ ដោយជ្រើសយកបេក្ខជនពីររូបដែលមានសម្លេងគាំទ្រខ្ពស់ជាងគេបន្តបន្ទាប់។ ប៉ុន្តែ ក្នុងករណីមានបេក្ខជនណាដែលមានសម្លេងគាំទ្រលើសពី ១២.៥% ឡើងទៅសុទ្ធតែត្រូវបានឡើងទៅប្រកួតនៅជុំទីពីរទាំងអស់ ទោះបីជា១អាសនៈមានបេក្ខជន៣ឬ៤ រូបក៏ដោយ។ ការបោះឆ្នោតនៅជុំទី២៖ បេក្ខជនណាទទួលបានសម្លេងគាំទ្រច្រើនជាងគេចាត់ទុកថាទទួលបានអាសនៈនោះ។ កាបោះឆ្នោតនៅឆ្នាំ២០១៧ គណបក្សEN MARCHI របស់លោកEmanual Macronទទួលបានអាសនៈចំនួន៥៣០គិត៩១.៨៦% គណបក្សដទៃ ទទួលបាន អាសនៈចំនួន៤៧គិត៨.១៤% សមាសភាពសមាជិករដ្ឋសភាភាគច្រើនមាន វ័យក្មេង និងមានស្ត្រី ៤២%។ ប្រធានរដ្ឋសភាលោកRichard Firrand (១៩៨៩-២០១៦-Socialist party/២០១៦-present Machi party)។

- **ព្រឹទ្ធសភា**

ព្រឹទ្ធសភាមានអាណត្តិ៦ឆ្នាំ ៣ឆ្នាំបោះឆ្នោតជ្រើសរើស១/២នៃសមាជិក

- ចំនួនសមាជិក ៣៤៨ នាក់
- ចំនួនសមាជិក ១២ នាក់ តំណាងពលរដ្ឋនៅបរទេស
- ប្រព័ន្ធ ឯកត្តនាម
- ១ អាសនៈ ១៦២.០០០នាក់
- បោះឆ្នោតមិនផ្ទាល់។

ការបោះឆ្នោតជ្រើសរើសសមាជិនព្រឹទ្ធសភាបារាំង ត្រូវធ្វើឡើងតាមប្រព័ន្ធឯកត្តនាម ភាគច្រើន ដោយមិនផ្ទាល់ពោលគឺត្រូវជ្រើសរើសដោយសមាជិកក្រុមប្រឹក្សាថ្នាក់តំបន់ ខេត្ត និងក្រុង។ប្រធានព្រឹទ្ធសភាលោក Gerard Larcher (Republic party/២០១៦ )ដល់បច្ចុប្បន្ន។

### ៣. ការបង្កើតរដ្ឋាភិបាលតាមរបបនយោបាយនីមួយៗ

ការបង្កើតរដ្ឋាភិបាលទៅតាមរបបនយោបាយនីមួយមានលក្ខណៈខុសៗគ្នាទៅតាមរបបនយោបាយ។ របបនយោបាយមានពីរធំៗ គឺ របបកុំម្មុយនីស្ត និងរបបសេរី។ រដ្ឋាភិបាល ត្រូវបានបង្កើតឡើងតាមរយៈរបបទាំងពីរមានដូចខាងក្រោមនេះ៖

## ៣.១ ការបង្កើតរដ្ឋាភិបាលតាមរបបកុំម្មុយនីស្ត

និយមន័យ របបកុំម្មុយនីស្ត គឺជារបបដែលមានឥទ្ធិពលខ្លាំងណាស់ ក្រោយសង្គ្រាមលោកលើកទី២ ហើយទើបនឹងដួលរលំនៅក្នុងឆ្នាំ ១៩៨៩, ១៩៩០ និង ១៩៩១ នៅក្នុងចំណោមប្រទេសទ្វីបអឺរ៉ុបកណ្តាល និង ខាងកើតដែលមានសហភាពសូវៀតធ្លាក់ទៅជាមួយផង។ សព្វថ្ងៃនៅសល់ប្រទេស ប្រជាមានិតចិន និង វៀត ណាមដែលនៅបន្តកាន់លទ្ធិកុម្មុយនីស្តប៉ុន្តែពុំសូវខ្លាំងដូចជំនាន់មុនៗទៀតឡើយ។ នៅក្នុងរបបមនោគមវិជ្ជា របស់កាលម៉ាក្សដែល ជារបបមូលធននិយមត្រូវតែរលំហើយត្រូវរបបកុម្មុយនីស្តជំនួសការវិវត្តន៍ នៃវិទ្យាសាស្ត្រ ប្រវត្តិសាស្ត្រ និង សង្គមវិទ្យា។ អំណាចផ្តាច់ការនៃវណ្ណៈអធន ដើម្បីឆ្លងទៅកាន់សង្គមនិយម។

កុំម្មុយនីស្តនិយម គឺជារបបមួយដែលគ្មានរដ្ឋ គ្មានវណ្ណៈអ្វីទាំងអស់មានតែអង្គការកុម្មុយនីស្តតែមួយ ប៉ុណ្ណោះ។ ការគ្រប់គ្រងរដ្ឋដឹកនាំដោយបក្សកុម្មុយនីស្ត ដែលជាអង្គការតែមួយគត់ដែលប្រើគោលការណ៍ប្រមូល ផ្តុំប្រជាធិបតេយ្យ។

ប្រមូលផ្តុំប្រជាធិបតេយ្យ គឺជាគោលការណ៍មួយដែលអនុវត្តព្រមគ្នាចំពោះគណបក្ស និងចំពោះរដ្ឋ។ ជា គោលការណ៍ នៅក្នុងការប្រមូលផ្តុំប្រជាធិបតេយ្យមានថ្នាក់ដឹកនាំពីទាបទៅខ្ពស់ ត្រូវជ្រើសរើសដោយការបោះ ឆ្នោតដែលជាវិធីប្រជាធិបតេយ្យ។ នៅក្នុងចំណុចនេះ ថ្នាក់ក្រោមត្រូវរាយការណ៍ទៅអង្គការផ្ទាល់ខ្លួនទៅអង្គការ ថ្នាក់ពីលើហើយរហូតដល់ថ្នាក់កំពូល។ មានការចេញនូវសេចក្តីសម្រេចភាគតិចត្រូវគោរពភាគច្រើន និងអនុវត្ត។ សេចក្តីសម្រេចរបស់ថ្នាក់លើមានឧត្តមភាពជានិច្ចលើថ្នាក់ក្រោម។ មួយវិញទៀតនៅក្នុងរបបសង្គមនិយមក៏មាន កត្តាមួយចំនួនជាមូលដ្ឋាន ៤ សម្រាប់បង្ហាញពីចរិកលក្ខណៈរបស់សង្គមនិយម និង ធានាពីភាពឯកភាពមាន ជាការផ្សារភ្ជាប់ទៅនឹងមនោគមវិជ្ជា ម៉ាក្សស៊ីស-ឡេទីននីស។ សង្គមនិយមភាវូបនីយកម្មសេដ្ឋកិច្ចដោយលុប បំបាត់មូលធននិយម និងការដឹកនាំជាទូទៅដោយបក្សកុម្មុយនីស្ត។ ដូចនេះរបបកុម្មុយនីស្តកើតមាននូវឥទ្ធិពល មួយនៃលទ្ធិផ្តាច់ការត្រូវបានអនុវត្តទៅលើសង្គមនិងប្រជាពលរដ្ឋ[2]។

## ៣.២ ការបង្កើតរដ្ឋាភិបាលតាមរបបសេរី

ដូចម្តេចដែលហៅថារបបសេរី?

របបសេរី គឺជារបបមួយដែលគេផ្តល់សិទ្ធិសេរីភាពឲ្យដល់ប្រជាពលរដ្ឋទាំងសិទ្ធិនយោបាយ និងសិទ្ធិ ពលរដ្ឋ។ សិទ្ធិនយោបាយក្នុងរបបសេរី គឺគេផ្តល់ឲ្យប្រជាពលរដ្ឋក្នុងការបោះឆ្នោតជ្រើសរើសថ្នាក់ដឹកនាំដោយ

[2] ដកស្រង់ចេញពី សៀវភៅនីតិរដ្ឋធម្មនុញ្ញ រៀបរៀងដោយសាស្ត្រាចារ្យ សុខ ចិន្តា និង សុខ យ៉ាន ទំព័រ ១១៨ ទៅ ១១៩

គោរពទៅតាមគោលការណ៍នៃការបោះឆ្នោតដែលមានលក្ខណៈប្រជាធិបតេយ្យសេរីឈរលើគោលការណ៍សំខាន់ ៥ យ៉ាងមានដូចជាៈ

ការបោះឆ្នោតជាសកលៈ មានន័យថាពលរដ្ឋទាំងអស់មានសិទ្ធិចូលរួមក្នុងការបោះឆ្នោត។ ការបោះឆ្នោតដោយស្មើគ្នាៈ គឺសន្លឹកឆ្នោតរបស់អ្នកបោះឆ្នោតសម្លេងមានតម្លៃស្មើគ្នា ពោលគឺដោយសម្លេងស្មើគ្នាសម្លេងដូចគ្នា។ ការបោះឆ្នោតដោយផ្ទាល់ៈ មានសិទ្ធិបោះឆ្នោតជាអ្នកសម្រេចចិត្តដោយខ្លួនឯងផ្ទាល់ក្នុងការជ្រើសរើសយក បេក្ខជន ឬ ក៏បញ្ជីដែលខ្លួនពេញចិត្តដោយខ្លួនឯងមិនមានអ្នកកណ្តាលមកជំនួសឡើយ។ ការបោះឆ្នោតដោយសេរីៈ មានន័យថាអ្នកបោះឆ្នោតមានសិទ្ធិជ្រើសរើសយកបេក្ខជន ឬ បញ្ជីបក្សដែលខ្លួនពេញចិត្តដោយសេរីពុំមានការគៀបសង្កត់ ឬ ការបង្ខិតបង្ខំពីនរណាម្នាក់ឡើយ។ ការបោះឆ្នោតដោយសម្ងាត់ៈ មានន័យថា អ្នកបោះឆ្នោតត្រូវបានរក្សាការសម្ងាត់អំពីសេចក្តីសម្រេចចិត្តក្នុងការជ្រើសរើសយក បេក្ខជន ឬ ក៏បញ្ជីបក្សដែលគេពេញចិត្ត ដើម្បីចៀសវាងកុំអោយមានការភ័យខ្លាចចំពោះការជ្រើសរើសរបស់ខ្លួន[3]។

សិទ្ធិពលរដ្ឋក្នុងរបបសេរី សំដៅលើសិទ្ធិសេរីភាពក្នុងការបញ្ចេញមតិ សមភាពចំពោះមុខច្បាប់ និងមានការចូលរួមក្នុងការសម្រេចចិត្តរបស់រដ្ឋ។ របបនេះ ទៀតសោធក៏កាត់បន្ថយនូវសកម្មភាពអំណាចរដ្ឋតាមរយៈច្បាប់ និងអនុម័តការបែងចែកអំណាចជាបីដោយឯករាជ្យពីគ្នា។ ទ្រឹស្តីសេរីនិយមនេះ ជាទ្រឹស្តីរបស់ទស្សនវិទូអង់គ្លេសម្នាក់ឈ្មោះថា លោក ចន ឡុក និងទស្សនវិទូម្នាក់ទៀតជាជនជាតិបារាំង មានឈ្មោះហៅថា ឆាលល្វីម៉ុងតេស្គីយើ[4]។ នៅក្នុងរបបសេរី គេហៅថា របបសេរីពហុនិយមមានរបប ៣ ដែលមានដូចខាងក្រោមនេះៈ

អំណាចត្រូវបានបែងចែកជា ៣ នៅក្នុងរបបសេរី គឺអំណាចនីតិប្បញ្ញត្តិ អំណាចនីតិប្រតិបត្តិ និងអំណាចតុលាការ ហើយអំណាចទាំង៣មិនត្រូវបានប្រមូលផ្តុំនៅក្នុងដៃមនុស្សតែម្នាក់ឡើយ។ មុខងារនីមួយៗត្រូវប្រគល់ឲ្យអង្គការផ្សេងៗពីគ្នា អំណាចនីតិប្បញ្ញត្តិ ប្រគល់ឲ្យសភាទាំងពីរ អំណាចនីតិប្រតិបត្តិប្រគល់ឲ្យស្តេច ឬ ប្រគល់ឲ្យរដ្ឋាភិបាលអំណាចជំនុំជំរះប្រគល់ឲ្យចៅក្រម។ អំណាចចុងក្រោយនេះ មិនមែននយោបាយទេចៅក្រមជាអ្នកធ្វើឲ្យមានការអនុវត្តច្បាប់។ អំណាចទាំងបី ស្ថិតនៅក្នុងដៃបុគ្គលតែម្នាក់នោះនឹងមានការរំលោភបំពាន[5]។

[3] ដកស្រង់ចេញពី សៀវភៅ នីតិរដ្ឋធម្មនុញ្ញ រៀបរៀងដោយសាស្ត្រាចារ្យ សុខ ចិន្តា និង សុខ យ៉ាន ទំព័រ ៦៦ ទៅ ៦៧

[4] ដកស្រង់ចេញពី សៀវភៅសិក្សាសង្គម ថ្នាក់ទី១០ ឆ្នាំ២០១៧ របស់ក្រសួងអប់រំ យុវជន និងកីឡា ទំព័រទី១១៤-១១៥

[5] ដកស្រង់ចេញពី សៀវភៅនីតិរដ្ឋធម្មនុញ្ញ រៀបរៀងដោយសាស្ត្រាចារ្យ សុខ ចិន្តា និង សុខ យ៉ាន ទំព័រ ១០៩

**ក. ការបង្កើតរដ្ឋាភិបាលនៃរបបប្រធានាធិបតីនិយម**

របបប្រជាធិបតេយ្យបែបប្រធានាធិបតីនិយម គឺ នីតិប្បញ្ញត្តិ និង នីតិប្រតិបត្តិ មានឯករាជ្យរៀងៗខ្លួន ហើយទទួលខុសត្រូវចំពោះប្រជាពលរដ្ឋ។ អ្នកបោះឆ្នោតជ្រើសតាំងអង្គការនីតិប្បញ្ញត្តិដោយឡែក និងអង្គការនីតិប្រតិបត្តិដោយឡែក។ របបប្រធានាធិបតីនិយម គឺអំណាចលើប្រធានាធិបតី។ ប្រធានាធិបតីកាន់កាប់អំណាចនីតិប្រតិបត្តិពេញដៃតែម្នាក់ឯងពោលគាត់ជាប្រមុខរដ្ឋផង និងប្រមុខរដ្ឋាភិបាលផង។ លោកជាអ្នករើស និងតែងតាំងរដ្ឋមន្ត្រី ដូច្នេះ រដ្ឋមន្ត្រីទាំងអស់ទទួលខុសត្រូវចំពោះមុខប្រធានាធិបតី ដែលមានសិទ្ធិបណ្តេញចេញតាមចិត្ត។ រដ្ឋមន្ត្រីទាំងអស់មិនប្រមូលផ្តុំបង្កើតជារដ្ឋាភិបាលដែលជាអង្គការសហសេវិកតាដូចក្នុងរបបសភានិយមនោះទេ ពួកគេជាសហការីរបស់ប្រធានាធិបតី ឬជាលេខាធិការ។

រដ្ឋមន្ត្រីម្នាក់ៗទទួលបន្ទុកកិច្ចការមួយចំនួនដើម្បីអនុវត្តនយោបាយរបស់ប្រធានាធិបតី។ ប្រធានាធិបតីជាអ្នកកាន់អំណាចនីតិប្រតិបត្តិដាច់មុខ។ ប្រធានាធិបតី ដែលមានអំណាចខ្លាំងយ៉ាងនេះចាំបាច់ត្រូវមានកម្លាំងរាស្ត្រគាំទ្រភាគច្រើនលើសលប់ដោយផ្ទាល់។ ហេតុដូច្នេះ ហើយបានជានៅក្នុងរបបប្រធានាធិបតីនិយមធម្មតាប្រធានាធិបតីត្រូវបានជ្រើសតាំងដោយការបោះឆ្នោតជាសកល ដោយផ្ទាល់ ឬ ពាក់កណ្តាលផ្ទាល់។

ប្រធានាធិបតី ដូចសភាដែរ គាត់តំណាងប្រជាជាតិ។ អនុប្រធានាធិបតី ត្រូវបានបោះឆ្នោតជ្រើសតាំងឡើងព្រមពេលជាមួយនឹងប្រធានាធិបតី។

ប្រធានាធិបតី គឺវាងឯករាជ្យទៅវិញទៅមករវាងអំណាចនីតិប្បញ្ញត្តិនិងអំណាចនីតិប្រតិបត្តិ។ បានន័យថា អង្គការនីតិប្រតិបត្តិដែលមានប្រធានាធិបតី និង រដ្ឋមន្ត្រីរបស់គាត់កាន់អំណាចនីតិប្រតិបត្តិពេញលេញ ឯអង្គការនីតិប្បញ្ញត្តិ គឺ រដ្ឋសភាកាន់អំណាចនីតិប្បញ្ញត្តិពេញលេញ។ ប្រធានាធិបតីមិនអាចជ្រើសរើសរដ្ឋមន្ត្រីនៅក្នុងចំណោមសមាជិកសភាទេ។ ប្រធានាធិបតីមិនអាចលើកឡើងនូវសេចក្តីព្រាងច្បាប់ដាក់ឲ្យសភាអនុម័តទេ។ ប្រធានាធិបតី មិនអាចចូលរួមទៅក្នុង មុខងារនីតិប្បញ្ញត្តិសភាមិនអាចជ្រៀតចូលទៅក្នុងដំណើរការរបស់នីតិប្រតិបត្តិ។ អង្គការមួយគ្មានអំណាចនឹងអនុវត្តការគៀបសង្កត់ទៅលើអង្គការមួយទៀត ប្រធានាធិបតីគ្មានអំណាចប្រកាសរំលាយសភាហើយសភាក៏មិនអាចទំលាក់ប្រធានាធិបតី។ នៅពេលដែលជាប់ឆ្នោតអង្គការនីមួយៗស្ថិតនៅរហូតដល់ចប់អាណត្តិ។ ប្រធានាធិបតីគ្មានសិទ្ធិផ្តួចផ្តើមធ្វើច្បាប់ ដូច្នេះវាមានការលំបាកនឹងធ្វើឲ្យបានសម្រេចនូវកម្មវិធីនយោបាយរបស់ខ្លួន។ ប្រសិនបើ សភាភាគច្រើនមិនមែនមានគំនិតនយោបាយដូចប្រធានាធិបតីនោះប្រាកដជាស្ទះដំណើរការជាមិនខានដែលជាហេតុនាំឲ្យមានវិបត្តិនយោបាយចេញមិនរួចព្រោះ

អង្គការនីមួយៗត្រូវស្ថិតនៅរហូតដល់ចប់អាណត្តិប្រធានាធិបតី និងសភាត្រូវបានបង្ខំឲ្យរស់នៅជាមួយគ្នាទោះបីមិនត្រូវគ្នាក៏ដោយ[6]។

**ខ. ការបង្កើតរដ្ឋាភិបាលនៃរបបសភានិយម**

ក្នុងរបបប្រជាធិបតេយ្យបែបសភានិយម ការបង្កើតរដ្ឋាភិបាល គឺ សំដៅទៅដល់ការជ្រើសរើសសមាជិកសភា និងបង្កើតសភា បន្ទាប់មកសមាជិកសភាត្រូវជ្រើសរើសឥស្សរជនណាម្នាក់នៃគណបក្សដែលទទួលបានសម្លេងភាគច្រើនតាមច្បាប់កំណត់ ឲ្យដឹកនាំអង្គនីតិប្រតិបត្តិដែលហៅថា រដ្ឋាភិបាល។ អ្នកដឹកនាំនោះហៅថា នាយករដ្ឋមន្ត្រី ដែលត្រូវបោះឆ្នោតផ្ដល់សេចក្ដីទុកចិត្តពីមតិភាគច្រើនក្នុងសភា។ របបសភានិយម គឺជារបបមួយដែលឈរលើគោលការណ៍បែងចែកអំណាចទន់ភ្លន់បានន័យថា អំណាចនីតិប្បញ្ញត្តិ នឹងនីតិប្រតិបត្តិមានការសហការគ្នានិងគៀបសង្កត់គ្នាទៅវិញទៅមក។ របបសភានិយមមានច្រើនមិនមែនមានតែមួយនោះទេ ពីព្រោះវាត្រូវកសាងឡើងតាមលក្ខណៈប្រទេសនីមួយៗ។ ប៉ុន្តែជារួមវាមានយន្តការរបៀបដូចគ្នា។ របបសភានិយម ជារបបដែលនៅក្នុងនោះរដ្ឋាភិបាលត្រូវមានសេចក្ដីទុកចិត្តជានិច្ចពីសមាជិកភាគច្រើននៃសភា។ នៅក្នុងរបបសភានិយមមានការឲ្យដាច់ពីគ្នានូវមុខងាររបស់ប្រមុខរដ្ឋនិងមុខងាររបស់រដ្ឋាភិបាល។ ប្រមុខរដ្ឋ មិនទទួលខុសត្រូវនយោបាយទេ។ សភាមិនអាចទម្លាក់ប្រមុខរដ្ឋបានទេ។ សភាអាចទម្លាក់បានតែរដ្ឋមន្ត្រីទាំងឡាយ។ស្ថេរភាពរបស់ប្រមុខរដ្ឋមានរយៈពេលបើប្រមុខរដ្ឋជាស្ដេចនោះនៅសោយរាជ្យ និងធ្វើប្រមុខរដ្ឋអស់មួយជីវិតបើប្រមុខរដ្ឋជាប្រធានាធិបតីដែលបោះឆ្នោតដោយសភា នោះមានរយៈពេលអាណត្តិជាកំណត់។ ប្រមុខរដ្ឋាភិបាល រដ្ឋមន្ត្រីទាំងឡាយដឹកនាំដោយប្រមុខរដ្ឋាភិបាលហៅថានាយករដ្ឋមន្ត្រីដែលត្រូវបានតែងតាំងដោយប្រមុខរដ្ឋ។ មន្ត្រីទាំងឡាយក៏តែងតាំងដោយប្រមុខរដ្ឋ។ សមាជិករដ្ឋាភិបាលត្រូវបានយកចេញពីសមាជិកសភាហើយត្រូវសភាបោះឆ្នោតយល់ព្រម។

រដ្ឋាភិបាលត្រូវមានការគាំទ្រដោយភាគច្រើននៅក្នុងសភាដើម្បីចូលកាន់តំណែងពីព្រោះរដ្ឋាភិបាលត្រូវទទួលខុសត្រូវនយោបាយចំពោះមុខសភា។ ការទទួលខុសត្រូវខាងនយោបាយ គឺជាកាតព្វកិច្ចរបស់អ្នកទទួលអាណត្តិនយោបាយដែលត្រូវតែទទួលខុសត្រូវអំពីការអនុវត្តអាណត្តិនេះ ចំពោះអ្នកដែលប្រគល់អាណត្តិឲ្យមកខ្លួន។ រដ្ឋាភិបាលចេញមកពីការបោះឆ្នោតទុកចិត្តរបស់សភា ដូច្នេះ រដ្ឋាភិបាលត្រូវទទួលខុសត្រូវនយោបាយចំពោះមុខសភា។ ការទទួលខុសត្រូវនយោបាយរដ្ឋាភិបាលអាចមាន ២ គឺៈ

- តាមការផ្ដួចផ្ដើមរបស់រដ្ឋាភិបាល (សុំសេចក្ដីទុកចិត្ត) ឬ

[6] ដកស្រង់ចេញពី សៀវភៅ នីតិរដ្ឋធម្មនុញ្ញ រៀបរៀងដោយសាស្ត្រាចារ្យ សុខ ចិន្តា និង សុខ យ៉ាន ទំព័រ ១១៦-១១៧

- តាមការផ្តួចផ្តើមរបស់សភា (ញត្តិបន្ទោស)។

តាមការផ្តួចផ្តើមរបស់រដ្ឋាភិបាល ៖ រដ្ឋាភិបាលខ្លួនឯងស្នើសុំឲ្យសភាបោះឆ្នោតទុកចិត្ត ឬ មិនទុកចិត្តលើនយោបាយរបស់ខ្លួន ឬ លើអត្ថបទនៃសេចក្តីព្រាងច្បាប់សំខាន់របស់ខ្លួន។

តាមការផ្តួចផ្តើមរបស់សភា គឺជាមធ្យោបាយសកម្មភាពរបស់សភាទៅលើរដ្ឋាភិបាល។ សមាជិកសភាបានលើកឡើងនូវញត្តិបន្ទោសទៅលើសមាជិករដ្ឋាភិបាល ឬ រដ្ឋាភិបាលទាំងមូលដាក់ឲ្យសភាអនុម័ត បើសភាគាំទ្រញត្តិបន្ទោសនោះរដ្ឋាភិបាលត្រូវលាលែងពីតំណែង។ សភាអាចបង្ខំឲ្យរដ្ឋាភិបាលលាលែង ពីតំណែងដោយសារគេលែងយល់ព្រមទៅលើនយោបាយរបស់រដ្ឋាភិបាល។

របបសភានិយម ជាចាំបាច់ត្រូវតែមានសមាជិកសភាភាគច្រើនគាំទ្ររដ្ឋាភិបាលហើយបើគ្មានយ៉ាងនេះពេលរដ្ឋាភិបាលអាចសម្រេចសុំរំលាយរដ្ឋសភា។ ប្រមុខរដ្ឋជាអ្នកប្រកាសរំលាយ។ ពេលបានសភាថ្មី មកសភារើសប្រមុខរដ្ឋាភិបាលថ្មី ក្នុងចំណោមគណបក្សដែលមានតំណាងច្រើនជាងគេនៅក្នុងសភា។ ការរំលាយសភាគឺ រំលាយតែសភាណាដែលកើតចេញមកពីការបោះឆ្នោតសកលតែប៉ុណ្ណោះ។

ចំណែកព្រឹទ្ធសភាដែលមិនមែនកើតចេញមកពីការបោះឆ្នោតសកលគេមិនត្រូវរំលាយទេ។ រីឯសភាដែលមានសិទ្ធិរំលាយរដ្ឋាភិបាលក៏ជាសភាដែលកើតចេញពីការបោះឆ្នោតជាសកលដែរ។ សភាចូលរួមក្នុងមុខងារនីតិប្រតិបត្តិដោយត្រួតពិនិត្យសកម្មភាពរបស់រដ្ឋាភិបាល និង ក្នុងករណីដែលសភាមិនពេញចិត្តសភាអាចទម្លាក់រដ្ឋាភិបាល។

របបសភានិយម ជារបបដែលអនុវត្តការបែងចែកអំណាចទន់ភ្លន់ព្រោះ អង្គការទាំងពីរ (នីតិប្បញ្ញត្តិ និងនីតិប្រតិបត្តិ) ចូលរួមក្នុងមុខងារគ្នាទៅវិញទៅមកនិងអាចទម្លាក់គ្នាទៅវិញទៅមក។

ម្យ៉ាងទៀតរបបសភានិយមមានពីរបែបគឺរបបសភានិយមបែបទ្វិកនិយមនិងរបបសភានិយមបែបឯកនិយមឬរបបសភានិយមពិតប្រាកដ។

របបសភានិយមទ្វិកនិយម រដ្ឋាភិបាលទទួលខុសត្រូវនយោបាយ មិនត្រឹមតែចំពោះមុខសភាទេ គឺចំពោះមុខប្រមុខរដ្ឋផងដែរ ដែលប្រមុខរដ្ឋក៏ជាអ្នកចូលរួមយ៉ាងសកម្មក្នុងការកាន់អំណាច។

របបសភានិយមបែបឯកនិយមឬរបបសភានិយមពិតប្រាកដ គឺជារបបសភានិយម ដែលរដ្ឋាភិបាលទទួលខុសត្រូវចំពោះមុខរដ្ឋសភា គឺសភាដែលចេញមកពីការបោះឆ្នោតជាសកលនិងដោយផ្ទាល់[7]។

---

[7] ដកស្រង់ចេញពី សៀវភៅនីតិរដ្ឋធម្មនុញ្ញ រៀបរៀងដោយសាស្ត្រាចារ្យ សុខ ចិន្តា និង សុខ យ៉ាន ទំព័រ ១១២, ១១៣,១១៤,១១៥

**គ. ការបង្កើតរដ្ឋាភិបាលនៃរបបចម្រុះ**

ក្នុងរបបប្រជាធិបតេយ្យចម្រុះ គឺជាការបញ្ចូលគ្នានូវរបបប្រជាធិបតេយ្យទាំងពីរ របបសភានិយម និង របបប្រធានាធិបតីនិយម ដែលអ្នកបោះឆ្នោត ជ្រើសតាំងតំណាងអង្គនីតិប្បញ្ញត្តិផង និង ប្រធានាធិបតីផង ហើយសភាបោះឆ្នោតផ្តល់សេចក្តីទុកចិត្តជ្រើសតាំងនាយករដ្ឋមន្ត្រី។

របបចម្រុះ យកវិធានខ្លះពីរបបសភានិយម និង ខ្លះពីរបបប្រធានាធិបតីនិយមយកមកប្រើលាយឡំគ្នា។ ពីរបបសភានិយម របបចម្រុះដកស្រង់យកវិធានដែលឲ្យមានរដ្ឋាភិបាលមួយជាអង្គការសហសេវិកតាសាមគ្គីគ្នា ហើយទទួលខុសត្រូវចំពោះមុខសភាដែលជ្រើសតាំងឡើងតាមវិធីបោះឆ្នោតជាសកល និងដោយផ្ទាល់។ រីឯ ពីរបបប្រធានាធិបតីនិយម របបចម្រុះដកស្រង់យកវិធានដែលឲ្យមានប្រធានាធិបតីដែលមានអំណាចខ្លាំងហើយ ដែលជ្រើសតាំងឡើងតាមវិធីបោះឆ្នោតជាសកល និងដោយផ្ទាល់។

នៅក្នុងរបបចម្រុះ គេត្រូវមានហត្ថលេខាអមរបស់ប្រមុខរដ្ឋនិងរបស់ប្រមុខរដ្ឋាភិបាលដែលបានបញ្ជាក់ ថាខ្លួនជាអ្នកទទួលខុសត្រូវ។ រីឯហត្ថលេខារបស់ប្រមុខរដ្ឋគ្រាន់តែសម្រាប់បញ្ជាក់អំពីលក្ខណៈផ្លូវការពិតប្រាកដ នៃសេចក្តីសម្រេចនានារបស់រដ្ឋាភិបាលតែប៉ុណ្ណោះ។ អំណាចដែលពីមុនជារបស់ព្រះរាជាត្រូវបានផ្ទេរប្រគល់ទៅ ឲ្យប្រមុខរដ្ឋាភិបាល។ ការផ្ទេរនេះ ត្រូវបានប្រព្រឹត្តឡើងដោយការចុះហត្ថលេខាអម។

នៅក្នុងរបបសភានិយម គ្រប់លិខិតរបស់ប្រមុខរដ្ឋចាំបាច់ត្រូវចុះហត្ថលេខាអមដោយប្រមុខរដ្ឋាភិបាល ដែលជាអ្នកទទួលខុសត្រូវនៅចំពោះមុខរដ្ឋសភា ។ ហត្ថលេខា ទាំងពីនេះពុំមានន័យដូចគ្នាទេ។ ដើមកំណើត របស់វា គឺការចុះហត្ថលេខាអមមានលក្ខណៈជាការទទួលយល់ព្រមដោយរដ្ឋាភិបាលនូវសេចក្តីសម្រេចរបស់ ប្រមុខរដ្ឋ។ បច្ចុប្បន្ននេះ ហត្ថលេខារបស់ប្រមុខរដ្ឋសម្រាប់បញ្ជាក់ពីភាពត្រឹមត្រូវតាមច្បាប់ (ជាផ្លូវការ) នូវសេចក្តីសម្រេចរបស់រដ្ឋាភិបាល[៨]។

[៨] ដកស្រង់ចេញពី សៀវភៅនីតិរដ្ឋធម្មនុញ្ញ រៀបរៀងដោយសាស្ត្រាចារ្យ សុខ ចិន្តា និង សុខ យ៉ាន ទំព័រ ១១៧-១១៨

# ជំពូកទី២
# នីតិវិធីបង្កើតរាជរដ្ឋាភិបាល
# កម្ពុជាឆ្នាំ ១៩៩៣ ដល់បច្ចុប្បន្ន

# ជំពូកទី២

# នីតិវិធីបង្កើតរាជរដ្ឋាភិបាលកម្ពុជាឆ្នាំ ១៩៩៣ ដល់បច្ចុប្បន្ន

## ១. សាវតាស្ថាប័ននីតិប្រតិបត្តិនៃប្រទេសកម្ពុជាឆ្នាំ ១៩៤៧ ដល់ ១៩៩៣

ស្ថាប័ននីតិប្រតិបត្តិ គឺរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ដែលមានតួនាទីអនុវត្តច្បាប់ទាំងឡាយណាដែលរដ្ឋសភាបានអនុម័តរួចនិងព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់ហើយ[9]។

មុននិងឈានចូលដល់ប្រធានបទស្តីពីការវិវត្តន៍រាជរដ្ឋាភិបាលកម្ពុជាឆ្នាំ១៩៩៣ ដល់ បច្ចុប្បន្ននេះគឺប្រទេសកម្ពុជាធ្លាប់ឆ្លងកាត់នៅការវិវត្តន៍ផ្លាស់ប្តូរជាច្រើនដំណាក់កាលរួចមកហើយចាប់តាំងពីឆ្នាំ ១៩៤៧ មានដូចខាងក្រោមៈ

**-រាជរដ្ឋាភិបាលឆ្នាំ** (**១៩៤៧-១៩៧០**)

រាជរដ្ឋាភិបាលព្រះរាជាណាចក្រកម្ពុជាទីមួយបង្កើតឡើងតាំងពីឆ្នាំ១៩៤៧ ដល់ឆ្នាំ១៩៧០គឺបានបញ្ចប់នៅពេលដែលពួក លន់ នល់ ធ្វើរដ្ឋប្រហារទម្លាក់ សម្តេច សីហនុ នាថ្ងៃទី ១៨ ខែ មីនា ឆ្នាំ ១៩៧០។

- សភាមានចំនួន ៦ អាណត្តិ។
- រដ្ឋាភិបាលចាប់ពីថ្ងៃទី ១២ ខែ មីនា ឆ្នាំ ១៩៤៥ ដល់ថ្ងៃទី ១៨ ខែ មីនា ឆ្នាំ ១៩៧០ គឺ រយៈពេល ២៥ ឆ្នាំមានរដ្ឋាភិបាលចំនួន ៥០។
- រដ្ឋធម្មនុញ្ញឆ្នាំ ១៩៤៧ បានកំណត់ចំនួនសមាជិករដ្ឋាភិបាលមានយ៉ាងច្រើនបំផុតត្រឹម ១៦ រូប។ រដ្ឋសភាជាអ្នកផ្តល់សេចក្តីទុកចិត្ត បង្កើតរដ្ឋាភិបាលដោយវិធីបោះឆ្នោតជាចំហតាមមតិភាគច្រើនដាច់ខាត (៥០%+១) នៃចំនួនសមាជិករដ្ឋសភាទាំងមូល[10]។

**-រដ្ឋាភិបាលសាធារណរដ្ឋខ្មែរ** (**១៩៧០-១៩៧៥**)

ប្រធានាធិបតីនៃសាធារណរដ្ឋប្រើប្រាស់អំណាចនីតិប្រតិបត្តិដែលប្រជាពលរដ្ឋបោះឆ្នោតឲ្យ។ ប្រធានាធិតី គឺជាអ្នកដឹកនាំអង្គការនីតិប្រតិបត្តិ។ ប្រធានាធិបតី គឺមានអនុប្រធានាធិបតី ១ រូប ជាជំនួយការ។ ប្រធានាធិបតី និង អនុប្រធានាធិបតីត្រូវបានប្រជាពលរដ្ឋបោះឆ្នោតឲ្យផ្ទាល់ជាសកលនិងជាសម្ងាត់ក្នុងបញ្ជីឈ្មោះតែមួយ។

ប្រធានាធិបតី មានអាណត្តិ ៥ឆ្នាំ និងអាចឈរឈ្មោះបោះឆ្នោតជាថ្មីបានតែម្តងគត់។ ប្រធានាធិបតីតែងតាំងរដ្ឋមន្ត្រីទី១ (នាយករដ្ឋមន្ត្រី) និងសមាជិកដទៃទៀតនៃរដ្ឋាភិបាល។

[9] ដកស្រង់ចេញពី សៀវភៅសេចក្តីផ្តើម នីតិរដ្ឋធម្មនុញ្ញ រៀបរៀងនិងចងក្រងដោយ បណ្ឌិត ឈុន ណារ៉េត ទំព័រ ២០៩

[10] ដកស្រង់ចេញពី សៀវភៅ សេចក្តីផ្តើម នីតិរដ្ឋធម្មនុញ្ញ រៀបរៀង និង ចងក្រងដោយ បណ្ឌិត ឈុន ណារ៉េត ទំព័រ ២០៩

រដ្ឋាភិបាលសាធារណៈរដ្ឋសភាបានចប់អាណត្តិនៅពេលពួកខ្មែរក្រហមផ្តួលរំលំដោយចុងការណុងនៅថ្ងៃទី១៧ មេសា ឆ្នាំ ១៩៧៥[11]។

**-រដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ** (**១៩៧៥-១៩៧៩**)

រាជរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ ត្រូវជ្រើសតាំងឡើងដោយសភាតំណាងប្រជាជនកម្ពុជាហើយទទួលខុសត្រូវទាំងស្រុងចំពោះសភាពប្រជាជនកម្ពុជាក្នុង កិច្ចដំណើរការងាររបស់ខ្លួនទាំងក្នុងនិងក្រៅប្រទេស។ រដ្ឋាភិបាលត្រូវដឹកនាំដោយនាយករដ្ឋមន្ត្រីមួយរូបគឺ ប៉ុល ពត។ កម្ពុជាប្រជាធិបតេយ្យ ក៏មានគណៈប្រធានរដ្ឋមួយរូបដែលសព្វថ្ងៃហៅថា ប្រមុខរដ្ឋនិងអនុប្រធានពីររូបផងដែរ។ គណៈប្រធានរដ្ឋ ត្រូវជ្រើសតាំងដោយសភាតំណាងប្រជាជនសម្រាប់រយៈពេល ៥ ឆ្នាំ។ លោក ខៀវ សំផន ជាគណៈប្រធានរដ្ឋ ឬ ជាប្រមុខរដ្ឋនៃរបបកម្ពុជាប្រជាធិបតេយ្យ[12]។

**-រដ្ឋាភិបាលសាធារណៈរដ្ឋប្រជាមានិតកម្ពុជា** (**១៩៧៩-១៩៨៩**)

តាមរដ្ឋធម្មនុញ្ញឆ្នាំ ១៩៨១ បានចែងថាក្រុមប្រឹក្សារដ្ឋមន្ត្រីជារដ្ឋាភិបាល នៃរបបសាធារណៈរដ្ឋប្រជាមានិតកម្ពុជា ជាអង្គការគ្រប់គ្រងសង្គមដោយផ្ទាល់ និងដឹកនាំពង្រីកសេដ្ឋកិច្ចជាតិដោយផ្ទាល់។ ក្រុមប្រឹក្សារដ្ឋមន្ត្រីមានអាណត្តិ ៥ ឆ្នាំ ស្មើនិងអាណត្តិរដ្ឋសភាហើយត្រូវបង្កើតឡើងដោយរដ្ឋសភា។

សាធារណៈរដ្ឋប្រជាមានិតកម្ពុជាមានក្រុមប្រឹក្សារដ្ឋមួយផងដែរ។ ដែលមានក្រុមប្រឹក្សារដ្ឋជា អង្គការតំណាងសាធារណៈរដ្ឋប្រជាមានិតកម្ពុជានិងជាអង្គការអចិន្ត្រៃយ៍របស់រដ្ឋសភា។ ក្រុមប្រឹក្សារដ្ឋ មានប្រធាន អនុប្រធាន អគ្គលេខាធិការ និងសមាជិកមួយចំនួនទៀតដែលកំណត់ដោយសភា។ នៅថ្ងៃទី៣០ ខែមេសា ឆ្នាំ ១៩៨៩ រដ្ឋសភានៃសាធារណៈរដ្ឋប្រជាមានិតកម្ពុជាបាន ធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញនេះដោយកែឈ្មោះប្រទេសកម្ពុជា ពីសាធារណៈរដ្ឋប្រជាមានិតកម្ពុជាមកជា ***“ រដ្ឋកម្ពុជា ”*** នៅក្នុងមាត្រា៤ នៃរដ្ឋធម្មនុញ្ញ។

ដូច្នេះ ហើយបានជារបបប្រជាមានិតកម្ពុជាមានឈ្មោះមួយទៀតថារដ្ឋាភិបាលកម្ពុជាតែរបបនេះនៅតែមានអ្នកគ្រប់គ្រង និងអាសនៈសភានៅដដែល[13]។

**-រដ្ឋាភិបាលរដ្ឋកម្ពុជា** (**១៩៨៩-១៩៩៣**)

រចនាសម្ព័ន្ធរដ្ឋាភិបាលនៃរដ្ឋកម្ពុជា គឺដូចគ្នាទៅនិងរដ្ឋាភិបាលនៃសាធារណៈរដ្ឋប្រជាមានិតកម្ពុជា[14]។

[11] ដកស្រង់ចេញពី សៀវភៅ សេចក្តីផ្តើម នីតិរដ្ឋធម្មនុញ្ញ រៀបរៀង និងចងក្រងដោយ បណ្ឌិត ឈុន ណារ៉េត ទំព័រ ២១០

[12] ដកស្រង់ចេញពី សៀវភៅ សេចក្តីផ្តើម នីតិរដ្ឋធម្មនុញ្ញ រៀបរៀង និងចងក្រងដោយ បណ្ឌិត ឈុន ណារ៉េត ទំព័រ ២១០-២១១

[13] ដកស្រង់ចេញពី សៀវភៅ សេចក្តីផ្តើម នីតិរដ្ឋធម្មនុញ្ញ រៀបរៀង និងចងក្រងដោយ បណ្ឌិត ឈុន ណារ៉េត ទំព័រ ២១១-២១២

[14] ដកស្រង់ចេញពី សៀវភៅ សេចក្តីផ្តើម នីតិរដ្ឋធម្មនុញ្ញ រៀបរៀង និងចងក្រងដោយ បណ្ឌិត ឈុន ណារ៉េត ទំព័រ ២១២

## ផ្នែកទី១. ការបង្កើតរាជរដ្ឋាភិបាលតាមអាណត្តិសភានីមួយៗ (១៩៩៣ ដល់បច្ចុប្បន្ន)

### ១.១ ការបង្កើតរាជរដ្ឋាភិបាលតាមអាណត្តិសភា ១៩៩៣-១៩៩៨

តាមកិច្ចព្រមព្រៀងក្រុងប៉ារីស ស្តីពីដំណោះស្រាយនយោបាយរួមមួយនៃកម្ពុជា ថ្ងៃទី ២៣ ខែ តុលា ឆ្នាំ ១៩៩១ បានកំណត់ឲ្យមានការបោះឆ្នោតដើម្បីកសាងនីតិរដ្ឋ និងបង្កើតស្ថាប័នគ្រប់គ្រងប្រទេស។ ក្នុងស្មារតីនេះ ការបោះឆ្នោតលើកទី១ បានប្រព្រឹត្តទៅនៅថ្ងៃទី ២៣ ខែ ឧសភា ឆ្នាំ ១៩៩៣ នៅទូទាំងប្រទេសជ្រើសរើសសភាធម្មនុញ្ញ ដើម្បីតាក់តែង និងអនុម័តរដ្ឋធម្មនុញ្ញមួយ។ គណបក្សនយោបាយចំនួន ១៩ បានឈរឈ្មោះបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ប្រជែងយកអាសនៈចំនួន ១២០ ក្នុង ២១ មណ្ឌល។

នៅក្នុងរដ្ឋសភានីតិកាលទី១ មានតំណាងរាស្ត្រមកពីគណបក្សចំនួន ៤ មានដូចខាងក្រោម៖

- គណបក្សហ្វ៊ុនស៊ិនប៉ិច មានចំនួន ៥៨ អាសនៈ
- គណបក្សប្រជាជនកម្ពុជា មានចំនួន ៥១ អាសនៈ
- គណបក្សប្រជាធិបតេយ្យសេរីនិយមព្រះពុទ្ធសាសនា មានចំនួន ១០ អាសនៈ
- គណបក្សម៉ូលីណាការ មានចំនួន ១ អាសនៈ[15]។

#### ក. ការបង្កើតសភាធម្មនុញ្ញ១៩៩៣

សមាជិកសភាធម្មនុញ្ញចំនួន ១២០ រូប ដែលប្រជារាស្ត្រប្រមាណ ៩០% ស្មើនឹង បួនលាននាក់ នៃអ្នកចុះឈ្មោះបោះឆ្នោត បានសម្រេចជ្រើសរើសឡើងតាមការបោះឆ្នោតកាលពីខែ ឧសភា ឆ្នាំ ១៩៩៣ ដែលរៀបចំឡើងដោយអង្គការសហប្រជាជាតិ បានបើកឆាកបង្ហាញជាផ្លូវការនូវសេចក្តីព្រៀងរដ្ឋធម្មនុញ្ញថ្មីមួយដែលមាន ១៤ជំពូកនិង១៤០មាត្រារបស់កម្ពុជា។ជាសេចក្តីព្រៀងរដ្ឋធម្មនុញ្ញជាប្រវត្តិសាស្ត្ររបស់កម្ពុជាដែលប្រកបដោយលក្ខណៈប្រជាធិបតេយ្យសេរីនិយមពហុបក្ស របបសេដ្ឋកិច្ច ទីផ្សារសេរី ព្រមទាំងប្រកបដោយសិទ្ធិសេរីភាពសម្រាប់ប្រជាពលរដ្ឋខ្មែរគ្រប់រូប ដូចដែលបានចែងទុកក្នុងសេចក្តីប្រកាសសាកលស្តីអំពីសិទ្ធិមនុស្សចែងទុកក្នុងធម្មនុញ្ញអង្គការសហប្រជាជាតិ ព្រមទាំងចែងទុកក្នុងអនុសញ្ញាអន្តរជាតិផ្សេងៗ ស្តីពីសិទ្ធិបុរស ស្ត្រី និង កុមារ។

សម័យប្រជុំពេញអង្គលើកទី២ នៃសភាធម្មនុញ្ញថ្ងៃទី ២១ ខែ កញ្ញា ឆ្នាំ ១៩៩៣ បានប្រព្រឹត្តទៅនៅក្រោមអធិបតីភាពរបស់លោក សឺន សាន ប្រធានសភាធម្មនុញ្ញ លោក ជា ស៊ីម និង លោក អ៊ឹង គាត អនុប្រធានទី១ និងអនុប្រធានទី២។ អង្គប្រជុំបានចាប់ឆ្នោតជ្រើសតាំងគណៈកម្មការរៀបចំការបោះឆ្នោតចំនួន ៣ រូប ដើម្បីបោះឆ្នោតអនុម័តលើរដ្ឋធម្មនុញ្ញទាំងស្រុង។ ការបោះឆ្នោតអនុម័តរដ្ឋធម្មនុញ្ញនេះ បានប្រព្រឹត្តទៅដោយសម្ងាត់ និងដោយសេរី។ ភាពប៉ិនប្រសប់ និងភាពជាក់ស្តែងនិយមរបស់សមាជិកសភាធម្មនុញ្ញក្នុងឆ្នាំ ១៩៩៣ ដែល

[15] ដកស្រង់ចេញពី ប្រវត្តិសភាកម្ពុជា ចាប់តាំងពីឆ្នាំ ១៩៩១ រហូតដល់បច្ចុប្បន្ន

បានឆ្លៀតឱកាលនៃភាពខ្វះខាត និងចន្លោះប្រហោងនៃបេសកកម្មរបស់ ( UNTAC) ដើម្បីចាប់បង្ខំឲ្យយកជម្រើសខ្មែរ។ ខណៈដែលកិច្ចព្រមព្រៀងក្រុងប៉ារីសគ្មានចែងពីរបបនយោបាយក្នុងអំឡុងពេល ក្រោយការបោះឆ្នោតនៅខែ ឧសភា ឆ្នាំ១៩៩៣ រហូតដល់ពេលអនុម័តសភាធម្មនុញ្ញអ្នកនយោបាយខ្មែរបានសម្រេចចិត្តបង្កើតរបបរាជានិយមអាស្រ័យរដ្ឋធម្មនុញ្ញ។ នៅចុងបញ្ចប់នៃការបោះឆ្នោតសកលឆ្នាំ ១៩៩៣ ដោយសារប្រព័ន្ធបោះឆ្នោតសមាមាត្រដែលកំណត់ដោយកិច្ចព្រមព្រៀងទីក្រុងប៉ារីស គ្មានគណបក្សនយោបាយណាមួយដែលមានសម្លេងភាគច្រើនពីរភាគបី (២/៣) ចាំបាច់សម្រាប់ការអនុម័តរដ្ឋធម្មនុញ្ញទ្បើយ។

វិបត្តិក្រោយការបោះឆ្នោត បង្កឲ្យមានការគំរាមកំហែងនៃសង្គ្រាមស៊ីវិលថ្មី។ ទោះបីជាមានការប្រឆាំងយ៉ាងខ្លាំងពីសហរដ្ឋអាមេរិកនិងអរិកភាពយ៉ាងខ្លាំងពីអ៊ុនតាក់ក៏ដោយសម្តេចព្រះ នរោត្តម សីហនុ ប្រធានក្រុមប្រឹក្សាជាតិជាន់ខ្ពស់ (SNC) សម្រេចបានដោយជោគជ័យក្នុងការដាក់ចេញនូវគំនិតផ្តួចផ្តើមបង្កើតរដ្ឋាភិបាលចម្រុះបណ្តោះអាសន្នដើម្បីដោះស្រាយវិបត្តិនេះ ដែលបានស្នើឡើងដោយគណបក្សប្រជាជនកម្ពុជា។ ជោគជ័យនេះ ស្តែងចេញតាមរយៈការបោះឆ្នោតជាឯកច្ឆ័ន្ទរបស់សភាធម្មនុញ្ញនៅថ្ងៃទី១៤ ខែមិថុនា ឆ្នាំ១៩៩៣ មួយថ្ងៃមុនការទទួលស្គាល់ជាផ្លូវការលទ្ធផលនៃការបោះឆ្នោតដោយអ៊ុន តាក់ នូវសេចក្តីសម្រេចមួយដែលបានលុបចោលការបោះឆ្នោតនៅថ្ងៃទី ១៨ ខែ មីនា ឆ្នាំ ១៩៧០ ទម្លាក់សម្តេចព្រះ នរោត្តម សីហនុ និងប្រគល់ថ្វាយព្រះអង្គវិញនូវបុព្វសិទ្ធិជាប្រមុខ។

**ខ. ដំណើរការសភាធម្មនុញ្ញ១៩៩៣**

ចាប់តាំងពីពេលនេះ មកសភាធម្មនុញ្ញចាប់ផ្តើមដំណើរការរបស់ខ្លួនដោយការរៀបចំតាក់តែងសេចក្តីព្រាងរដ្ឋធម្មនុញ្ញនិងអនុម័តសេចក្តីព្រាងរដ្ឋធម្មនុញ្ញនេះ។ សភាធម្មនុញ្ញ បានដំណើរការយ៉ាងសកម្មរហូតដល់ថ្ងៃទី ២១ ខែកញ្ញា ឆ្នាំ១៩៩៣ បានអនុម័តរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាដោយទទួលបានសម្លេង ៩៧% គាំទ្រ ហើយត្រូវបានព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជាឡាយព្រះហត្ថលេខាប្រកាសឲ្យប្រើនៅថ្ងៃទី ២៤ ខែកញ្ញា ឆ្នាំ១៩៩៣ ដោយអនុវត្តតាមរបបរាជានិយមអាស្រ័យរដ្ឋធម្មនុញ្ញ។

សមាជិកសភាធម្មនុញ្ញទាំងអស់មានចំនួន១២០រូបដែលកើតចេញពីការបោះឆ្នោតជាសកលជាសម្ងាត់ដោយស្មើភាព ដោយផ្ទាល់ រៀបចំដោយអង្គការសហប្រជាជាតិ។ សភាធម្មនុញ្ញ មានភារកិច្ចជាដំបូង និងតែមួយគត់របស់ខ្លួន គឺព្រាង និងអនុម័តរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា។

ក្រោមការដឹកនាំរបស់សម្តេចព្រះបវរសេដ្ឋា សឺន សាន ជាប្រធានសភាធម្មនុញ្ញ ឯកឧត្តម ជា ស៊ីម ជាអនុប្រធានទី២ និង ឯកឧត្តម អ៊ឹង គៀត ជាអនុប្រធានទី២ បានធ្វើសេចក្តីព្រាងរដ្ឋធម្មនុញ្ញ ថ្មីនៃព្រះរាជាណាចក្រកម្ពុជាមួយដែលរៀបចំឡើងនៅថ្ងៃទី៣០ ខែមិថុនា ឆ្នាំ១៩៩៣។ មុននិងធ្វើសេចក្តីព្រាងរដ្ឋធម្មនុញ្ញថ្មី នោះសភាធម្មនុញ្ញក៏បានអនុម័តបទបញ្ជាផ្ទៃក្នុងនៃសភាធម្មនុញ្ញ។ បទបញ្ជាផ្ទៃក្នុងនៃសភាធម្មនុញ្ញនេះ ត្រូវចូលជាធរមាន

ចាប់ពីពេលដែលសភាធម្មនុញ្ញបាន អនុម័តយល់ព្រមហើយផងដែរ។ ក្នុងបទបញ្ជាផ្ទៃក្នុងនៃសភាធម្មនុញ្ញត្រង់ជំពូក១ ។ ប្រការ ១ បញ្ជាក់ថា បទបញ្ជានេះមានសុពលភាពតែក្នុងសភាធម្មនុញ្ញតែប៉ុណ្ណោះ[16]។

**គ. ការប្រែក្លាយពីសភាធម្មនុញ្ញទៅជាសភាជាតិឆ្នាំ១៩៩៣-១៩៩៨**

រដ្ឋធម្មនុញ្ញមួយត្រូវបានប្រកាសឲ្យប្រើនៅថ្ងៃទី ២៤ ខែកញ្ញា ឆ្នាំ១៩៩៣ បន្ទាប់មកសភាធម្មនុញ្ញ ក៏បានក្លាយទៅជារដ្ឋសភានីតិកាលទី១ សម្រាប់រយៈពេល ៥ ឆ្នាំ ( ១៩៩៣-១៩៩៨)។

ក្រោយពេលរដ្ឋធម្មនុញ្ញនេះចូលជាធរមានសភាធម្មនុញ្ញត្រូវក្លាយទៅជារដ្ឋសភា។ បទបញ្ជាផ្ទៃក្នុងរបស់រដ្ឋសភាត្រូវចូលជាធរមានក្រោយទទួលបានការអនុម័តពីរដ្ឋសភា។ ក្នុងករណីដែលរដ្ឋសភាមិនទាន់ចាប់ដំណើរការបាន ប្រធាន អនុប្រធានទីមួយ និង អនុប្រធានទីពីរ នៃសភាធម្មនុញ្ញ នឹងចូលរួមបំពេញភារកិច្ចក្នុងក្រុមប្រឹក្សារាជសម្បត្តិ បើសភាពការណ៍ ក្នុងប្រទេសទាមទារ[17]។

**ឃ. ការបង្កើតរាជរដ្ឋាភិបាល**

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា បានបង្កើតឡើងចាប់ពីឆ្នាំ ១៩៩៣ គឺ ក្រោយការបោះឆ្នោត។ នៅក្នុងរាជរដ្ឋាភិបាលអាណត្តិទីមួយពីឆ្នាំ ១៩៩៣ ដល់ ១៩៩៨ ជារាជរដ្ឋាភិបាលដែលមាននាយករដ្ឋមន្ត្រីពីរហៅថា សហនាយករដ្ឋមន្ត្រី ហើយរដ្ឋមន្ត្រីនៅតាមក្រសួងមួយចំនួនទៀតក៏មាននាយករដ្ឋមន្ត្រី២រូប ដែលគេហៅថាសហរដ្ឋមន្ត្រី។ នៅក្នុងរាជរដ្ឋាភិបាលអាណត្តិទី១គឺរាជរដ្ឋាភិបាលបង្កើតឡើងដោយការសម្រុះសម្រួលផ្នែកនយោបាយរវាងគណបក្សនយោបាយធំៗពីរ គឺ គណបក្សហ្វ៊ុនស៊ិនប៉ិច និងគណបក្សប្រជាជន ដែលកាលនោះគណបក្សហ្វ៊ុនស៊ិនប៉ិច ជាអ្នកឈ្នះឆ្នោត។ ព្រះករុណាព្រះបាទសម្តេចព្រះនរោត្តម សីហនុ ព្រះអង្គបានឈ្វេងយល់ថា ដើម្បីបញ្ចប់វិបត្តិនយោបាយនិងការបែកបាក់ជាតិជាថ្មីម្តងទៀតនោះ ព្រះអង្គបានស្នើឲ្យមានរូបមន្តរាជរដ្ឋាភិបាលក្បាលពីរដែលមាននាយករដ្ឋមន្ត្រី ២ រូប នាយករដ្ឋមន្ត្រីទី ១ គឺសម្តេចក្រុមព្រះ នរោត្តម រណឫទ្ធិ ជាប្រធានគណបក្សហ្វ៊ុនស៊ិនប៉ិច និង នាយករដ្ឋមន្ត្រីទី២ គឺសម្តេច ហ៊ុន សែន ជាអនុប្រធាន គណបក្សប្រជាជនកម្ពុជា។ ដោយសារតែរាជរដ្ឋាភិបាលអាណត្តិទីមួយ កើតឡើងដោយសារការសម្រុះសម្រួលផ្នែកនយោបាយ ការបង្កើតរាជរដ្ឋាភិបាលចម្រុះដែលមាន ៣ គណបក្សនៅពេលនោះត្រូវបែងចែកកូតាតាមគោលការណ៍ ៤៥%+ ៤៥% + ១០% គឺ គណបក្ស ហ្វ៊ុនស៊ិនប៉ិច ទទួលបានកៅអីក្នុងជួររាជរដ្ឋាភិបាល ៤៥% គណបក្សប្រជាជនកម្ពុជាទទួលកៅអីក្នុងជួររាជរដ្ឋាភិបាល ៤៥% និង គណបក្សសេរីនិយមព្រះពុទ្ធសាសនា ទទួល

[16] ដកស្រង់ចេញពី សៀវភៅ អភ័យឯកសិទ្ធិរដ្ឋសភានៅកម្ពុជា (ករណីសិក្សាប្រៀបធៀបប្រទេសជប៉ុន) ស្រាវជ្រាវដោយ និស្សិតឈ្មោះក. ធូ ធនេថ និងវ៉ៃ ដារិទ្ធិ ឆ្នាំសរសេរណា ២០១៦ ទំព័រ ៣-៤

[17] មាត្រា ១៥៧ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ ១៩៩៣

បានកៅអីក្នុងជួររាជរដ្ឋាភិបាល ១០%[18]។ នៅឆ្នាំ ១៩៩៣ រាជាធិបតេយ្យអាស្រ័យរដ្ឋធម្មនុញ្ញត្រូវបានស្តារឡើងវិញនៅប្រទេសកម្ពុជា។ នាយករដ្ឋមន្ត្រីត្រូវបានកំណត់ជាផ្លូវការនៅក្នុងរដ្ឋធម្មនុញ្ញនាឆ្នាំនោះ។

កិច្ចព្រមព្រៀងសម្ព័ន្ធភាពរវាងគណបក្សហ៊្វុនស៊ិនប៉ិច និង គណបក្សប្រជាជនកម្ពុជានៅឆ្នាំ១៩៩៣បានសម្គាល់នូវរយៈពេលខ្លីមួយដែលប្រទេសកម្ពុជាត្រូវមាននាយករដ្ឋមន្ត្រីចំនួន ២ រូប គឺ សម្តេច តេជោ ហ៊ុន សែន និង ព្រះអង្គម្ចាស់ នរោត្តម រណឫទ្ធិ។ នាយករដ្ឋមន្ត្រី គឺតម្រូវឲ្យធ្វើជាសមាជិកសភា។ ដំបូង ត្រូវជ្រើសតាំងដោយសភាសម្លេងភាគច្រើនសិន មុនពេលធ្វើពិធីស្បថឡើងកាន់អំណាច។ ពិធីឡើងកាន់តំណែងជានាយករដ្ឋមន្ត្រីត្រូវប្រព្រឹត្តធ្វើឡើងនៅឯព្រះបរមរាជវាំង។ នាយករដ្ឋមន្ត្រីដែលបានតែងតាំងត្រូវតែធ្វើសច្ចាប្រណិធាននៅមុខព្រះមហាក្សត្រ និងសម្តេចព្រះសង្ឃរាជ គណៈមហានិកាយ និងគណៈធម្មយុត្តិនិកាយ។

បន្ទាប់មក គណៈរដ្ឋមន្ត្រីនឹងត្រូវបានបង្ហាញ។ ការបង្កើតរដ្ឋាភិបាលថ្មីធ្វើឡើងមិនលើសពី ៦០ ថ្ងៃនោះទេបន្ទាប់ពីការបោះឆ្នោតហើយ ដូចដែលបានកំណត់នូវក្នុងច្បាប់រដ្ឋធម្មនុញ្ញ។ នៅក្នុងមាត្រា១២៥ នៃរដ្ឋធម្មនុញ្ញបានចែងថាបើតំណែងនាយករដ្ឋមន្ត្រីត្រូវទំនេរនោះនាយករដ្ឋមន្ត្រីស្តីទី(បណ្តោះអាសន្ន) នឹងឡើងកាន់តំណែងជំនួសបាន។ ការរំលាយរាជរដ្ឋាភិបាលតាមមាត្រា ១២៥ ថ្មី នៃរដ្ឋធម្មនុញ្ញដែលចែងថា តំណែងនាយករដ្ឋមន្ត្រីនៅទំនេរជាស្ថាបពរនេះ ដោយសារមូលហេតុជាច្រើនដូចជា៖

- ដោយនាយករដ្ឋមន្ត្រីលាឈប់
- ដោយនាយករដ្ឋមន្ត្រីស្លាប់
- ដោយនាយករដ្ឋមន្ត្រីប្រកាសចូលនិវត្តន៍
- នាយករដ្ឋមន្ត្រីត្រូវទម្លាក់ដោយរដ្ឋសភា។

យោងតាមមាត្រា១២៦ថ្មី (មាត្រា ១០៧ ចាស់) សមាជិកមួយរូបៗ នៃរាជរដ្ឋាភិបាលត្រូវទទួលទណ្ឌកម្មពីបទឧក្រិដ្ឋ ឬ បទមជ្ឈិម ដែលខ្លួនបានប្រព្រឹត្តក្នុងការបំពេញការងាររបស់ខ្លួន។ ក្នុងករណីនេះ និងក្នុងករណីធ្វើខុសជាទម្ងន់ក្នុងការបំពេញការងាររបស់ខ្លួន រដ្ឋសភាអាចសម្រេចប្តឹងទៅតុលាការមានសមត្ថកិច្ច។ រដ្ឋសភាសម្រេចក្នុងរឿងនេះ ដោយវិធីបោះឆ្នោតជាសម្ងាត់តាមមតិភាគច្រើនដាច់ខាត នៃសមាជិករដ្ឋសភាទាំងមូល។ ការរំលាយរាជរដ្ឋាភិបាលតាមមាត្រា ១២៦ ថ្មី នេះបើនាយករដ្ឋមន្ត្រីមានទោសលើបទមជ្ឈិម ឬ បទឧក្រិដ្ឋដូចជាការសម្លាប់មនុស្ស សកម្មភាពឧក្រិដ្ឋផ្សេងៗទៀត ដូចមានចែងក្នុងក្រមព្រហ្មទណ្ឌរាជរដ្ឋាភិបាលក៏បានរំលាយផង

[18] ដកស្រង់ចេញពី សៀវភៅ សេចក្តីផ្តើម នីតិរដ្ឋធម្មនុញ្ញ រៀបរៀង និង ចងក្រងដោយ បណ្ឌិត ឈុន ណារ៉េត ទំព័រ ២១២-២១៣

ដែរ។ នាយករដ្ឋមន្ត្រី ក៏អាចធ្វើខុសធ្ងន់ធ្ងរក្នុងការបំពេញការងាររបស់ខ្លួនដូចជាពុករលួយបក្សពួកនិយម ឬ គ្រួសារនិយម ឬ បានធ្វើផ្ទុយទៅនឹងរដ្ឋធម្មនុញ្ញធ្ងន់ធ្ងរ ការគឹបកេងបំបាត់ពន្ធបំបាត់ចំណូលរដ្ឋជាដើម។ យោង តាមមាត្រា ១២០ ថ្មី (មាត្រា ១០១ ចាស់) មុខងារនៃសមាជិករាជរដ្ឋាភិបាល មានវិសមិតភាព និងសកម្មភាព ខាងវិជ្ជាជីវៈផ្នែកពាណិជ្ជកម្ម ឬ ឧស្សាហកម្ម ហើយនិងការកាន់តំណែងណាមួយក្នុងមុខងារសាធារណៈ[19]។

**ខ. ក្រសួង និងស្ថាប័ននានា**

ក្រសួងមានចំនួន១៧នៅក្នុងរាជរដ្ឋាភិបាលអាណត្តិទីមួយ ដែលមានសហនាយករដ្ឋមន្ត្រី២ ដូចជា ក្រសួងការពារជាតិ ក្រសួងមហាផ្ទៃ និងទីស្តីការគណៈរដ្ឋមន្ត្រី។ គេសង្កេតឃើញថាក្រោយពេលច្បាប់ស្តីពីការ រៀបចំការប្រព្រឹត្តទៅរបស់គណៈរដ្ឋមន្ត្រីដែលរដ្ឋសភាបានអនុម័តនៅក្នុងខែ កក្កដា ឆ្នាំ១៩៩៤ គេឃើញមាន សមាសភាពសមាជិករាជរដ្ឋាភិបាលអាណត្តិទីមួយមានដូចខាងក្រោមនេះ៖

១. នាយករដ្ឋមន្ត្រី = ២ រូប

២. ឧបនាយករដ្ឋមន្ត្រី = ២ រូប

៣. ទេសរដ្ឋមន្ត្រី = ៥ រូប

៤. រដ្ឋមន្ត្រី = ១៩ រូប សម្រាប់ក្រសួងចំនួន ១៧

(ក្រសួងការពារជាតិ ក្រសួងមហាផ្ទៃ ទីស្តីការគណៈរដ្ឋមន្ត្រីមានរដ្ឋមន្ត្រី ២ រូប)

៥. រដ្ឋលេខាធិការ = ២៤ រូប។

**ផ្នែកទី២ ការបង្កើតរាជរដ្ឋាភិបាលតាមអាណត្តិសភា១៩៩៨-២០០៣**

បន្ទាប់ពីការបោះឆ្នោតនៅ ឆ្នាំ ១៩៩៨ សភាមួយថ្នាក់ទៀតត្រូវបានបង្កើតឡើង។ ស្ថាប័នព្រឹទ្ធសភា គឺ ជាផ្លែផ្កានៃការមូលមតិគ្នាខាងនយោបាយសំដៅដោះស្រាយភាពជាប់គាំងខាងនយោបាយដែលអង្គនីតិប្រតិបត្តិ មិនអាចបង្កើតបានដោយសារលក្ខខណ្ឌសម្លេងភាគច្រើនលើសលប់ ២/៣ នៅក្នុងសភា។

នីតិកាលទី២ បានប្រព្រឹត្តទៅនៅថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ១៩៩៨ ដែលមានគណបក្សនយោបាយឈរ ឈ្មោះបោះឆ្នោតចំនួន ៣៩ ប្រជែងយកអាសនៈសភាចំនួន ១២២ ក្នុង ២៣ មណ្ឌល។

គណបក្សបីបានឈ្នះអាសនៈក្នុងនោះមានដូចខាងក្រោមនេះ៖

- មានគណបក្សប្រជាជនកម្ពុជា ៦៤ អាសនៈ
- គណបក្សហ៊្វុនស៊ិនប៉ិច ៤៣ អាសនៈ និង
- គណបក្ស សម រង្ស៊ី មានចំនួន អាសនៈ ១៥។

[19] ដកស្រង់ចេញពី សៀវភៅ សេចក្តីផ្តើម នីតិរដ្ឋធម្មនុញ្ញ រៀបរៀងដោយ បណ្ឌិត ឈុន ណារ៉េត ទំព័រ ២២៨,២២៩,២៣០

**ក. ការបង្កើតរដ្ឋសភា**

រដ្ឋសភាមានសមាជិកតំណាងរាស្ត្រយ៉ាងតិច១២០រូប។ តំណាងរាស្ត្រត្រូវជ្រើសតាំងដោយការបោះឆ្នោតជាសកល ដោយសេរី ដោយស្មើភាព ដោយចំពោះ និងតាមវិធីជ្រើសរើសឆ្នោតជាសម្ងាត់។ តំណាងរាស្ត្រអាចឈរឈ្មោះបោះឆ្នោតសាជាថ្មីបាន។ អ្នកដែលមានសិទ្ធិឈរឈ្មោះជាបេក្ខជនតំណាងរាស្ត្រ គឺជាប្រជាពលរដ្ឋខ្មែរទាំងពីរភេទដែលមានសិទ្ធិបោះឆ្នោតមានអាយុយ៉ាងតិច ២៥ឆ្នាំ មានសញ្ជាតិជាខ្មែរតាំងពីកំណើត។ បែបបទនិងការប្រព្រឹត្តទៅនៃការបោះឆ្នោតត្រូវកំណត់ក្នុងច្បាប់បោះឆ្នោត។

**ខ. ដំណើរការនៃរដ្ឋសភា**

ការរៀបចំដំណើរការនៃរដ្ឋសភាយ៉ាងយូររយៈពេល៦០ ថ្ងៃ ក្រោយការបោះឆ្នោត រដ្ឋសភាត្រូវបើកសម័យប្រជុំរបស់ខ្លួនជាលើកដំបូងតាមរយៈការកោះប្រជុំពីព្រះមហាក្សត្រ។ ម្យ៉ាងទៀត ក្នុងរយៈពេល ៦០ថ្ងៃនេះក៏ជាលទ្ធផលនៃការបោះឆ្នោតជ្រើសរើសរដ្ឋសភាថ្មី ត្រូវបានប្រកាសមុនកាលកំណត់រយៈពេលឲ្យកោះប្រជុំរដ្ឋសភាថ្មីជាលើកដំបូងដែរ។ ក្នុងអំឡុងពេល ៦០ថ្ងៃ ក្រោយការបោះឆ្នោត រដ្ឋសភាថ្មីត្រូវចូលកាន់មុខតំណែងរបស់ខ្លួនជាលើកដំបូងក្រោមអធិបតីភាពនៃព្រះមហាក្សត្រ និងព្រះមហេសី។

សម័យប្រជុំលើកដំបូងនេះ ចាប់ផ្តើមដំណើរការដោយសម្រេចឲ្យបាននូវកិច្ចការ ៤ បែបដែលចែងឡើងដោយមាត្រា៨២ការសម្រេចពីសុពលភាពនៃអាណត្តិរបស់សមាជិកនីមួយៗជាអំណាចសំខាន់របស់សភា ដែលអាចមានការប៉ះទង្គិចទៅលើអំណាចដែលផ្តល់ឲ្យក្រុមប្រឹក្សាធម្មនុញ្ញក្នុងការត្រួតពិនិត្យ និង ដោះស្រាយរាល់បញ្ហាតវ៉ា ទាមទារ ទាក់ទិនទៅនិងការបោះឆ្នោត (មាត្រា ១៣៦ វាក្យខណ្ឌទី២) ។ យើងអាចមានការព្រួយបារម្ភថាបើមានលក្ខណៈផ្ទុយគ្នារវាងសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញទៅនិងសេចក្តីសម្រេចអង្គសភា ទាក់ទិននឹងសុពលភាពសមាជិកសភាណាមួយនោះ សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញអាចនឹងត្រូវចាត់ទុកដោយឡែក។ ដូច្នេះ ហើយនីតិវិធីពីរយ៉ាងទាក់ទិនទៅនិងកម្មវត្ថុមតែមួយ ដែលអាចផ្តល់នូវផលវិបាកគួរឲ្យកត់សម្គាល់។ ការធ្វើសច្ចាប្រណិធានរបស់សមាជិកសភា។ ការបោះឆ្នោតជ្រើសរើសដាច់ដោយឡែកពីគ្នា នូវប្រធាន អនុប្រធានរដ្ឋសភា និងសមាជិកទាំងអស់នៃគណៈកម្មការនានារបស់រដ្ឋសភា ដោយមតិភាគច្រើន ២/៣ នៃសមាជិករដ្ឋសភាទាំងមូល។ ការអនុម័តនូវបទបញ្ជាផ្ទៃក្នុង ដែលកំណត់អំពីការរៀបចំ និងដំណើរប្រព្រឹត្តទៅនៃរដ្ឋសភា។ រដ្ឋសភាជាអង្គការ ដែលកាន់អំណាចនីតិប្បញ្ញត្តិ ហើយបំពេញភារៈកិច្ចរបស់ខ្លួនដូចបានកំណត់ក្នុងរដ្ឋធម្មនុញ្ញនិងច្បាប់ជាធរមាន[20]។ រដ្ឋសភាមានសមាជិកយ៉ាងតិច ១២០ រូប។ តំណាងត្រូវជ្រើសតាំងដោយការបោះឆ្នោតជាសកល ដោយសេរី ដោយស្មើរភាព ដោយចំពោះ ដោយសម្ងាត់[21]។ នីតិកាលរបស់រដ្ឋសភាមាន

[20] មាត្រា៩០ ថ្មី រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ ១៩៩៣

[21] មាត្រា ៧៦ ថ្មី រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ ១៩៩៣

កំណត់ ៥ ឆ្នាំ ហើយត្រូវផុតកំណត់នៅពេលដែលរដ្ឋសភាថ្មីចូលកាន់តំណែង។ រដ្ឋសភា មិនអាចត្រូវបានរំលាយមុនផុតអាណត្តិបានឡើយវៀរលែងតែក្នុងករណីដែលរាជរដ្ឋាភិបាលត្រូវបានទម្លាក់ពីរដងក្នុងរយៈ ១២ ខែ។ ក្នុងរយៈពេលមានសង្គ្រាម ឬ ក្នុងកាលៈទេសៈពិសេសដទៃទៀតដែលមិនអាចធ្វើការបោះឆ្នោតកើតរដ្ឋសភាអាចប្រកាសបន្តនីតិកាលរបស់ខ្លួនម្តងបានមួយឆ្នាំតាមសំណើរបស់ព្រះមហាក្សត្រ។ ការប្រកាសបន្តនីតិកាលរបស់រដ្ឋសភាត្រូវសម្រេចដោយមតិយល់ព្រម ២/៣ យ៉ាងតិចនៃចំនួនសមាជិករដ្ឋសភាទាំងមូល។ រដ្ឋសភាអាចទម្លាក់គណៈរដ្ឋមន្ត្រី ឬ ទម្លាក់រាជរដ្ឋាភិបាលពីតំណែងដោយអនុម័តញ្ញត្តិបន្ទោសតាមសម្លេងឆ្នោតភាគច្រើននៃសមាជិកទាំងមូល[22]។ ក្នុងករណីនេះ សូមធ្វើការកត់សម្គាល់ថាប្រសិនបើរដ្ឋសភាធ្វើការទម្លាក់រដ្ឋាភិបាល ២ដងក្នុងរយៈពេល ១២ ខែនាយករដ្ឋមន្ត្រីអាចស្នើព្រះមហាក្សត្ររំលាយរដ្ឋសភា។ ព្រះមហាក្សត្រ ត្រូវរំលាយរដ្ឋសភាបន្ទាប់ពីទ្រង់បានការយល់ព្រមពីប្រធានរដ្ឋសភា។

ចាប់តាំងពីឆ្នាំ ១៩៩៨ មករាល់ការបោះឆ្នោតទាំងអស់ត្រូវបានមើលខុសត្រូវដោយ គ.ជ.ប។ ស្ថាប័នបោះឆ្នោតនេះ ក៏ទទួលរងការរិះគន់ជាច្រើនពីគណបក្សប្រឆាំង អង្គការឃ្លាំមើលការបោះឆ្នោត និងអង្គការអន្តរជាតិ រាប់បញ្ចូលទាំងសភាសហភាពអឺរ៉ុប និងការិយាល័យឧត្តមស្នងការ អង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សផងដែរនៅពេលថ្មីៗនេះ។ ការរិះគន់ទាំងនេះរួមមាន ស្ថាប័នរៀបចំការបោះឆ្នោតខ្វះឯករាជ្យភាពលំអៀងទៅកាន់គណបក្សកាន់អំណាចនិងរៀបចំការបោះឆ្នោតទន់ខ្សោយ មានលក្ខណៈជាប្រព័ន្ធដែលអនុគ្រោះគណបក្សកាន់អំណាច។

**គ. ការបង្កើតរាជរដ្ឋាភិបាល**

ក្រោយការបោះឆ្នោតជាតិឆ្នាំ ១៩៩៨ គណបក្សប្រជាជនកម្ពុជា និងគណបក្សហ្វ៊ុនស៊ិនប៉ិច បានឈានដល់ការព្រមព្រៀងគ្នាបង្កើតរដ្ឋាភិបាលចម្រុះរួមគ្នា ដោយសុខចិត្តធ្វើសម្បទានចែករំលែកអំណាចគ្នាទាំងនៅក្នុងអង្គនីតិប្បញ្ញត្តិ និងអង្គការនីតិប្រតិបត្តិ។ ផ្អែកតាមការព្រមព្រៀងគ្នារវាងគណបក្សទាំងពីរនេះ ព្រះមហាក្សត្រនរោត្តម សីហនុ ព្រះអង្គទ្រង់សព្វព្រះរាជហឫទ័យកោះអញ្ជើញថ្នាក់ដឹកនាំកំពូលនៃគណបក្សទាំងពីរចូលរួមប្រជុំនៅរសៀលថ្ងៃទី ១២-១៣ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ នៅក្នុងព្រះរាជវាំង។ គណបក្សប្រជាជន មានសម្តេច ជា ស៊ីម ជាប្រធានគណបក្ស សម្តេច ហ៊ុន សែន ជាអនុប្រធាន និង ឯកឧត្តម សុខ អាន ជាសមាជិកគណបក្សផងដែរ។ រីឯ ខាងគណបក្សហ្វ៊ុនស៊ិនប៉ិច មានសម្តេចក្រុមព្រះនរោត្តម រណឫទ្ធិ ជាប្រធាន ឯកឧត្តម តុល ឡោះ អគ្គលេខាធិការគណបក្ស និង ឯកឧត្តម យូ ហុកគ្រី។

[22] មាត្រា ៧៨ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ ១៩៩៣

**ឃ.ក្រសួង និងស្ថាប័ន**

រាជរដ្ឋាភិបាលកម្ពុជាអាណត្តិទី២ (១៩៩៨-២០០៣) មានព្រះមហាក្សត្រ ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ។

១. នាយករដ្ឋមន្ត្រី = ១ រូប

(ប្រមុខរាជរដ្ឋាភិបាល-នាយករដ្ឋមន្ត្រី លោក ហ៊ុន សែន)

២. ឧបនាយករដ្ឋមន្ត្រី = ២ រូប

៣. ទេសរដ្ឋមន្ត្រី = ៨ រូប

៤. រដ្ឋមន្ត្រីនៃទីស្តីការគណៈរដ្ឋមន្ត្រី = ១ រូប

៥. រដ្ឋលេខាធិការ = ៤៨ រូប

៦. អនុរដ្ឋលេខាធិការមាន = ១១៥ រូប

៧. រដ្ឋមន្ត្រី = ២៥ រូប កាន់ក្រសួង។

**ផ្នែកទី៣ ការបង្កើតរាជរដ្ឋាភិបាលតាមអាណត្តិសភា២០០៣-២០០៨**

ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៣ ប្រព្រឹត្តទៅនៅថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០០៣ ដើម្បីជ្រើសតាំងតំណាងរាស្ត្រចំនួន ១២៣ រូប។ គណបក្សនយោបាយចំនួន២៣ បានឈរឈ្មោះបោះឆ្នោត សម្រាប់មណ្ឌលចំនួន២៤ ។ មានគណបក្សចំនួន ៣ បានឈ្នះអាសនៈ។ តំណាងរាស្ត្រមានចំនួន១២៣ រូប មានសមាសភាពមកពីគណបក្សមានដូចជា៖

- គណបក្សប្រជាជនកម្ពុជាទទួលបានចំនួន ៧៣ អាសនៈ
- គណបក្សហ៊្វុនស៊ិនប៉ិចទទួលបានចំនួន ២៦ អាសនៈ
- គណបក្សសមរង្ស៊ីទទួលបានចំនួន ២៤ អាសនៈ។

ក្នុងរយៈកាលនេះ រាជរដ្ឋាភិបាលមានភារកិច្ចដឹកនាំការងារប្រចាំថ្ងៃតែប៉ុណ្ណោះ។ ក្នុងពេលមានសង្គ្រាម ឬ ក្នុងកាលៈទេសៈពិសេស ដទៃទៀតដែលមិនអាចធ្វើការបោះឆ្នោតកើតរដ្ឋសភាអាចប្រកាសបន្តនីតិកាលមួយ ដងបានចំនួនមួយឆ្នាំតាមសំណើររបស់ព្រះមហាក្សត្រ។ ការប្រកាសបន្តនីតិកាលរបស់រដ្ឋសភាត្រូវសម្រេច ដោយ មតិយល់ព្រម ២/៣ យ៉ាងតិច នៃចំនួនសមាជិករដ្ឋសភាទាំងមូល។ ថ្ងៃទី ១២ ខែ កក្កដា ឆ្នាំ ២០០៤ ព្រឹទ្ធសភាបានបើកសម័យប្រជុំពេញអង្គ ដើម្បីពិភាក្សា និង អនុម័តលើសេចក្តីស្នើច្បាប់ធម្មនុញ្ញបន្ថែមក្រោមការ ដឹកនាំរបស់លោក ញឹក ប៊ុនឆៃ ប្រធានព្រឹទ្ធសភាស្តីទី (នៅថ្ងៃ ១១ កក្កដា ឆ្នាំ ២០០៤ មានកម្លាំងប្រដាប់អាវុធ បានឡោមព័ទ្ធបរិវេណព្រឹទ្ធសភា ដែលមានគេហដ្ឋានសម្តេច ជា ស៊ីម ផងដែរហើយថ្ងៃ ១២ ខែ កក្កដា សម្តេច ជា ស៊ីម ត្រូវបាននាយប៉ូលីសជាន់ខ្ពស់ ហុក ឡុងឌី ជូនដំណើរទៅពិនិត្យជំងឺនៅប្រទេសថៃ)។ សម័យប្រជុំបាន

អនុម័តយល់ព្រមក្នុងសម្លេង ៤៨ លើ ៤៩ គាំទ្រ ចំពោះសេចក្តីស្នើច្បាប់ធម្មនុញ្ញបន្ថែមនេះ ហើយនៅថ្ងៃទី ១៣ សីហា សេចក្តីស្នើច្បាប់ធម្មនុញ្ញបន្ថែម ត្រូវបានប្រកាសឲ្យប្រើដោយព្រះរាជក្រមក្នុងព្រះបរមនាមព្រះករុណាព្រះមហាក្សត្រ (ចុះហត្ថលេខា ដោយញឹក ប៊ុនឆៃ)។ នៅថ្ងៃទី១៣ ខែកុម្ភៈ លោក សម រង្ស៊ី ស្នើឲ្យមាននូវការបង្កើតរូបមន្ត ៥០បូក១(៥០+១)ដើម្បីបោះឆ្នោតសម្តែងការទុកចិត្តក្នុងការបង្កើតរាជរដ្ឋាភិបាលថ្មី។ នៅថ្ងៃដដែលនោះការិយាល័យអ្នកនាំពាក្យ គណបក្សប្រជាជន បានចេញសេចក្តីប្រកាសព័ត៌មានស្វាគមន៍សេចក្តីស្នើរបស់គណបក្ស សមរង្ស៊ី រីឯគណបក្ស ហ្វ៊ុនស៊ិនប៉ិច វិញបានចេញសេចក្តីថ្លែងការណ៍មួយថ្ងៃក្រោយ។

នៅថ្ងៃទី ២ មីនា ឆ្នាំ ២០០៦ រដ្ឋសភាបានអនុម័តលើវិសោធនកម្មមាត្រាចំនួន ៨ នៃរដ្ឋធម្មនុញ្ញដើម្បីបន្តរូបមន្តសម្លេងអនុម័តពី ២/៣ មក ៥០%+១ វិញធ្វើឲ្យអំណាចរាជរដ្ឋាភិបាលព្រឹទ្ធសភា រដ្ឋសភាធ្លាក់ក្នុងដៃគណបក្សប្រជាជនកម្ពុជាទាំងស្រុង[23]។

**ក. ការបង្កើតរដ្ឋសភា**

ច្បាប់ស្តីពីការកំណត់ ចំនួនអាសនៈរដ្ឋសភា នីតិកាលទី៣ ដែលរដ្ឋសភាបានអនុម័តពីថ្ងៃទី ២៣ ខែកក្កដា ឆ្នាំ ២០០២ នាសម័យប្រជុំពេញអង្គលើកទី៨ នីតិកាលទី២ ហើយដែលព្រឹទ្ធសភាពុំមានពេល គ្រប់គ្រាន់ដើម្បីពិនិត្យ អត្ថបទច្បាប់នេះ ឲ្យទាន់តាមការកំណត់របស់ មាត្រា១១៣ ថ្មីនៃរដ្ឋធម្មនុញ្ញឡើយ។ នៅក្នុងចំនួនអាសនៈរដ្ឋសភានីតិកាលទី៣ ត្រូវបានកំណត់ត្រឹមចំនួន ១២៣ ប៉ុណ្ណោះ។ រដ្ឋសភា និងរដ្ឋាភិបាលសម្រាប់នីតិកាលទី៣ នៃរដ្ឋសភាបានបង្កើតចេញជារូបរាងពេញលក្ខណៈនាថ្ងៃព្រហស្បតិ៍ទី ១៥ កក្កដា ឆ្នាំ ២០០៤ បន្ទាប់ពីបានឆ្លងកាត់ភាពជាប់គាំងខាងនយោបាយ នេះគឺបានឆ្លងកាត់នូវវិវត្តន៍បត់បែនជាច្រើនជួនស្មុគស្មាញជួនធូរស្រាល។

**ខ. ដំណើរការនៃរដ្ឋសភា**

នៅក្នុងដំណើរ នៃការបោះឆ្នោតជាកញ្ចប់មិនអាចជជែកពិភាក្សាអ្វីបានឡើយហើយក៏មិនអាចមានការពន្យល់អំពីការបោះឆ្នោតនេះក្រោយការប្រកាសលទ្ធផលនៃការបោះឆ្នោតជាកញ្ចប់នេះដែរ។ សមាជិករដ្ឋសភាត្រូវធ្វើការបោះឆ្នោតដោយបញ្ជាក់ថាព្រម ឬមិនព្រមចំពោះបញ្ជីរាយនាមជាកញ្ចប់មួយដែលព្រឹទ្ធសភា រដ្ឋសភាបានដាក់ជូន។ ការបោះឆ្នោតនេះត្រូវធ្វើឡើងដោយវិធីលើកដៃ។ នៅដើមនីតិកាលថ្មីនីមួយៗរដ្ឋសភា ក្រោយអធិបតីភាពព្រឹទ្ធសមាជិករដ្ឋសភាមុននិងផ្តើមការងាររបស់ខ្លួន និង ក្រោយពេលសម្រេចអំពីសុពលភាពនៃអាណត្តិរបស់សមាជិកម្នាក់ៗអាចចាប់ផ្តើមអនុម័តអត្ថបទដែលមានចារិកជារដ្ឋធម្មនុញ្ញ ឬ ច្បាប់ដើម្បីអនុវត្តន៍បាននូវគោលដៅដូចមានចែងក្នុងមាត្រា១។ នីតិកាលរបស់រដ្ឋសភាមានកំណត់រយៈពេល ៥ ឆ្នាំ ហើយត្រូវផុត

[23] ដកស្រង់ចេញពី សៀវភៅ រដ្ឋាភិបាលកម្ពុជាពីឆ្នាំ ១៩៤៥ ដល់ឆ្នាំ ២០១០ បោះពុម្ពលើកទី២ ទំព័រ ២៤២

កំណត់នៅពេលដែលសភាថ្មីចូលកាន់តំណែង។ រដ្ឋសភាមិនត្រូវបានរំលាយនៅផុតអាណត្តិឡើយ វៀរលែងតែក្នុងករណីដែល រាជរដ្ឋាភិបាលត្រូវបានទម្លាក់ ២ ដង ក្នុងរយៈពេល ១២ ខែ ។ ក្នុងករណីដដែលព្រះមហាក្សត្រត្រូវរំលាយរដ្ឋសភាក្រោយពីព្រះអង្គទ្រង់បានទទួលការស្នើពីនាយករដ្ឋមន្ត្រី និងបន្ទាប់ពីទ្រង់បានទទួលការយល់ព្រមពីប្រធានរដ្ឋសភា។ ការបោះឆ្នោតដើម្បីជ្រើសរើសប្រធានរដ្ឋសភាថ្មី និងប្រព្រឹត្តក្នុងរយៈពេល ៦០ ថ្ងៃ យ៉ាងយូរចាប់ពីថ្ងៃរំលាយរដ្ឋសភាមក។

**គ. ការបង្កើតរាជរដ្ឋាភិបាល**

នៅថ្ងៃទី១៥ ខែមីនា ឆ្នាំ២០០៤ នៅវេលាម៉ោង ១៧ រសៀល សម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន និងជាអនុប្រធានគណបក្សប្រជាជនកម្ពុជា បានអញ្ជើញទៅបង្គំគាល់សាកសួរសុខទុក្ខ សម្តេចក្រុមព្រះនរោត្តម រណឫទ្ធិ ព្រះប្រធានគណបក្សហ៊្វុនស៊ិនប៉ិច ក្នុងលក្ខណៈជាបង និងប្អូន នៅឯរាជដំណាក់វាលស្បូវ ឃុំវាលស្បូវ ស្រុកកៀនស្វាយ ខេត្តកណ្តាល។ ជំនួបនេះ គឺជាព្រឹត្តិការណ៍នយោបាយដ៏សំខាន់បំផុតក្នុងការទម្លុះទម្លាយភាពជាប់គាំងផ្នែកនយោបាយរបស់កម្ពុជា ដែលបានអូសបន្លាយអស់រយៈពេលជាង៨ ខែ កន្លងមកហើយក្រោយការបោះឆ្នោតជាសកលនាថ្ងៃទី២៧ កក្កដា ឆ្នាំ ២០០៣។ ឥស្សរជន អ្នកនយោបាយដ៏សំខាន់ទាំងពីររូប បានឯកភាពបង្កើតឲ្យមានបរិយាកាសធូរស្រាល ដែលអាចឈានទៅបង្កើតបានរដ្ឋាភិបាលចម្រុះមួយមាន ២ គណបក្ស គឺប្រជាជន និងហ៊្វុនស៊ិនប៉ិច ហើយដែលសម្តេចនាយករដ្ឋមន្ត្រីក៏បានគាំទ្រយល់ព្រមឲ្យសម្តេចក្រុមព្រះនរោត្តម រណឫទ្ធិ អាចជ្រើសរើសយកឥស្សរជនមកពី គណបក្សនយោបាយផ្សេងចូលមកក្នុងរដ្ឋាភិបាលថ្មីក៏បានដែរ។ ឥស្សរជនអ្នកដឹកនាំជាន់ខ្ពស់ទាំងពីរក៏បានឯកភាពបង្កើតឲ្យមានក្រុមការងាររបស់គណបក្សនយោបាយទាំងពីរ ដែលមានឥស្សរជនជាន់ខ្ពស់រួមមាន៖

| **គណបក្សប្រជាជនកម្ពុជា** | **និងគណបក្សហ៊្វុនស៊ិនប៉ិច** |
|---|---|
| ១. លោក.សាយ ឈុំ ជាប្រធាន | ១. ក្រុមព្រះនរោត្តម សិរីវុឌ្ឍ ជាប្រធាន |
| ២. លោក.ស ខេង | ២. លោក.លឺ ឡាយស្រេង |
| ៣. លោក.សុខ អាន | ៣. លោក.ញឹក ប៊ុនឆៃ |
| ៤. លោក.ទៀ បាញ់ | ៤. លោក.ស៊ុន ចាន់ថុល |
| ៥. លោក.អ៊ឹម ឈុនលឹម | ៥. លោក.គង់ វិបុល។ |

ក្រុមការងារនេះ នឹងធ្វើការពិភាក្សាលើការរៀបចំសមាសភាពថ្នាក់ដឹកនាំ រដ្ឋសភា រាជរដ្ឋាភិបាល និងគាក់តែងកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាលអាណត្តិថ្មី។ នៅថ្ងៃទី ២៨ ខែ មីនា ឆ្នាំ ២០០៤ នៅវេលាម៉ោង ៩ ព្រឹក ក្រុមការងាររបស់គណបក្សនយោបាយធំទាំងពីររួមមានគណបក្សប្រជាជនកម្ពុជាចំនួន ៥ រូប ដឹកនាំដោយលោក សាយ ឈុំ និងគណបក្សហ៊្វុនស៊ិនប៉ិច ចំនួន ៥ រូប ដឹកនាំដោយស្តេចក្រុមឃុននរោត្តម សិរីវុឌ្ឍ បានជួប

ប្រជុំជាលើកដំបូងនៅក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា (CDC)។ កិច្ចប្រជុំនេះ ជាការអនុវត្តតាមស្មារតី នៃកិច្ចប្រជុំកំពូលសម្តេចក្រុមព្រះ និង សម្តេច ហ៊ុន សែន ថ្ងៃទី ១៥ ខែ មីនា ឆ្នាំ ២០០៤។ កិច្ចប្រជុំពិភាក្សាជាលើកដំបូងរបស់ក្រុមការងារទាំងពីរបានឯកភាពគ្នាលើរបៀបវារៈកិច្ចប្រជុំមានចំនួន ៣ មានដូចខាងក្រោម៖

១. ពិភាក្សាអំពីកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាលចម្រុះ។

២. ពិភាក្សាលើពិធីសារ នៃកិច្ចព្រមព្រៀងសហប្រតិបត្តិការរវាងគណបក្សទាំងពីរ

៣.ពិភាក្សាអំពីរចនាសម្ព័ន្ធដឹកនាំរបស់រដ្ឋសភា និងរាជរដ្ឋាភិបាល ហើយបន្ទាប់ពីបញ្ចប់កិច្ចប្រជុំនៅវេលាម៉ោង ១២ ថ្ងៃត្រង់ ក្រុមការងាររបស់ភាគីទាំងពីរបានចេញសេចក្តីប្រកាសព័ត៌មានមួយមានខ្លឹមសារជាអាទិ៍ថា ក្រុមការងារទាំងពីរបានផ្លាស់ប្តូរឯកសារនៃសេចក្តីព្រាងកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាលចម្រុះ ដែលស្នើឡើងដោយគណបក្សរៀងៗខ្លួន។ ក្រុមការងារនៃគណបក្សទាំងពីរបានស្តាប់ការធ្វើអត្ថាធិប្បាយសង្ខេប ដោយតំណាងក្រុមការងារនីមួយៗ ស្តីពីសេចក្តីព្រាងកម្មវិធីនយោបាយ ហើយបានវាយតម្លៃថា មានចំណុចស្របគ្នាជាច្រើនក្នុងសេចក្តីព្រាងទាំងពីរ។

នៅថ្ងៃទី ២ ខែ មិថុនា ឆ្នាំ ២០០៤ វេលាម៉ោង ៥ រសៀល នៅព្រះដំណាក់វាលស្បូវ ស្ថិតនៅឃុំវាលស្បូវ ស្រុក កៀនស្វាយ ខេត្តកណ្តាល សម្តេចក្រុមព្រះនរោត្តម រណប្ញទ្ធិ ព្រះប្រធានគណបក្សហ៊្វុនស៊ិនប៉ិច និង សម្តេច ហ៊ុន សែន ជាអនុប្រធានគណបក្សប្រជាជនបានជួបគ្នាជាលើកទី ២ ដើម្បីដោះស្រាយចំណុចសេសសល់នៃកម្មវិធីនយោបាយសម្រាប់រាជរដ្ឋាភិបាលអាណត្តិថ្មី ដែលក្រុមការងារនៃគណបក្សទាំងពីរ ពុំទាន់បានសម្រេចនៅឡើយ។ លទ្ធផលនៃជំនួបនេះ ថ្នាក់ដឹកនាំនៃគណបក្សទាំងពីរបានសម្រេចដោះស្រាយបញ្ចប់ទាំងស្រុងនូវខ្លឹមសារនៃកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាល និង ឯកភាពគ្នាជ្រើសរើសយកនីតិវិធីបោះឆ្នោតជាកញ្ចប់ដើម្បីជ្រើសតាំងរចនាសម្ព័ន្ធដឹកនាំរដ្ឋសភា និងផ្តល់ការទុកចិត្តចំពោះ សមាសភាពរាជរដ្ឋាភិបាលសម្រាប់នីតិកាលទី ៣ នៃរដ្ឋសភា។ ថ្នាក់ដឹកនាំទាំងពីរក៏បានឯកភាពគ្នាផងដែរ ឲ្យក្រុមការងារគណបក្សទាំងពីរចាប់ផ្តើមពិភក្សាអំពីពិធីសារនៃកិច្ចព្រមព្រៀងសហប្រតិបត្តិការរវាងគណបក្សទាំងពីរ និង នីតិវិធីនៃការបោះឆ្នោតជាកញ្ចប់។ លើសពីនេះ ទៅទៀតនៅដំណាក់កាលចុងក្រោយបើសិនជាគណៈកម្មការចម្រុះនេះ ដោះស្រាយមិនបានលោកសុខចិត្តឆ្លៀតពេលត្បិតត្បៀតរបស់លោកជួបប្រធានគណបក្សប្រឆាំងលោកសមរង្ស៊ី ដើម្បីរកដំណោះស្រាយនយោបាយសមស្របមួយ។

ម្យ៉ាងវិញទៀតការប្រកាសរបស់លោកហ៊ុនសែនថាចង់បង្រួបបង្រួមជាតិនេះស្របទៅនិងគោលបំណងរបស់លោក សម រង្ស៊ី ដែលលោកបានប្រកាសថាលោកមិនចង់យកខ្មែរណាមួយជាសត្រូវនោះទេ។ ហើយនៅមុនបោះឆ្នោតប្រមាណ ១ សប្តាហ៍ក្រោយពេលលោក សម រង្ស៊ី បានវិលចូលមាតុប្រទេសវិញលោកសម រង្ស៊ី បានព្យាយាមដាក់លិខិតទៅក្រុមប្រឹក្សាធម្មនុញ្ញគណៈកម្មាការជាតិរៀបចំការបោះឆ្នោត និងដាក់ទៅប្រធានរដ្ឋ

សភាដើម្បីសុំឲ្យលោកមានសិទ្ធិបោះឆ្នោតនិងសិទ្ធិឈរឈ្មោះជាបេក្ខជនតំណាងរាស្ត្រ។ នៅពេលនោះកម្ពុជាបានជាប់គាំងនយោបាយក៏ប៉ុន្តែនៅឆ្នាំ ២០០៤ លោក ហ៊ុន សែន ដើម្បីចង់បង្កើតរដ្ឋាភិបាលថ្មីបាននោះលោកបានប្រើយុទ្ធសាស្ត្រនយោបាយបំបែកសម្ព័ន្ធ អ្នកប្រជាធិបតេយ្យដោយទាញយកគណបក្សហ៊្វុនស៊ិនប៉ិច របស់សម្តេចក្រុមព្រះបែកចេញពីលោកសម រង្ស៊ី ទៅបង្កើតរដ្ឋាភិបាលចម្រុះជាមួយគ្នាបន្ទាប់ពីជាប់គាំងនយោបាយជាង ១១ ខែមក។

រដ្ឋាភិបាលថ្មីនីតិកាលទី៣ នេះបានបង្កើតឡើងនៅក្នុងខែ កក្កដា ឆ្នាំ ២០០៤។ នៅថ្ងៃទី៥ ខែកក្កដា ឆ្នាំ ២០០៤ រដ្ឋសភាបានបើកសម័យប្រជុំបន្តលើកទី១ នីតិកាលទី៣ក្រោមការដឹកនាំរបស់លោកជា សុទ្ធ ព្រឹទ្ធសមាជិករដ្ឋសភា។ រដ្ឋសភាបានអនុម័តដោយលើកដៃក្នុងសម្លេង ៩៦/៩៦ ក្នុងការជ្រើសតាំង ប្រធាន អនុប្រធានរដ្ឋសភា ប្រធានអនុប្រធានគណៈកម្មការនានានៃរដ្ឋសភានិង ផ្តល់ការទុកចិត្តចំពោះសមាសភាព នៃរាជរដ្ឋាភិបាលកម្ពុជាសម្រាប់នីតិកាលទី ៣ នៃរដ្ឋសភា។ សម្តេចក្រុមព្រះនរោត្តម រណឫទ្ធិ ត្រូវជ្រើសតាំងជាព្រះប្រធានរដ្ឋសភា សម្តេច ហេង សំរិន ងួន ញ៉ិល ត្រូវបានជ្រើសតាំងជាអនុប្រធានទី១ និង ទី២ របស់រដ្ឋសភា សម្តេច ហ៊ុន សែន ជានាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា។

**ឃ. ការបង្កើតច្បាប់ធម្មនុញ្ញបន្ថែម**

ច្បាប់ធម្មនុញ្ញនេះ មាន គោលដៅធានាក្នុងគ្រប់កាលៈទេសៈនូវដំណើរការល្អប្រសើរនៃស្ថាប័នជាតិដោយគោរពទៅតាមគោលការណ៍ជាមូលដ្ឋាននៃលទ្ធិប្រជាធិបតេយ្យ សេរីពហុបក្សសមស្របតាមតម្រូវការនៃភាពចាំបាច់[24]។ ច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិត្រូវបានរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជាអនុម័តនៅថ្ងៃទី ៨ ខែ កក្កដា ឆ្នាំ២០០៤ នាសម័យប្រជុំរដ្ឋសភាលើកទី១ នីតិកាលទី៣។

**ខ. ការបង្កើតរាជរដ្ឋាភិបាលដោយការបោះឆ្នោតជាកញ្ចប់**

ការបោះឆ្នោតនេះ គឺដើម្បីអនុម័ត ឬ សម្រេចបញ្ហាជាច្រើន ក្នុងពេលតែមួយដោយសមាជិក ម្នាក់ប្រើសម្លេងតែមួយ។ នៅក្នុងចំណុចនេះ មាននីតិវិធីដែលត្រូវបានដកស្រង់ចេញពីរដ្ឋធម្មនុញ្ញប្រទេសបារាំងយកមកកែច្នៃទៅតាមបរិបទនយោបាយកម្ពុជា ដែលអ្នកនយោបាយខ្មែរយកមកប្រើក្រោយពីជាប់គាំងនយោបាយពីឆ្នាំ ២០០៣ រហូតដល់ខែ កក្កដា ឆ្នាំ ២០០៤។

ឧទាហរណ៍៖ ក្រោយពីការបោះឆ្នោតសកលជ្រើសរើសតំណាងរាស្ត្រឆ្នាំ ២០០៣ គណបក្សប្រជាជនជាប់ឆ្នោតបាន ៧៣ អាសនៈ គណបក្ស ហ៊្វុនស៊ិនប៉ិច ២៦ អាសនៈ និង គណបក្ស សម រង្ស៊ី ទទួលបាន ២៤

[24] មាត្រា១ នៃច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានានូវដមណើរការជាប្រក្រតីនៃស្ថាប័នជាតិ

អាសនៈ។ នៅក្នុងដំណើរការ នៃការបោះឆ្នោតជាកញ្ចប់មិនអាចជជែកពិភាក្សាអ្វីបានឡើយ ហើយក៏មិនអាចមានការពន្យល់អំពីការបោះឆ្នោតនេះក្រោយការប្រកាសលទ្ធផលនៃការបោះឆ្នោតជាកញ្ចប់នេះដែរ។

សមាជិករដ្ឋសភា ត្រូវធ្វើការបោះឆ្នោតដោយបញ្ជាក់ថាព្រម ឬ មិនព្រមចំពោះបញ្ជីរាយនាមជាកញ្ចប់មួយដែលព្រឹទ្ធសមាជិក រដ្ឋសភាបានដាក់ជូន។ ការបោះឆ្នោតនេះ ត្រូវធ្វើឡើងដោយវិធីលើកដៃ[25]។

**ច. ក្រសួង និងស្ថាប័ននានា**

សមាសភាពរាជរដ្ឋាភិបាលមានដូចខាងក្រោម៖

១. នាយករដ្ឋមន្ត្រី = ១ រូប គឺអគ្គសេនាបតីតេជោ ហ៊ុន សែន

២. ឧបនាយករដ្ឋមន្ត្រី = ៧ រូប

៣. ទេសរដ្ឋមន្ត្រី = ១៥ រូប (៨ រូប រដ្ឋមន្ត្រី កាន់ក្រសួង ៧ រូប ទៀតមិនកាន់ក្រសួង តែទទួលបន្ទុកបេសកម្មពិសេសតាមការប្រគល់ភារកិច្ចផ្ទាល់ពីនាយករដ្ឋមន្ត្រី)

៤. រដ្ឋមន្ត្រី = ២៩ កាន់ក្រសួង

៥. រដ្ឋលេខាធិការ = ១៣២ រូប។

## ផ្នែកទី៤ ការបង្កើតរាជរដ្ឋាភិបាលតាមអាណត្តិសភា២០០៨-២០១៣

ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៤ បានប្រព្រឹត្តទៅនៅថ្ងៃទី២៧ ខែ កក្កដា ឆ្នាំ ២០០៨ ដើម្បីជ្រើសតាំងតំណាងរាស្ត្រ ចំនួន ១២៣ រូប ដែលមានគណបក្សនយោបាយឈរឈ្មោះបោះឆ្នោតចំនួន ១១ សម្រាប់មណ្ឌលចំនួន ២៤។ ក្នុងនោះមានគណបក្សដែលឈ្នះឆ្នោតមាន៖

- គណបក្សប្រជាជនកម្ពុជាមានចំនួន ៩០ អាសនៈ
- គណបក្សសម រង្ស៊ី មានចំនួន ២៦ អាសនៈ
- គណបក្សសិទ្ធិមនុស្សមានចំនួន ៣ អាសនៈ
- គណបក្សហ្វ៊ុនស៊ិនប៉ិច មានចំនួន ២ អាសនៈ និង
- គណបក្សនរោត្តម រណឫទ្ធិមានចំនួន ២ អាសនៈ។

សរុបមកអាសនៈដែលមានក្នុងរដ្ឋសភាមានទាំងអស់ចំនួន ១២៣ អាសនៈ នៅទូទាំងប្រទេសកម្ពុជា។ ដូចដែលមានចែងក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា។ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ចែងថា រដ្ឋសភាមានសមាជិកជាតំណាងរាស្ត្រយ៉ាងតិច ១២០ រូប។ តំណាងរាស្ត្រត្រូវជ្រើសតាំងដោយការបោះឆ្នោតសកល ដោយសេរី ដោយស្មើភាព ដោយចំពោះ និងតាមវិធីជ្រើសឆ្នោតជាសម្ងាត់។ អាសនៈដែលទទួលបានគិត

[25] មាត្រា ៥ ច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ

ជាភាគរយះ គណបក្សប្រជាជនកម្ពុជា ៩០ អាសនៈស្មើនិង ៧៣.១៨% គណបក្សសមរង្ស៊ី ២៦ អាសនៈស្មើនិង ២១.១៤% គណបក្សសិទ្ធិមនុស្ស ០៣ អាសនៈស្មើនិង ២.៤៤% គណបក្សហ្វ៊ុនសិុនប៉ិច ០២ អាសនៈ ស្មើនិង ១.៦២ % គណបក្សនរោត្តមរណឫទ្ធិ ០២ អាសនៈស្មើនិង ១.៦២%។

តំណាងរាស្ត្រសរុប ១២៣ រូប ក្នុងនោះតំណាងរាស្ត្រជាស្ត្រីចំនួន ២៧ រូប ស្មើនិង ២១.៩៤% តំណាងរាស្ត្រ ជាជនជាតិភាគតិចចំនួន ៦ រូប ក្រុមសមាជិកស្ត្រីរដ្ឋសភាត្រូវបានបង្កើតឡើង។ រដ្ឋសភានីតិកាលទី៤ បានបើកសម័យប្រជុំដំបូងក្រោមព្រះរាជធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រនៃព្រះបរមរាជាណាចក្រកម្ពុជានៅថ្ងៃ ពុធ ទី ២៤ ខែ កញ្ញា ឆ្នាំ ២០០៨ ។ តំណាងរាស្ត្របានធ្វើសច្ចាប្រណិធាននៅព្រះបរមរាជវាំង មុនចូលកាន់តំណែងនៅថ្ងៃដដែល។ រដ្ឋសភាបានប្រជុំក្រោមអធិបតីភាព ឯកឧត្តម ជា សុទ្ធ ព្រឹទ្ធសមាជិករដ្ឋសភាដើម្បីបោះឆ្នោតជ្រើសតាំងប្រធាន អនុប្រធានគណៈកម្មការជំនាញ និងផ្តល់សេចក្តីទុកចិត្តរាជរដ្ឋាភិបាលនៅថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០០៨។ ប្រទេសកម្ពុជា ជាព្រះរាជាណាចក្រ ដែលព្រះមហាក្សត្រទ្រង់ ប្រតិបត្តិតាមរដ្ឋធម្មនុញ្ញនិងតាមលទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស ជារដ្ឋឯករាជ អធិបតេយ្យ សន្តិភាព អព្យាក្រឹត្យ អចិន្ត្រៃយ៍ និងមិនចូលបក្សសម្ព័ន្ធ។

**ក. ការបង្កើតរដ្ឋសភា**

ការបង្កើតរដ្ឋសភា និងរដ្ឋាភិបាលក្នុងពេលតែមួយតាមច្បាប់រដ្ឋធម្មនុញ្ញបន្ថែមមាត្រា ៣,៤,៥, និង៦ ថ្មី ដែលការបង្កើតនេះ គឺតាមរយៈការបោះឆ្នោតជាកញ្ចប់ដែលយើងបានធ្វើការពន្យល់យ៉ាងពិស្តារហើយនៅក្នុងជំពូករដ្ឋសភា។ នៅក្នុងមាត្រា ១១៨ ថ្មី នៃរដ្ឋធម្មនុញ្ញបានបញ្ជាក់ថាគណៈរដ្ឋមន្ត្រីជារាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា។ មាត្រានេះ ដែលក៏បានរៀបរាប់អ្នកណាខ្លះជាសមាជិករាជរដ្ឋាភិបាលគណៈរដ្ឋមន្ត្រីដឹកនាំដោយនាយករដ្ឋមន្ត្រីមួយរូបអមដោយទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការជាសមាជិក[26]។

**ខ. ដំណើរការនៃរដ្ឋសភា**

នៅក្នុងឆ្នាំ ២០០៨ អាសនៈនៅក្នុងរដ្ឋសភាបានរក្សាចំនួន ១២៣ ដដែល។ ការបោះឆ្នោតនៅអាណត្តិទី ៤ នេះមានគណបក្សចូលរួមចំនួន ១០ ហើយចំនួនអ្នកមានឈ្មោះបោះឆ្នោតគឺ ៨ លាន ១ សែន នាក់និងអាត្រាទៅបោះឆ្នោត ៧៥%។ ការបោះឆ្នោតលើកនេះ គឺគណបក្សប្រជាជនកម្ពុជាបានឈ្នះភ្លូកទឹកភ្លូកដីតែម្តងដោយទទួលបានអាសនៈ ដល់ ៩០ កៅអីឯណោះ។

សល់ពីនេះ គណបក្សនរោត្តមរណឫទ្ធិ និង គណបក្សហ្វ៊ុនសិុនប៉ិច បានត្រឹមតែចែកគ្នាម្នាក់ ២ កៅអី ដែលជាផ្លែផ្កានៃការបែកបាក់គ្នា។

[26] មាត្រា ១១៨ ថ្មី (មាត្រា ៩៩ ចាស់) រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ១៩៩៣

**គ. ការបង្កើតរាជរដ្ឋាភិបាល**

ការបង្កើតរាជរដ្ឋាភិបាល គឺគេអាចបង្កើតតាមរូបមន្ត ២ យ៉ាងដោយរូបមន្តទី ១ បង្កើតតាមរូបមន្តរដ្ឋធម្មនុញ្ញឆ្នាំ ១៩៩៣ គឺគេបង្កើតរដ្ឋសភាហើយបង្កើតរដ្ឋាភិបាលតាមក្រោយ (ឪកើតមុនកូន) និងរូបមន្តទី ២ គេបង្កើតរដ្ឋាភិបាលតាមច្បាប់ធម្មនុញ្ញបន្ថែម គឺគេបង្កើតរដ្ឋសភានិងរដ្ឋាភិបាលក្នុងពេលតែមួយ (ឪ និងកូនកើតដំណាលគ្នា)។ នៅក្នុងរូបមន្តទីមួយៈ បង្កើតរដ្ឋសភាហើយបង្កើតរដ្ឋាភិបាលតាមក្រោយការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រហើយ គេបង្កើតរដ្ឋសភាតាមមាត្រា ១១៩ ថ្មី និងមាត្រា ៩០ ថ្មី។

ដូច្នេះ ក៏មានរូបមន្តបង្កើតរដ្ឋាភិបាលនេះឡើងក្រោយពេលគេបង្កើតក្បាលម៉ាស៊ីនរដ្ឋសភាចប់សព្វគ្រប់ហើយ ប្រធានរដ្ឋសភា ដោយមានមតិឯកភាពពីអនុប្រធានទាំងពីរ នៃរដ្ឋសភាត្រូវចាត់តាំងបេក្ខជននាយករដ្ឋមន្ត្រីពីគណបក្សដែលមានកៅអីច្រើនជាងគេ ឬ សម្លេងឆ្នោតឈ្នះគេស្នើទៅព្រះមហាក្សត្រដើម្បីចេញ ព្រះរាជក្រឹត្យតែងតាំងបេក្ខជននាយករដ្ឋមន្ត្រីនោះឲ្យរៀបចំសមាសភាពសមាជិករាជរដ្ឋាភិបាល។ ក្រោយពេល បេក្ខជននាយករដ្ឋមន្ត្រីរៀបចំ សមាសភាពសមាជិករាជរដ្ឋាភិបាលហើយត្រូវនាំសមាជិកទាំងអស់នោះទៅឲ្យរដ្ឋសភាបោះឆ្នោតផ្តល់សេចក្តីទុកចិត្តតាមសម្លេងឆ្នោតភាគច្រើនដាច់ខាត (៥០% +១) នៃសមាជិករដ្ឋសភាទាំងមូល។ ការបោះឆ្នោតនេះគេធ្វើតាមវិធីបោះឆ្នោតជាសម្ងាត់។ ក្រោយពេលរដ្ឋសភាផ្តល់សេចក្តីទុកចិត្តដល់រាជរដ្ឋាភិបាលហើយនាយករដ្ឋមន្ត្រីត្រូវតែបញ្ជូនបញ្ជីឈ្មោះសមាជិករាជរដ្ឋាភិបាលទាំងមូលស្នើទៅព្រះមហាក្សត្រដើម្បីចេញព្រះរាជក្រឹត្យតែងតាំងរាជរដ្ឋាភិបាលទាំងមូល[27]។

**ឃ. ក្រសួង និងស្ថាប័ននានា**

នៅក្នុងព្រះរាជក្រឹត្យស្តីពីការតែងតាំងសមាជិករាជរដ្ឋាភិបាលកាលពីថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ដែលឡាយព្រះហស្ថលេខាដោយព្រះមហាក្សត្រ នរោត្តម សីហមុនី។ ចំនួនសមាជិក រាជរដ្ឋាភិបាលអាណត្តិទី៤ មានដូចតទៅៈ

១.នាយករដ្ឋមន្ត្រី = ១ រូប គឺសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

២. ឧបនាយករដ្ឋមន្ត្រី = ១០ រូប (១ រូប ឧបនាយករដ្ឋមន្ត្រីប្រចាំការ)

៣. ទេសរដ្ឋមន្ត្រី = ១៦ រូប (៤ រូបជារដ្ឋមន្ត្រីកាន់ក្រសួង ១២ រូបទៀតមិនកាន់ក្រសួងតែទទួលបន្ទុកបេសកម្មពិសេសតាមការប្រគល់ភារកិច្ចផ្ទាល់ពីនាយករដ្ឋមន្ត្រី)

៤. រដ្ឋមន្ត្រី = ២៦ រូប កាន់ក្រសួង

[27] ដកស្រង់ចេញពីសៀវភៅ មូលដ្ឋានច្បាប់ និងស្ថាប័នច្បាប់ និពន្ធដោយ ឯកឧត្តម គន យឿន បោះពុម្ពលើកទី៣ ទំព័រ ១៥១,១៥២,១៥៣

៥. រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី = ៨ រូប (ធ្វើការងារតាមការប្រគល់ភារកិច្ចផ្ទាល់ពីនាយករដ្ឋមន្ត្រី)

៦. រដ្ឋលេខាធិការ = ១៧៦ រូប

(២ រូប ជារដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានកាសចរណ៍ស៊ីវិល និងរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ)

៧. អនុរដ្ឋលេខាធិការ = ២០៥ រូប។

សមាជិករាជរដ្ឋាភិបាល និងអនុរដ្ឋលេខាធិការនៅក្នុងរាជរដ្ឋាភិបាលអាណត្តិទី៤ នេះមានការកើនចំនួនបន្ថែមទៀត ដោយសារតែសេចក្តីត្រូវការចាំបាច់របស់រាជរដ្ឋាភិបាលសម្រាប់ដឹកនាំប្រទេសជាតិ នៅក្នុងដំណាក់កាលបច្ចុប្បន្ននេះ។ រាជរដ្ឋាភិបាលអាណត្តិទី៤ នេះ មានក្រសួងចំនួន ២៥ ដែលជាសេនាធិការឲ្យរាជរដ្ឋាភិបាល និង មានរដ្ឋលេខាធិការដ្ឋានចំណុះឲ្យទីស្តីការគណៈរដ្ឋមន្ត្រីចំនួន២។ ក្រសួងទាំងនេះ រាជរដ្ឋាភិបាលអាចលុបចោល ឬ បង្កើតថែមទៀត ក្នុងករណីចាំបាច់នៃការដឹកនាំការងារ និងដើម្បីប្រសិទ្ធិភាពការងារ។ ចំណែកឯ រដ្ឋលេខាធិការដ្ឋានចំនួន ២ ដែលចំណុះឲ្យទីស្តីការគណៈរដ្ឋមន្ត្រី នៅថ្ងៃខាងមុខបើរាជរដ្ឋាភិបាលយល់ឃើញថាចាំបាច់អាចដំឡើងទៅជាក្រសួងបាន។

ប៉ុន្តែ ការបង្កើតក្រសួងថ្មី ឬការលុបក្រសួងណាមួយនោះ ត្រូវឆ្លងកាត់ការអនុម័តពីរដ្ឋសភាតាមមតិភាគច្រើនដាច់ខាតនៃចំនួនសមាជិករដ្ឋសភា។ រួចហើយបញ្ចូលទៅព្រះមហាក្សត្រឡាយព្រះហស្ថលេខាប្រកាសឲ្យប្រើ ដោយព្រះរាជក្រមលើច្បាប់រៀបចំអង្គការមួយ។

**ផ្នែកទី៥ ការបង្កើតរាជរដ្ឋាភិបាលតាមអាណត្តិសភា២០១៣-២០១៨**

ការបោះឆ្នោតសកលជ្រើសតាំងតំណាងរាស្ត្រនីតិកាលទី៥ នៃរដ្ឋសភាបានប្រព្រឹត្តទៅនៅថ្ងៃទី ២៨ ខែកក្កដា ឆ្នាំ ២០១៣ ចាប់ពីម៉ោង ៧:០០ ព្រឹក ដល់ម៉ោង ១៥ :០០ រសៀលនៅការិយាល័យបោះឆ្នោតចំនួន ១៩ ០០៩ នៅទូទាំងប្រទេស។ បើតាមសៀវភៅស្តីពីការបោះឆ្នោតសកលជ្រើសតាំងតំណាងរាស្ត្រនីតិកាលទី៥ នៃរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០១៣ ដែលបានផ្សព្វផ្សាយដោយ គ.ជ.ប កាលពីថ្ងៃទី៥ ខែកញ្ញា ឆ្នាំ ២០១៣ បង្ហាញថាប្រជាជនដែលចេញទៅបោះឆ្នោតមានអាត្រា ៦៩,៦១% ស្មើនិង ៦ ៧៣៥ ២៤៤ នាក់ ក្នុងចំណោមអ្នកចុះឈ្មោះបោះឆ្នោតចំនួន ៩ ៦៧៥ ៤៥៣ នាក់[28]។ អាសនៈដែលទទួលបានមានដូចជាៈ

- គណបក្សប្រជាជនកម្ពុជា ៦៨ អាសនៈ ស្មើនិង ៥៥,២៨%
- គណបក្សសង្គ្រោះជាតិ ៥៥ អាសនៈ ស្មើនិង ៤៤,៧១%។

[28] ដកស្រង់ចេញពី សៀវភៅស្តីពី ការបោះឆ្នោតសកលជ្រើសតាំងតំណាងរាស្ត្រនីតិកាលទី៥ នៃរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០១៣

តំណាងរាស្ត្រសរុបចំនួន ១២៣ រូប ក្នុងនោះតំណាងរាស្ត្រ ស្ត្រី ២៥រូប ក្រុមស្ត្រីសមាជិករដ្ឋសភាត្រូវបានបង្កើត។ បរិយាកាសបោះឆ្នោតបានប្រព្រឹត្តទៅដោយរលូននិងប្រកបដោយសន្តិភាព។ ជោគជ័យនៃការបោះឆ្នោតនេះ ឆ្លុះបញ្ចាំងឲ្យឃើញពីការវិវត្តន៍ជាវិជ្ជមានប្រកបដោយមោទនភាពនូវការអនុវត្តលទ្ធិប្រជាធិបតេយ្យក្នុងប្រទេសកម្ពុជា។ ប្រជាពលមានសិទ្ធិពេញលេញក្នុងការសម្តែងចេញនូវឆន្ទៈរបស់ខ្លួនដោយសេរីនៅគ្រប់ដំណាក់កាលនៃដំណើរការបោះឆ្នោត។ ប្រជាពលរដ្ឋចូលរួមក្នុងយុទ្ធនាការឃោសនាបោះឆ្នោត ដើម្បីសម្តែងចេញនូវការគាំទ្រចំពោះ គណបក្សនយោបាយដែលខ្លួនពេញចិត្តដោយពុំមានការគៀបសង្កត់និងគំរាមកំហែងពីមជ្ឈដ្ឋានណាមួយឡើយ។

ក្នុងដំណើរការបោះឆ្នោតនេះ ពុំមានអំពើហិង្សាធ្ងន់ធ្ងរដែលប៉ះពាល់ដល់ដំណើរការបោះឆ្នោតហើយក៏ពុំមានឃើញរបាយការណ៍ណាមួយអំពីការរំលោភបំពាន ឬ ការធ្វើឃាតខាងនយោបាយដល់សមាជិកគណៈបក្សណាមួយនោះទេ។ការបោះឆ្នោតបានប្រព្រឹត្តទៅក្រោមការឃ្លាំមើលរបស់អ្នកសង្កេតការណ៍អន្តរជាតិចំនួន ២៩២ នាក់ និងសង្កេតការណ៍ជាតិចំនួន ៤០ ១៤២ នាក់ រួមមានអ្នកសង្កេតការណ៍របស់អង្គការ COMFREL ដែលមានវត្តមាននៅគ្រប់ការិយាល័យបោះឆ្នោតហើយបានសង្កេតឃើញជាទូទៅថាការបោះឆ្នោតនេះប្រព្រឹត្តទៅដោយសេរី យុត្តិធម៌ តម្លាភាព គ្មានការគំរាមកំហែងគ្មានអំពើហិង្សា និងអាចទទួលយកបាន។

**ក. ការបង្កើតរដ្ឋសភា**

នៅថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០១៣ គឺជាកាលបរិច្ឆេទនៃកិច្ចប្រជុំដំបូងនៃការបង្កើតសភានីតិកាលទី ៥។ វាក្យខណ្ឌទី១ មាត្រា៨២ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាបានចែងថារដ្ឋសភាបើកសម័យប្រជុំដំបូង ៦០ ថ្ងៃយ៉ាងយូរក្រោយពេលបោះឆ្នោតតាមការកោះប្រជុំរបស់ព្រះមហាក្សត្រ។ ខុមហ្វ្រែលយល់ថា ជាបច្ចេកទេសមានរយៈពេលច្រើនក្នុងការអនុវត្តន៍ មាត្រា៨២ ខាងលើព្រោះថាក្រោយការបោះឆ្នោតគឺគេនិយាយទៅដល់ការបញ្ចប់ការបោះឆ្នោតឬការប្រកាសលទ្ធផលបោះឆ្នោតចុងក្រោយ។ ដូចនេះ ក្រោយពេលបោះឆ្នោតគឺចាប់តាំងពីក្រោយថ្ងៃទី០៨ ខែកញ្ញា ឆ្នាំ២០១៣ ដែលគណកម្មាធិការជាតិរៀបចំការបោះឆ្នោតបានប្រកាសលទ្ធផលជាផ្លូវការនៃការបោះឆ្នោតនោះ។ កិច្ចប្រជុំរដ្ឋសភាដំបូងដែលឆ្លើយតបតាមមាត្រា៨២ ខាងលើអាចត្រូវបានពន្យាពេលរហូតដល់ដើមខែវិច្ឆិកា។ ការសន្យាពេលនេះ គឺទុកពេលវេលាឲ្យគណបក្សប្រជាជនកម្ពុជានិងគណបក្សសង្គ្រោះជាតិមានពេលវេលាគ្រប់គ្រាន់ដើម្បីចរចារស្វែងរកដំណោះស្រាយជម្លោះក្រោយការបោះឆ្នោត។ មាត្រា ច្បាប់ខាងលើបានសរសេរថារដ្ឋសភាបើកសម័យប្រជុំដំបូង៦០ ថ្ងៃយ៉ាងយូរក្រោយការបោះឆ្នោត។ ក្រោយពេលបោះឆ្នោតសំដៅទៅលើ ពេលដែលដំណើរការបោះឆ្នោតទាំងមូលបានបញ្ចប់មានន័យថា ក្រោយការបោះឆ្នោតទទួលបានលទ្ធផលផ្លូវការមិនសំដៅទៅលើក្រោយកាលបរិច្ឆេទណាមួយដែលបានកំណត់ក្នុងប្រតិទិនបោះឆ្នោតដូចជាថ្ងៃ

បោះឆ្នោតជាដើមនោះទេ[29]។ នៅក្នុងកិច្ចប្រជុំរដ្ឋសភាដំបូងកាលពីថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០១៣មានតែបេក្ខជនជាប់ឆ្នោតជាតំណាងរាស្ត្រចំនួន ៦៨ រូប មកពីគណបក្សប្រជាជនកម្ពុជាទេបានចូលរួមក្នុងកិច្ចប្រជុំដំបូងនោះ ដោយមិនមានបេក្ខជនជាប់ឆ្នោតជាតំណាងរាស្ត្រចំនួន៥៥រូប របស់គណបក្សសង្គ្រោះជាតិ។ ក្នុងដំណើរការនេះ បេក្ខជនជាប់ឆ្នោតចំនួន ៦៨ រូប មកពីគណបក្សប្រជាជនកម្ពុជាបានក្លាយជាសមាជិកតំណាងរាស្ត្រខណៈពេល ដែលបេក្ខជនជាប់ឆ្នោត ៥៥ រូប របស់គណបក្សសង្គ្រោះជាតិមិនទាន់ក្លាយជាសមាជិកតំណាងរាស្ត្រនៅឡើយទេ។ ជាលទ្ធផល គណបក្សសង្គ្រោះជាតិ បានធ្វើពហិការមិនចូលសភាក្នុងខែកញ្ញា ឆ្នាំ២០១៣ ហើយបានប្ដេជ្ញាថានិងមិនចូលសភារហូតដល់ការកែទម្រង់ការបោះឆ្នោតត្រូវបានធ្វើឡើង។ លទ្ធផល ជម្លោះបាននាំមកឲ្យមានការផ្ទុះនៃបាតុកម្មប្រឆាំងរដ្ឋាភិបាលយ៉ាងរីករាលដាល។ នៅថ្ងៃទី១០ ខែមេសា ឆ្នាំ២០១៤ នាយករដ្ឋមន្ត្រី ហ៊ុន សែន បានយល់ព្រមរៀបចំការបោះឆ្នោតរយៈពេលមុន ៥ខែ នៅដើមខែ កុម្ភៈ ឆ្នាំ២០១៨។ គណបក្សប្រឆាំងបានប្រានចោលការលើកឡើងនេះដោយទាមទារឲ្យមានការបោះឆ្នោតនៅ ដើមឆ្នាំ២០១៥ ឬ ពាក់កណ្ដាលនៃឆ្នាំ ២០១៦។ នៅថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០១៤ វិបត្តិនយោបាយនេះបានបញ្ចប់ជាផ្លូវការហើយគណបក្សប្រឆាំងបានយល់ព្រមទទួលយកអាសនៈរបស់ពួកគេនៅក្នុងរដ្ឋសភា។ គេក៏បានឯកភាពគ្នាដែរថា ការបោះឆ្នោតលើកក្រោយនឹងត្រូវធ្វើនៅឆ្នាំ ២០១៨។

ទោះជាយ៉ាងណា លោក សម រង្ស៊ី ជាប្រធាន គណបក្សសង្គ្រោះជាតិត្រូវបានដកចេញពីអភ័យឯកសិទ្ធិសភាហើយ បន្ទាប់មកត្រូវបានហាមមិនឲ្យវិលត្រឡប់ចូលប្រទេសកម្ពុជាវិញបន្ទាប់ពីបានចាកចេញពីប្រទេស។ សំណើរសុំលើកលែងទោសពីព្រះមហាក្សត្រត្រូវបានលោក ហ៊ុន សែន រារាំងហើយនៅខែ ធ្នូ ឆ្នាំ ២០១៦ អនុប្រធាន លោក គឹម សុខា ត្រូវបានជំនួសលោក សម រង្ស៊ី ជាប្រធានភាគតិច។ នៅថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០១៧ លោក សម រង្ស៊ី បានលាលែងពីតំណែងប្រធានគណបក្សសង្គ្រោះជាតិហើយត្រូវបានលោក គឹម សុខា បន្តតំណែង។ នៅថ្ងៃទី ៣ ខែ កញ្ញា លោក គឹម សុខា ត្រូវបានចាប់ខ្លួននិងចោទពីបទក្បត់ជាតិដែលបានលើកនូវសំណួរអំពីអនាគតនៃគណបក្សសង្គ្រោះជាតិ។នៅថ្ងៃទី១៦ខែវិច្ឆិកា ឆ្នាំ ២០១៧ គណបក្សសង្គ្រោះជាតិត្រូវបានរំលាយដោយបង្ខំដោយលុបបំបាត់ការប្រកួតប្រជែងពិតប្រាកដចំពោះ គណបក្សប្រជាជនដែលកាន់អំណាច អាសនៈរបស់ គណបក្សដែលរំលាយក្នុងសភាត្រូវបានចែកឲ្យគណបក្សបីផ្សេងទៀត។

[29] ដកស្រង់ចេញពី ខុមហ្វ្រែល ប្រតិបត្តិអ្នកឃ្លាំមើល លេខ ៥០ ឆ្នាំទី១៦ ចេញផ្សាយពីថ្ងៃ២៥ ខែ មេសា ឆ្នាំ ២០១៤

### ខ. ដំណើរការនៃរដ្ឋសភា

សម័យប្រជុំសភាដំបូង និងសម័យប្រជុំសភាលើកទី១ នីតិកាលទី៥ ចាប់ផ្តើមដំណើរការដោយមិនមានវត្តមានតំណាងរាស្ត្របក្សប្រឆាំងហើយដោយមានការយាងចូលរួមរបស់ព្រះមហាក្សត្រជាព្រះរាជាធិបតី។ ព្រះមហាក្សត្រព្រះបាទសម្តេចព្រះបរមនាថនរោត្តម សីហមុនី ថតរូបជាមួយ អ្នកតំណាងរាស្ត្រគណបក្សប្រជាជនកម្ពុជានៅខាងមុខអាគាររដ្ឋសភាក្នុងរាជធានីភ្នំពេញកាលពីព្រឹកថ្ងៃទី ២៣ ខែ កញ្ញា ឆ្នាំ ២០១៣។

រដ្ឋសភាដែលមានសុទ្ធតែតំណាងរាស្ត្រគណបក្សប្រជាជនកម្ពុជាទាំង ៦៨ រូប នៅព្រឹកថ្ងៃទី ២៣ ខែ កញ្ញា បានពិភក្សាលើរបៀបវារៈពីរសំខាន់ គឺប្រកាសសុពលភាពរដ្ឋសភា និង អនុម័តបទបញ្ជាផ្ទៃក្នុងរដ្ឋសភា។ ប្រធានកិត្តិយសគណបក្សប្រជាជនកម្ពុជា និងជាអ្នកតំណាងរាស្ត្រជាប់ឆ្នោតមណ្ឌលកំពង់ចាមដែលមានវ័យចំណាស់ជាងគេ លោក ហេង សំរិន ត្រូវបានជ្រើសរើសជាព្រឹទ្ធសមាជិករដ្ឋសភាឲ្យឡើងថ្លែងសុន្ទរកថា ប្រកាសពីសុពលភាពនៃរដ្ឋសភានីតិកាលទី៥ នៅព្រឹកថ្ងៃទី ២៣ ខែ កញ្ញា។ លោក ហេង សំរិន បញ្ជាក់ជារួមថារដ្ឋសភាមានសមាជិកចំនួន ១២៣ រូប ក្នុងនោះ ៦៨ រូប មកពីគណបក្សប្រជាជនកម្ពុជានិង ៥៥ រូប ជាសមាជិកមកពីគណបក្សសង្គ្រោះជាតិ។ សមាជិកសភាគណបក្សប្រជាជនកម្ពុជាលោក ជាម យៀប មានប្រសាន៍ថាដំណើរការប្រជុំសភាជាលើកដំបូងក្នុងនីតិកាលទី៥ នេះ ប្រព្រឹត្តទៅដោយរលូនតាមច្បាប់ដោយមានការចូលរួមពីគ្រប់ស្ថានទូតអន្តរជាតិប្រចាំកម្ពុជាព្រមទាំងក្រោមព្រះរាជាធិបតីអង្គព្រះមហាក្សត្រ។ លោកបន្តថា ទោះបីសមាជិកសភាទាំង ៥៥ រូប របស់គណបក្សសង្គ្រោះជាតិមិនចូលរួមប្រជុំក្តីក៏កិច្ចប្រជុំសភាលើកដំបូងនេះ បានអនុម័តរួចហើយថា គណបក្សប្រឆាំងមានសមាជិកចំនួន ៥៥ រូបជាអ្នកតំណាងរាស្ត្រ ប៉ុន្តែអ្នកទាំងនោះត្រូវចូលស្បថនៅព្រះរាជវាំងជាមុនសិនដើម្បីបានទទួលអភ័យឯកសិទ្ធិសមាជិកសភា។ លោកក៏បញ្ជាក់ថា គណបក្សប្រជាជននៅតែបើកផ្លូវចរចារជាមួយគណបក្សប្រឆាំងក្នុងការរៀបចំក្បាលម៉ាស៊ីនដឹកនាំរដ្ឋសភាតែ បក្សប្រឆាំងមិនអាចចូលកាន់តំណែងក្នុងជួររដ្ឋាភិបាលបានទេ។ យ៉ាងណាមិញគណបក្សសង្គ្រោះជាតិដែលប្រមូលថ្នាក់ដឹកនាំទាំងអស់ទៅស្នាក់នៅខេត្តសៀមរាបដើម្បីធ្វើពហិការមិនចូលរួមសម័យប្រជុំសភាដំបូងនិងសម័យប្រជុំលើកទី១នាព្រឹកថ្ងៃទី២៣ ខែកញ្ញាបានចេញសេចក្តីថ្លែងការណ៍មួយបញ្ជាក់ថាខ្មែរទាំងមូលទេតែជាសភាឯកបក្ស និងផ្ទុយទៅនិងគោលការណ៍ប្រជាធិបតេយ្យ។ កិច្ចប្រជុំសភាជាលើកដំបូងសម្រាប់នីតិកាលទី៥ នេះប្រព្រឹត្តទៅដោយមានការចូលរួមពីមន្ត្រីអង្គទូតអន្តរជាតិនានាដូចជាតំណាងទូតសហភាពអឺរ៉ុបអគ្គរដ្ឋទូតសហរដ្ឋអាមេរិក អគ្គរដ្ឋទូតចិន អគ្គរដ្ឋទូត និងរដ្ឋទូតពីប្រទេសតំបន់អាស៊ាននិងប្រទេសជាច្រើនទៀត។ នៅរសៀលថ្ងៃទី ២៣ ខែ កញ្ញា សមាជិកសភារបស់គណបក្សប្រជាជនកម្ពុជាទាំង ៦៨ រូប ចូលរួមស្បថចំពោះមុខវត្ថុស័ក្តិសិទ្ធិប្តេជ្ញាបម្រើជាតិដើម្បីទទួលបានអភ័យឯកសិទ្ធិសភាសម្រាប់នីតិកាលទី៥។ សមាជិកសភាទាំងអស់នឹងចូលរួមបោះឆ្នោតជាកញ្ចប់ជ្រើសតាំងថ្នាក់ដឹកនាំរដ្ឋសភានិងជ្រើសតាំងគណៈរដ្ឋមន្ត្រីនៅថ្ងៃទី ២៤ ខែ កញ្ញា។

គណបក្សប្រឆាំងបានចាត់ទុកការប្រជុំសភាដែលចូលរួមតែពីខាងគណបក្សប្រជាជនកម្ពុជានោះ ថាជាសភាខុសច្បាប់បើទោះជាព្រះមហាក្សត្រយាងទៅបើកកិច្ចប្រជុំសភាលើកដំបូងក៏ដោយ។ មន្ត្រីជាន់ខ្ពស់គណបក្សប្រឆាំង ដែលពេលនេះកំពុងនៅខេត្តសៀមរាបថែមទាំងបានអះអាងថា បេក្ខជនតំណាងរាស្ត្រជាប់ឆ្នោតរបស់ខ្លួនមិនអាចក្បត់ឆន្ទះប្រជារាស្ត្រដើម្បីទៅចូលប្រជុំនេះឡើយ។ មន្ត្រីជាន់ខ្ពស់គណបក្សសង្គ្រោះជាតិបានប្រកាសថា គណបក្សប្រជាជនកម្ពុជាបានរំលោយកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីសនិងបានចាត់ទុកការបង្កើតសភាថ្មីថា ជាសភាខុសច្បាប់។

លោក សម រង្ស៊ី ជាប្រធានគណបក្សសង្គ្រោះជាតិមានប្រសាសន៍នៅក្នុងវត្តមុនីសុវណ្ណ ហៅថា វត្តគង់ម៉ុចនៅខេត្តសៀមរាប ក្រុងសៀមរាប ថាបេក្ខជនតំណាងរាស្ត្រគណបក្សសង្គ្រោះជាតិនៅតែគិតពីផលប្រយោជន៍ប្រជាពលរដ្ឋជាម្ចាស់ឆ្នោតជាធំមិនអាចទៅចូលរួមប្រជុំសភាលើកដំបូងបាននោះឡើយ។ ដូច្នេះ លោក សម រង្ស៊ី នៅបន្ទាប់ពីលោកបានដាក់បិណ្ឌនៅវត្ត គង់ ម៉ុច ជាមួយនិង លោក កឹម សុខា ជាអនុប្រធានគណបក្សព្រមទាំងបេក្ខជនតំណាងរាស្ត្រជាប់ឆ្នោតមួយចំនួនទៀត។ លោក សម រង្ស៊ី បានប្តេជ្ញាចិត្តថាគណបក្សសង្គ្រោះជាតិ នឹងរកយុត្តិធម៌ជូនប្រជាពលរដ្ឋឲ្យខានតែបាន។

ការបញ្ចេញប្រតិកម្មរបស់ប្រធានគណបក្សសង្គ្រោះជាតិនេះ ធ្វើឡើងភ្លាមៗបន្ទាប់ពីព្រះមហាក្សត្រសម្តេច ព្រះបរមនាថ នរោត្តម សហមុនី បានយាងទៅបើកសម័យប្រជុំរដ្ឋសភាដំបូងនៅព្រឹកថ្ងៃទី ២៣ ខែ កញ្ញា ទៅតាមការគ្រោងទុកទោះបីជាអង្គការសង្គមស៊ីវិល និងគណបក្សប្រឆាំងព្រមទាំងប្រជាពលរដ្ឋជិត ៣ សែននាក់បានផ្តិតមេដៃ និងធ្វើញត្តិថ្វាយព្រះអង្គសុំពន្យាពេលក្តី។ ព្រះមហាក្សត្រសម្តេចព្រះនរោត្តម សីហមុនី ព្រះអង្គមានព្រះរាជបន្ទូលនៅក្នុងព្រះរាជពិធីបើកអង្គប្រជុំសភាលើកដំបូងនៅថ្ងៃទី ២៣ ខែ កញ្ញា ថាព្រះអង្គចង់ឲ្យប្រជាជាតិកម្ពុជាមានសាមគ្គីភាពខ្ពស់ឈរលើមូលដ្ឋានយុត្តធម៌សង្គម និងនីតិរដ្ឋ។ ក្រុមប្រជាពលរដ្ឋមួយចំនួននៅខេត្តសៀមរាបបានបញ្ចេញប្រតិកម្មភ្លាមៗបន្ទាប់ពីកិច្ចប្រជុំសភាដំបូងបានបញ្ចប់។ ប្រជាពលរដ្ឋទាំងនោះបានស្រែកពាក្យថា អយុត្តិធម៌ៗចំពោះការបើកប្រជុំសភាលើកដំបូងដោយមិនទាន់បានរកយុត្តិធម៌លទ្ធផលឆ្នោតជូនប្រជាពលរដ្ឋនៅឡើយ។លោកកឹមសុខាជាអនុប្រធានគណបក្សសង្គ្រោះជាតិមានប្រសាសន៍ថាបេក្ខជនតំណាងរាស្ត្រជាប់ឆ្នោតគណបក្សសង្គ្រោះជាតិមិនចូលប្រជុំនេះ មិនមែនគណបក្សសង្គ្រោះជាតិមិនគោរពព្រះមហាក្សត្រនោះទេ ប៉ុន្តែបញ្ជាចម្បងគណបក្សសង្គ្រោះជាតិមិនអាចក្បត់ឆន្ទៈប្រជាពលរដ្ឋនោះទេ។

**គ. ការបង្កើតរាជរដ្ឋាភិបាល**

ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៥ របស់គណកម្មាធិការរៀបចំការបោះឆ្នោត (គ.ជ.ប) កាលពីថ្ងៃទី០៨ ខែកញ្ញា ឆ្នាំ២០១៣ បានបង្ហាញថាគណបក្សប្រជាជនកម្ពុជាគឺជាគណបក្សទទួលបានបេក្ខជនជាប់ឆ្នោតចំនួន ៦៨ នាក់នៃ១២៣ អាសនៈនៃរដ្ឋសភា។

រាជរដ្ឋាភិបាលនៃប្រទេសកម្ពុជា អង្គនីតិប្រតិបត្តិ ត្រូវបានបង្កើតឡើងសម្រាប់អាណត្តិទី៥ ឆ្នាំ ២០១៣ តាមរយៈការបោះឆ្នោតជាសកល និងដោយផ្ទាល់។ តាមការស្នើសុំរបស់ប្រធានរដ្ឋសភា និងដោយមានការយល់ព្រមពីអនុប្រធានទាំងពីរព្រះមហាក្សត្រ ក្នុងនាមជាព្រះប្រមុខរដ្ឋតែងតាំងតស្សរជនជាន់ខ្ពស់មួយរូបដែលជាសមាជិកគណបក្សនយោបាយឈ្នះឆ្នោតឲ្យបង្កើតគណៈរដ្ឋមន្ត្រី។ ក្រោយពីការបោះឆ្នោតជាតិឆ្នាំ ២០១៣ រាជរដ្ឋាភិបាលអាណត្តិទី៥ ត្រូវបានបង្កើតឡើង។

**ឃ. ក្រសួង និងស្ថាប័ននានា**

សមាជិករាជរដ្ឋាភិបាលស្ទើតែទាំងអស់ គឺជាប្រធានក្រសួង និងស្ថាប័នជាតិ។ ក្នុងគោលបំណងរក្សាឯករាជ្យភាពរបស់ស្ថាប័នទាំងនេះពីរាជរដ្ឋាភិបាល ប្រធាននិងសមាជិកស្ថាប័នជាតិខ្លះ មិនមែនជាសមាជិករាជរដ្ឋាភិបាលទេ។ ស្ថាប័នជាតិទាំងនេះ មិនមែនជាផ្នែកនៃអង្គនីតិប្រតិបត្តិ អង្គនីតិប្បញ្ញត្តិ និងអង្គតុលាការទេ ប៉ុន្តែជាស្ថាប័នជាតិឯករាជ្យដោយឡែក។ កំណែទម្រង់គួរកត់សម្គាល់ ដែលកើតឡើងជាមួយនឹងស្ថាប័នជាតិភាគច្រើន កើតឡើងភ្លាមៗ នៅក្រោយពីការបោះឆ្នោតជាតិឆ្នាំ ២០១៣។ ស្ថាប័នជាតិទាំងនោះលែងដាក់ឲ្យស្ថិតនៅក្រោមទីស្តីការគណៈរដ្ឋមន្ត្រីហើយ ប៉ុន្តែនៅក្រោមក្រសួងទទួលបន្ទុកនៃរាជរដ្ឋាភិបាល។ កំណែទម្រង់នេះ មានគោលដៅរៀបចំ និងដាក់បញ្ចូលស្ថាប័នជាតិទទួលបន្ទុកតាមវិស័យទាំងនោះក្នុងរចនាសម្ព័ន្ធនៃក្រសួងជាប់ពាក់ព័ន្ធ។ សព្វថ្ងៃនេះ រាជរដ្ឋាភិបាលនៃប្រទេសកម្ពុជា មានក្រសួង និងរដ្ឋលេខាធិការដ្ឋាន មានចំនួនសរុប ២៨ ព្រមទាំងស្ថាប័នជាតិមួយចំនួនផ្សេងទៀត មានដូចខាងក្រោម៖

| | | |
|---|---|---|
| ១. នាយករដ្ឋមន្ត្រី | = | ១ រូប សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន |
| ២. ឧបនាយករដ្ឋមន្ត្រី | = | ៣ រូប |
| ៣. ទេសរដ្ឋមន្ត្រី | = | ៧ រូប (មានក្រសួង ២៨ រូប)។ |

**ផ្នែកទី៦ ការបង្កើតរាជរដ្ឋាភិបាលតាមអាណត្តិសភា២០១៨-២០២៣**

ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៦ ប្រព្រឹត្តទៅនៅថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០១៨ ដោយមានគណបក្សនយោបាយចូលរួមចំនួន ២០ដើម្បីប្រជែងយកអាសនៈសភាចំនួន១២៥ក្នុង ២៥មណ្ឌល។ រដ្ឋសភានីតិកាលទី៦ ត្រូវបានបង្កើតឡើងជាផ្លូវការហើយ នៅថ្ងៃព្រហស្បតិ៍ តាមរយៈការបោះឆ្នោតជាកញ្ចប់។ លោក ហេង សំរិន ត្រូវបានជ្រើសតាំងជាប្រធាន ឲ្យបន្តដឹកនាំរដ្ឋសភានីតិកាលទី៦ អមដោយអនុប្រធានពីររូប គឺ លោក ងួន ញ៉ិល ជាអនុប្រធាន ទី១ និងលោកស្រី ឃួន សុដារី ជាអនុប្រធានទី២។ ក្រៅពីក្បាលដឹកនាំរដ្ឋសភា សម័យប្រជុំពេញអង្គក៏បានបោះឆ្នោតអនុម័តលើសមាសភាពគណៈកម្មការជំនាញទាំង ១០ នៃរដ្ឋសភាផងដែរ។

**ក. ការបង្កើតរដ្ឋសភា**

រដ្ឋសភានីតិកាលទី ៦ កើតចេញពីបោះឆ្នោតសកលកាលពីថ្ងៃទី ២៩ ខែ កក្កដា ឆ្នាំ២០១៨ តាមប្រព័ន្ធសមាមាត្រមាន ២៥ មណ្ឌលរាជធានី-ខេត្ត មានគណបក្សនយោបាយចំនួន ២០ ចូលរួម។ ប្រជាពលរដ្ឋបានចុះឈ្មោះបោះឆ្នោតចំនួន ៨.៣៨០.២១៧ នាក់ ប្រជាជនកម្ពុជា ១២៥ អាសនៈ ស្មើនិង ១០០%។ តំណាងរាស្ត្រសរុបចំនួន ១២៥ រូប ក្នុងនោះតំណាងរាស្ត្រ ស្ត្រី ២៥ រូប ស្មើនិង ២០% តំណាងរាស្ត្រជនជាតិភាគតិចចំនួន ៧ រូប ក្រុមសមាជិកសភាកម្ពុជានៃអ្នកនយោបាយស្ត្រី ត្រូវបង្កើត។ បានបើកសម័យប្រជុំដំបូង ក្រោមព្រះរាជាធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ព្រះករុណាព្រះបាទសម្តេច បរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជានៅថ្ងៃ ពុធ ទី ៥ ខែ កញ្ញា ឆ្នាំ ២០១៨។

តំណាងរាស្ត្រ បានធ្វើសច្ចាប្រណិធាននៅព្រះបរមរាជវាំងមុនចូលកាន់តំណែងនៅរសៀលថ្ងៃដដែល។ រដ្ឋសភា បានប្រជុំក្រោមអធិបតីភាពសម្តេចអគ្គមហាពញាចក្រី ហេង សំរិន ព្រឹទ្ធសភា សមាជិករដ្ឋសភាដើម្បីបោះឆ្នោតជ្រើសតាំងប្រធាន អនុប្រធានរដ្ឋសភា ប្រធាន អនុប្រធានគណៈកម្មាការជំនាញ និងផ្តល់សេចក្តីទុកចិត្តរាជរដ្ឋាភិបាលនៅថ្ងៃទី ៦ ខែ កញ្ញា ឆ្នាំ ២០១៨[30]។

**ខ. ដំណើរការនៃរដ្ឋសភា**

នៅពេលមានបើកសម័យប្រជុំលើកទី១ នៃនីតិកាលនីមួយៗរដ្ឋសភាត្រូវចាប់ដំណើរការក្រោមអធិបតីភាពប្រធានបណ្តោះអាសន្នមួយរូបដែលជាបេក្ខជនជាប់ឆ្នោតមានអាយុច្រើនជាងគេដែលមានវត្តមាន ហើយមានសមាជិកប្រាំរូប ដែលជាបេក្ខជនជាប់ឆ្នោតមានអាយុតិចជាងគេដែលមានវត្តមានជាលេខាធិការដើម្បីជួយប្រធានក្នុងការងារ។

ក្នុងករណី ដែលស្ថានភាពនយោបាយតម្រូវឲ្យអនុវត្តតាមច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិក្រោមការដឹកនាំរបស់ព្រឹទ្ធសមាជិករដ្ឋសភាខាងលើនេះ ប្រសិនបើមានកូរ៉ុមលើសពីពាក់កណ្តាលនៃចំនួនសមាជិករដ្ឋសភាទាំងមូលរដ្ឋសភាត្រូវចាប់ផ្តើមធ្វើការតាមរបៀបវារៈដូចតទៅៈ

១. សម្រេចអំពីសុពលភាពនៃអាណត្តិរបស់សមាជិកនីមួយៗ។

២. បោះឆ្នោតជាកញ្ចប់ដើម្បីជ្រើសតាំងប្រធាន អនុប្រធាន រដ្ឋសភា ប្រធាន អនុប្រធានគណៈកម្មាការជំនាញទាំងអស់នៃរដ្ឋសភា នឹងផ្តល់សេចក្តីទុកចិត្តចំពោះរាជរដ្ឋាភិបាលនៅដើមនីតិកាលនីមួយៗដោយវិធីលើកដៃនឹងដោយសម្លេងភាគច្រើនដាច់ខាតនៃសមាជិករដ្ឋសភាទាំងមូល។ មិនអាចជជែកពិភាក្សា អ្វីឡើយនៅ

[30] ដកស្រង់ចេញពី សារតារដ្ឋសភា រៀបរៀងដោយ NA001 (កាលពី៣/២៥/២០១៣ ៥:២១:០២PM)

ក្រោមអធិបតីភាពរបស់ព្រឹទ្ធសមាជិក។តំណាងរាស្ត្រទាំងអស់ត្រូវធ្វើសច្ចាប្រណិធានមុនពេលចូលកាន់តំណែងដូចមានខ្លឹមសារចែងក្នុងឧបសម្ព័ន្ធទី៥ នៃរដ្ឋធម្មនុញ្ញ។

**គ. ការបង្កើតរាជរដ្ឋាភិបាល**

ក្នុងករណី មាត្រា ៨២ និងមាត្រា ១១៩ ថ្មី នៃរដ្ឋធម្មនុញ្ញមិនអាចអនុវត្តទៅបានដូចនេះរដ្ឋសភាត្រូវអនុវត្តទៅតាមនីតិវិធីច្បាប់ធម្មនុញ្ញបន្ថែមតាមសំណើររបស់គណបក្សនយោបាយ ដែលមានអាសនៈនៅក្នុងរដ្ឋសភាច្រើនជាងគេ ឬ មានតំណាងរាស្ត្រច្រើនជាងគេនៅក្នុងរដ្ឋសភា អាចដំណើរការបោះឆ្នោតជាកញ្ចប់ដើម្បីជ្រើសតាំងប្រធាន និងអនុប្រធានទី១ និងទី២ នៃរដ្ឋសភា ក៏ដូចជាប្រធាន អនុប្រធាន និងលេខាធិការនៃគណៈកម្មការនានារបស់រដ្ឋសភា ក្នុងពេលជាមួយគ្នា និងការបោះឆ្នោតផ្តល់សេចក្តីទុកចិត្តចំពោះការបង្កើតរាជរដ្ឋាភិបាល[31]។

**ឃ. ក្រសួង និងស្ថាប័ននានា**

រដ្ឋសភានីតិកាលទី ៦ តាមព្រះរាជត្រាស់បង្គាប់ ព្រះករុណាព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជានោះ លោក សាយ ឈុំ ប្រមុខស្តីទី បានតែងតាំងទីប្រឹក្សារាជរដ្ឋាភិបាលចំនួន ២០៧ រូប តាមព្រះរាជក្រឹត្យចុះថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ២០១៨។ ទីប្រឹក្សារាជរដ្ឋាភិបាលចំនួន ២០៧ រូប ដែលប្រមុខរដ្ឋស្តីទី បានតែងតាំង។ នាយករដ្ឋមន្ត្រី សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន។ ប្រទេសកម្ពុជាមាន ឧបនាយករដ្ឋមន្ត្រីទាំងអស់សរុបចំនួន ១០ រូប។ មានទេសរដ្ឋមន្ត្រី ១៧ រូប ទទួលបន្ទុកបេសកម្មពិសេស។ រដ្ឋមន្ត្រី រួមមានដូចជា៖

- ឯកឧត្តម កិត្តិនីតិកោសលបណ្ឌិត ប៊ិន ឈិន រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី
- សម្តេចក្រឡាហោម ស ខេង រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ
- សម្តេចពិជ័យសេនា ទៀ បាញ់ រដ្ឋមន្ត្រីក្រសួងការពារជាតិ
- ឯកឧត្តម ប្រាក់ សុខុន រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

[31] ដកស្រង់ចេញពី សៀវភៅ ស្ថាប័ននយោបាយ ព្រះរាជាណាចក្រកម្ពុជា សាស្ត្រាចារ្យ ដុំ អ៊ីម បោះពុម្ពលើកទី១ ទំព័រ ១៥៥,១៥៦,១៥៧

# ផ្នែកទី៧ បញ្ហាប្រឈម និងដំណោះស្រាយ

## ៧.១ បញ្ហាប្រឈមមុខនៅពេលបង្កើតរាជរដ្ឋាភិបាល

តាមការសិក្សាពីប្រវត្តិសាស្ត្រ កន្លងមកទាក់ទងនិងរាជរដ្ឋាភិបាលប្រទេសកម្ពុជាយើងសង្កេតឃើញថា រដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣កន្លងមកកើតមានការបោះឆ្នោតជាច្រើនដំណាក់កាលនៅក្នុងការបោះឆ្នោតជ្រើសរើស ប្រធាន និងអនុប្រធានរដ្ឋសភា ក៏ដូចជាជ្រើសរើស នាយករដ្ឋមន្ត្រី ត្រូវការសម្លេងគាំទ្រ ២/៣ ទើបអាចជ្រើសតាំង បាន។ ដោយសារគណបក្សហ៊្វុនស៊ិនប៉ិច និង គណបក្ស សម រង្ស៊ី បានបង្កើតសម្ព័ន្ធភាពអ្នកប្រជាធិបតេយ្យ ដែលមិនព្រមឲ្យគណបក្សណាមួយចូលជាមួយគណបក្សប្រជាជនដើម្បីបង្កើតរដ្ឋាភិបាលបាន (បើចូល ចូល ទាំងអស់គ្នា បើចេញ ចេញទាំងអស់គ្នា) ស្ថានភាពនយោបាយក៏ត្រូវបានកកស្ទះ។

នៅថ្ងៃទី៥ ខែ វិច្ឆិកា ឆ្នាំ ២០០៣ ព្រះករុណាព្រះបាទសម្តេចនរោត្តមសីហនុ ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ស្តេចយាងធ្វើជាព្រះរាជាធិបតីភាព នៃកិច្ចប្រជុំកំពូលរបស់គណបក្សនយោបាយធំៗទាំងបី រួម មានឥស្សរជនជាន់ខ្ពស់ដឹកនាំគណបក្សចូលរួម៖ គណបក្សប្រជាជន មានសម្តេច ជា ស៊ីម ជាប្រធាន សម្តេច ហ៊ុន សែន លោក ស ខេង លោក សាយ ឈុំ លោក ទៀ បាញ់ លោក សុខ អាន លោក ទេព ងន លោក ប្រាក់ សុខុន លោក ឱម យិនទៀង និង លោក ម៉ប់ សារិន ជាលេខាកត់ត្រាកិច្ចប្រជុំសម្រាប់គណបក្សប្រជាជនកម្ពុជា។ គណបក្សហ៊្វុនស៊ិនប៉ិច មានសម្តេច ក្រុមព្រះនរោត្តម រណឫទ្ធិ ជាប្រធាន សម្តេច ក្រុមឃុននរោត្តម សិរិវុឌ្ឍ លោក កុល ផេង លោក ស៊ុន ចាន់ថុល និង លោក គង់ វិបុល ជាអ្នកកត់ត្រារបស់គណបក្ស។

គណបក្សសម រង្ស៊ី លោក សម រង្ស៊ី ជាប្រធានគណបក្ស លោក អេង ឆៃអ៊ាង លោក អ៊ូ ប៊ុនឡុងលោក ស្រី ជូឡុង សូម៉ូរ៉ា និង លោក អ៊ឹង ប៊ុនអាង ជាអ្នកកត់ត្រាសម្រាប់គណបក្ស។ កិច្ចប្រជុំកំពូលក៏មានព្រះរាជ វត្តមានសម្តេចព្រះសុគន្ធាធិបតី ប៊ូ គ្រី សម្តេច ព្រះសង្ឃរាជគណៈធម្មយុត្តិនិកាយ សម្តេច ព្រះឧត្តមបញ្ញា ដួង ផង់ ព្រះរាជតំណាង សម្តេចព្រះសង្ឃរាជគណៈមហានិកាយយាងចូលនិមន្តជាព្រះរាជអធិបតីផងដែរ។ កិច្ចប្រជុំ កំពូលប្រព្រឹត្តធ្វើឡើងនៅក្នុងប្រាសាទសិរិមង្គលព្រះបរមរាជវាំង ដោយចាប់ផ្តើមពីម៉ោង ៨ ព្រឹករហូតដល់ម៉ោង ១៣។ លទ្ធផលនៃកិច្ចប្រជុំមានចេញសេចក្តីថ្លែងការរួមមួយមាន ៣ ចំណុច សំខាន់ៗ គឺទីមួយ ក្នុងការរៀបចំរដ្ឋ សភា គណបក្សប្រជាជនកម្ពុជា ថ្វាយនូវតំណែងព្រះប្រធានរដ្ឋសភាថ្វាយសម្តេចក្រុមព្រះនរោត្តម រណឫទ្ធិ និង អនុប្រធានពីររូបមកពីគណបក្សប្រជាជន។ ទីពីរ ការរៀបចំរាជរដ្ឋាភិបាលមាន ៣ គណបក្ស ហើយគណបក្ស ប្រជាជនស្នើតែងតាំង សម្តេច ហ៊ុន សែន ជាបេក្ខភាពនាយករដ្ឋមន្ត្រី។ ទីបី គណបក្សទាំងបី មានឯកភាពគ្នាធ្វើ

វិសោធនកម្មរដ្ឋធម្មនុញ្ញបង្កើតឲ្យតំណែងអនុប្រធានទី៣ នៃរដ្ឋសភា ដែលទទួលដោយគណបក្ស សម រង្ស៊ី។ ប៉ុន្តែខ្លឹមសារនៃសេចក្តីថ្លែងការណ៍នេះពុំបានបញ្ជាក់នូវគោលជំហរដាច់ណាត់របស់គណបក្សទាំងបី ទេ ដែលមួយថ្ងៃក្រោយមកខ្លឹមសារនៃជំនួបនេះ ហាក់ដូចត្រូវស្លាប់ទៅវិញ។ នៅថ្ងៃទី ៦ ខែ វិច្ឆិកា អ្នកនយោបាយនៃគណបក្ស ហ៊្វុនស៊ិនប៉ិច និង គណបក្ស សម រង្ស៊ី បានប្រកែកថា ខ្លួនពុំបានធានាចំពោះបេក្ខភាពនាយករដ្ឋមន្ត្រីរបស់សម្តេច ហ៊ុន សែន ទេដែលពេលនោះបានឲ្យការបង្កើតរាជរដ្ឋាភិបាលត្រូវបន្តជាប់គាំងតទៅទៀត[32]។ កម្ពុជាធ្លាប់មានប្រវត្តិសាស្ត្រជាប់គាំងផ្នែកនយោបាយ ក្រោយពីបោះឆ្នោតដែលមិនអាចបង្កើតរដ្ឋាភិបាលបានភ្លាមៗចំនួន ពីលើករួចមកហើយ គឺឆ្នាំ ១៩៩៣ និងឆ្នាំ ២០០៣ ហើយដោយសារតែបក្សចាញ់ឆ្នោតមិនទទួលយកលទ្ធផលបោះឆ្នោត។ ហើយភាពតានតឹងរវាងអ្នកនយោបាយនៅបក្សផ្សេងគ្នា បានវាយប្រហារពាក្យសម្តីដាក់គ្នាទៅវិញទៅមក រវាងប្រធានបក្សហ៊្វុនស៊ិនប៉ិច របស់សម្តេចក្រុមព្រះនរោត្តម រណឫទ្ធិ និងអនុប្រធានបក្សប្រជាជនលោក ហ៊ុន សែន។

នៅឆ្នាំ ២០១៣ នេះ អ្នកនយោបាយខ្មែរអាចនិងបង្កើតប្រវត្តិសាស្ត្ររបស់ខ្លួនលើកទី ៣ គឺការប្រកាសមិនទទួលស្គាល់លទ្ធផលរបស់គណបក្សប្រឆាំងក្រោយពេលបោះឆ្នោតដែលលទ្ធផលនេះ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតមិនទាន់បង្ហើបឲ្យដឹងអាសនៈនៅឡើយ។ គណបក្សសង្គ្រោះជាតិ ដែលជាគណបក្សប្រឆាំងធំជាងគេនោះបានប្រកាសមិនទទួលស្គាល់លទ្ធផលបោះឆ្នោតភ្លាមៗ។ ការប្រកាសរបស់គណបក្សនេះ ស្របគ្នានឹងអង្គការសង្គមស៊ីវិលមួយចំនួន ដែលធ្វើការឃ្លាំមើលការបោះឆ្នោត បានរកឃើញភាពមិនប្រក្រតីនៅថ្ងៃបោះឆ្នោតកាលពីថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ ២០១៣ មានរាប់រយករណី។ ការប្រកាសមិនទទួលស្គាល់លទ្ធផលរបស់គណបក្សប្រឆាំងដោយសារតែមន្ត្រីជាន់ខ្ពស់គណបក្សប្រជាជនកម្ពុជា អះអាងថា គណបក្សនេះឈ្នះឆ្នោត រីឯខាងគណបក្សសង្គ្រោះជាតិ អះអាងថា ខ្លួនឈ្នះឆ្នោតដែរ។ ប្រទេសកម្ពុជា ជាប្រទេសមួយដែលប្រកាន់យកនយោបាយប្រជាធិបតេយ្យសេរីពហុបក្ស។ ប្រជាពលរដ្ឋខ្មែរជាម្ចាស់វាសនានៃប្រទេសជាតិរបស់ខ្លួន ពោលគឺប្រជាពលរដ្ឋជាអ្នកជ្រើសរើសអ្នកដឹកនាំរបស់ខ្លួនតាមរយៈការបោះឆ្នោតជាសកល គឺការបោះឆ្នោតជ្រើសរើសសភាតំណាងរាស្ត្រ។

ក្រោយការបោះឆ្នោតជ្រើសរើសសភាតំណាងរាស្ត្រ យើងសង្កេតឃើញរដ្ឋាភិបាលមួយកើតឡើងតាមការទទួលសេចក្តីទុកចិត្តពីសភាតំណាងរាស្ត្រ (រដ្ឋសភា)។ មាត្រា១១៩ថ្មី នៃរដ្ឋធម្មនុញ្ញបានចែងថា តាមសេចក្តី

[32] ដកស្រង់ចេញពី សៀវភៅរដ្ឋាភិបាលកម្ពុជាពីឆ្នាំ ១៩៤៥ ដល់ឆ្នាំ ២០១០ បោះពុម្ពលើកទី២ ទំព័រ ២៣០-២៣១

ស្នើសុំពីប្រធានដោយមានមតិឯកភាពពីអនុប្រធានទាំងពីរ នៃរដ្ឋសភាព្រះមហាក្សត្រទ្រង់ចាត់តាំងរូបជនមួយរូប ក្នុងចំណោមតំណាងរាស្ត្រនៃគណបក្សដែលឈ្នះឆ្នោតឲ្យបង្កើតរដ្ឋាភិបាល។

## ៧.២ ដំណោះស្រាយតាមផ្លូវច្បាប់

នៅរាជរដ្ឋាភិបាលអាណត្តិទីមួយ នេះ គឺរាជរដ្ឋាភិបាលបង្កើតឡើងដោយសារការសម្រុះសម្រួលផ្នែកនយោបាយរវាងគណៈបក្សនយោបាយធំៗពីរ គណបក្សប្រជាជនកម្ពុជា និងគណៈបក្សហ៊្វុនស៊ិនប៉ិច ដែលកាលនោះគណបក្សហ៊្វុនស៊ិនប៉ិច ជាអ្នកឈ្នះឆ្នោត។ ព្រះករុណាព្រះបាទសម្តេច ព្រះនរោត្តមសីហនុ ព្រះអង្គបានឃើញយល់ថា ដើម្បីបញ្ចប់វិបត្តិនយោបាយ និងការបែកបាក់ជាតិជាថ្មីម្តងទៀតនោះ ព្រះអង្គបានស្នើឲ្យមានរូបមន្តរដ្ឋាភិបាលក្បាលពីរដែលមាននាយករដ្ឋមន្ត្រី ២ រូប គឺ នាយករដ្ឋមន្ត្រីទី១ សម្តេចក្រុមព្រះ នរោត្តម រណឫទ្ធិ ប្រធាន គណបក្សហ៊្វុនស៊ិនប៉ិច និង នាយករដ្ឋមន្ត្រីទី ២ គឺ សម្តេច ហ៊ុន សែន ជាអនុប្រធាន គណបក្សប្រជាជនកម្ពុជា។ ព្រះរាជសកម្មភាពរបស់ព្រះមហាក្សត្រក្នុងដំណោះស្រាយនយោបាយ ព្រះមហាក្សត្រសម្តេចព្រះបរមនាថ នរោត្តមសីហមុនី នៅថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០១៣ ព្រះអង្គបានផ្ញើព្រះរាជសារកោះអញ្ជើញប្រជុំជូនសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន ជាអនុប្រធាន គណបក្សប្រជាជនកម្ពុជា និង ឯកឧត្តម សម រង្ស៊ី ជាប្រធានគណបក្សសង្គ្រោះជាតិរួមទាំងសហការីម្នាងៗចំនួន ២ រូប ឲ្យចូលរួមប្រជុំក្រោមអធិបតីភាពរបស់ព្រះអង្គដើម្បីដោះស្រាយបញ្ហាប្រទេសជាតិវេលាម៉ោង ៩ ព្រឹកថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ២០១៣ នៅព្រះបរមរាជវាំង។ ការកំណត់នៅវេលាម៉ោង ៩ ព្រឹក នាថ្ងៃទី ១៤ ខែកញ្ញា ឆ្នាំ២០១៣ ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជាទ្រង់បានគង់ជាអធិបតីភាពក្នុងជំនួបប្រជុំថ្នាក់ដឹកនាំ នៃគណបក្សជាប់ឆ្នោតទាំងពីរ ដែលមានសម្តេចអគ្គមហាសេនាបតីតេជោហ៊ុន សែន រួមទាំងសហការី២ រូប ដែលរួមមានឯកឧត្តម សាយ ឈុំ និង ឯកឧត្តម ស ខេង ដែលបានតំណាងគណបក្សប្រជាជនកម្ពុជា និងវត្តមានរបស់ ឯកឧត្តម សម រង្ស៊ី រួមទាំងសហការី ២ រូប ដែលរួមមាន ឯកឧត្តម កឹម សុខា និង ឯកឧត្តម គួយ ប៊ុនរឿង ជាតំណាងគណបក្សសង្គ្រោះជាតិ។ នៅក្នុងស្ថានភាពពេលនោះ ព្រះអង្គបានថ្លែងព្រះរាជសន្ទរកថាក្នុងអត្ថន័យនិងរាជបំណាងឲ្យគណបក្សទាំងពីររួមគ្នាដើម្បីដោះស្រាយវិវាទនយោបាយ ដោយសន្តិវិធីក្នុងគុណប្រយោជន៍សម្រាប់ជាតិទាំងមូល[33]។

[33] ដកស្រង់ចេញពី សៀវភៅ ដំណើរការប្រព្រឹត្តទៅរបស់រដ្ឋសភានីតិកាលទី៤ តាក់តែងឡើងដោយ និស្សិតឈ្មោះ កែវ ឈនរីជូ ឆ្នាំសរសេររបាយការណ៍ ២០១២ ទំព័រ ៤០-៤១

មួយវិញទៀត នៅថ្ងៃទី១២ ខែ កក្កដា ឆ្នាំ ២០០៤ សភាបានបើកសម័យប្រជុំពេញអង្គ ដើម្បីពិភាក្សា និង អនុម័តលើសេចក្តីស្នើច្បាប់ធម្មនុញ្ញបន្ថែម។ សម័យប្រជុំនេះបានអនុម័តយល់ព្រមក្នុងសម្លេង ៤៨ លើ ៤៩ គាំទ្រចំពោះសេចក្តីស្នើច្បាប់ធម្មនុញ្ញបន្ថែមនេះ ហើយនៅថ្ងៃ ១៣ ខែ សីហា សេចក្តីស្នើច្បាប់ធម្មនុញ្ញបន្ថែម ត្រូវបានប្រកាសឲ្យប្រើដោយព្រះរាជក្រមក្នុងព្រះបរមនាមព្រះករុណាព្រះមហាក្សត្រ[34]។ នៅថ្ងៃទី ១៣ ខែ កុម្ភៈ លោក សម រង្ស៊ី បានស្នើនូវរូបមន្ត ៥០%+១ ដើម្បីបោះឆ្នោតសម្តែងការទុកចិត្ត ក្នុងការបង្កើតរដ្ឋាភិបាលថ្មី។ នៅថ្ងៃដដែលនោះការិយាល័យអ្នកនាំពាក្យគណបក្សប្រជាជនបានចេញសេចក្តីប្រកាសព័ត៌មានស្វាគមន៍សេចក្តីស្នើរបស់គណបក្ស សម រង្ស៊ី រីឯគណបក្សហ៊្វុនស៊ិនប៉ិចវិញបានចេញសេចក្តីថ្លែងការណ៍មួយថ្ងៃក្រោយ។

ព្រះអង្គម្ចាស់ នរោត្តម រណឫទ្ធិ ក៏បានបញ្ចេញយោបល់ផងដែរថា ព្រះអង្គគាំទ្រការបោះឆ្នោតឯកត្តនាមជាជាងសមាមាត្រ។ ថ្ងៃទី២ ខែមីនា ឆ្នាំ២០០៦ រដ្ឋសភាបានអនុម័តដើម្បីប្តូររូបមន្តសម្លេងអនុម័តពី ២/៣ មក ៥០%+១ វិញធ្វើឲ្យអំណាចរដ្ឋាភិបាលព្រឹទ្ធសភា រដ្ឋសភាធ្លាក់ក្នុងដៃគណបក្សប្រជាជនកម្ពុជាទាំងស្រុង[35]។

---

[34] ដកស្រង់ចេញពីសៀវភៅ រដ្ឋាភិបាលកម្ពុជា ពីឆ្នាំ ១៩៤៥ ដល់ឆ្នាំ ២០១០ បោះពុម្ពលើកទី២ របបសេរីពហុបក្សនាយករដ្ឋមន្ត្រី១ ទំព័រ ២៣៧

[35] ដកស្រង់ចេញពីសៀវភៅ រដ្ឋាភិបាលកម្ពុជា ពីឆ្នាំ ១៩៤៥ ដល់ឆ្នាំ ២០១០ បោះពុម្ពលើកទី២ របបសេរីពហុបក្សនាយករដ្ឋមន្ត្រី១ ទំព័រ ២៤២

# សេចក្តីសន្និដ្ឋាន

# សេចក្តីសន្និដ្ឋាន

នៅក្នុងការសិក្សា និងបទពិសោធន៍កន្លងមកដែលធ្លាប់ជួបប្រទះបញ្ជាក់ឲ្យឃើញថា គឺវាមានភាពខុសគ្នានិង ដូចគ្នាទៅតាមការប្រែប្រួលនូវស្ថានភាពជាក់ស្តែងនៅក្នុងសង្គមខ្មែរយើងទាំងស្រុងបើយើងក្រឡេកទៅមើលពីអតីតកាលតាំងពីឆ្នាំ ១៩៤៧ មកប្រទេសជាតិមានការផ្លាស់ប្តូរ របបនយោបាយទៅតាមដំណាក់កាលនីមួយៗ ជាហូរហែនិងមានសោកនាកម្មយ៉ាងព្រៃផ្សៃបំផុតនៅក្នុងសង្គមខ្មែរ នាសម័យនោះប្រជាពលរដ្ឋរស់នៅយ៉ាងពិបាកទាំងការហូបចុក ការស្នាក់នៅ ទីជម្រក ការអត់ឃ្លាន និងជួបវិបត្តិបញ្ហាសង្គ្រាមស៊ីវិលនៅក្នុងស្រុកថែមទៀតផងដែលធ្វើឲ្យមានការបាត់បង់នូវអាយុជីវិតប្រជាពលរដ្ឋខ្មែរយើងអស់រាប់លាននាក់ ដែលធ្វើឲ្យភាពឈឺចាប់ខ្លោចផ្សារនៅដក់ជាប់ក្នុងចិត្ត គ្មានថ្ងៃអាចបំភ្លេចបាននូវភាពឈឺចាប់កន្លងមក។ ជាមួយគ្នានោះដែលឈានមកដល់ឆ្នាំ ១៩៩៣ ដល់បច្ចុប្បន្ននេះប្រទេសជាតិមានការផ្លាស់ប្តូរនូវរបបនយោបាយដូចគ្នាតែមានភាពខុសគ្នាទៅតាមការដឹកនាំផងដែរ។ ដោយសារប្រទេសកម្ពុជា គឺជាព្រះរាជាណាចក្រដែលព្រះមហាក្សត្រទ្រង់ប្រតិបត្តិតាមរដ្ឋធម្មនុញ្ញនិងតាមលទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស។ ដូចនេះ ការផ្លាស់ប្តូរពីរបបមួយអាស្រ័យទៅតាមការបោះឆ្នោតក្នុងការជ្រើសរើសមេដឹកនាំដែលល្អសម្រាប់គ្រប់គ្រងប្រទេសប្រកបដោយសមត្ថភាព ម៉ឺងម៉ាត់មានកាយសម្បទាស្វាហាប់ថែមទាំងមានចំណេះដឹងខ្ពង់ខ្ពស់ ដែលអាចធ្វើជាថ្នាក់ដឹកនាំមួយរូប ដែលមានប្រជាប្រិយ៍ភាពមានសមានចិត្តល្អ និង ដឹកនាំប្រទេសជាតិប្រកបដោយសន្តិភាពមិនមានភាពអនាធិបតេយ្យអសន្តិសុខនៅក្នុងសង្គម ដែលប្រជាពលរដ្ឋរស់នៅពួកគាត់គ្មានភាពភ័យខ្លាចមានតែស្នាមញញឹម និងមានសុខភមង្គលនៅក្នុងគ្រួសារ។ ប្រទេសជាតិមានតែភាពរីកចម្រើនជឿនលឿនអាស្រ័យទៅតាមការដឹកនាំ ការគ្រប់គ្រងល្អ មនុស្សនៅក្នុងសង្គមមានចំណេះដឹង មិនមានការរើសអើងរវាងគ្នា និងគ្នា គ្មានការប្រកាន់ពូជសាសន៍ ពណ៌សម្បុរ មានតែការស្រឡាញ់រាប់អានគ្នា និងចេះជួយគ្នាក្នុងគ្រាមានអាសន្ន។ ការផ្លាស់ប្តូររបបមួយអាស្រ័យទៅតាមការបោះឆ្នោត គ្មានការប្រើអំពើហិង្សា សម្លុតគំរាមកំហែង គ្មានការបន្លំសន្លឹកឆ្នោតដើម្បីចង់បានជ័យជំនះសកម្មភាពបែបនេះបើមានប្រទេសជាតិប្រាកដជាមានភាពសុក្រឹត្យ យុត្តិធម៌ ក្នុងការគ្រប់គ្រងប្រទេសជាតិបានល្អជានិច្ច។

និយាយយ៉ាងវែងអន្លាយក៏មិនភ្លេចនូវការដែលបានសិក្សាប្រធានបទ ***ការវិវត្តន៍រាជរដ្ឋាភិបាលកម្ពុជាឆ្នាំ ១៩៩៣ ដល់បច្ចុប្បន្ន*** នេះថាមានការផ្លាស់ប្តូរអ្វីខ្លះនោះដែល រដ្ឋាភិបាលកើតឡើងដោយការបោះឆ្នោតផ្តល់សេចក្តីទុកចិត្តពីសភា ដោយការបោះឆ្នោតធ្វើឡើងក្នុងរយៈពេល ៥ ឆ្នាំម្តង ។ នីតិកាលទីមួយ រដ្ឋាភិបាលមាន

នាយករដ្ឋមន្ត្រីពីរ ដែលគេហៅថា សហនាយករដ្ឋមន្ត្រី ដែលការគ្រប់គ្រងប្រទេសមានក្បាលម៉ាស៊ីនពីរផងដែរ។ ក្រោយមកទៀត ការបោះឆ្នោតនីតិកាលជាបន្តបន្ទាប់ទៀតប្រទេសកម្ពុជាលែងមាននាយករដ្ឋមន្ត្រីពីរទៀតហើយ ព្រោះពេលនោះមានតែគណបក្សប្រជាជនទេដែលមានអាសនៈ និងសម្លេងច្រើនជាងគេដែលជាអ្នកឈ្នះសន្លឹកឆ្នោត។ ការដែលឈ្នះច្រើនបែបនេះក៏ក្នុងពេលមួយនោះ កម្ពុជាធ្លាប់មានបញ្ហាជាប់គាំងនយោបាយមួយកើតឡើងដែល គណបក្សប្រឆាំងគាត់មិនចូលរួមក្នុងការប្រជុំសភា។ មកដល់ឆ្នាំក្រោយទៀត ប្រទេសកម្ពុជា បានសម្រេចយកការបោះឆ្នោតនៅសភា សម្លេងភាគច្រើនដាច់ខាត ៥០%+១ បើទោះបីជាគ្មាននៅសមាជិកគណបក្សប្រឆាំងក៏គេអាចបង្កើតរដ្ឋាភិបាលកម្ពុជាស្របច្បាប់បានទៅតាមសម្លេងឆ្នោតដែលឈ្នះដាច់នេះ។ ចាប់តាំងពីឆ្នាំ១៩៩៣មក ប្រទេសកម្ពុជាមានការផ្លាស់ប្តូរ ៦ដំណាក់កាលរួចមក ហើយដំណាក់កាលទីមួយៈ ១៩៩៣, ១៩៩៨, ២០០៣, ២០០៨, ២០១៣, ២០១៨។ នៅឆ្នាំចុងក្រោយឆ្នាំ ២០១៨ មានតែគណបក្សប្រជាជន ដែលឈ្នះដាច់ដោយឆ្នាំ នោះមានកៅអី ១២៥ គណបក្សកាន់អំណាចទទួលបាន ១២៥ កៅអី នៅក្នុងសភាតែនៅឆ្នាំ ២០១៨ អវត្តមានគណបក្សសង្គ្រោះជាតិ។

គណបក្សសង្គ្រោះជាតិ ត្រូវបានរំលាយដោយតុលាការកាលពីឆ្នាំ ២០១៧ មកហើយ។ ដូច្នេះ គណបក្សសង្គ្រោះជាតិ គ្មានវត្តមាននៅក្នុងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្របានឡើយ។ មានតែគណបក្សកាន់អំណាច ម្នាក់គត់ដែលជាអ្នកឈ្នះសន្លឹកឆ្នោតភ្លូកទឹកភ្លូកដីនៅពេលនោះផងដែរ។

# អនុសាសន៍

ក្រោយពីបានសិក្សាអំពីប្រធានបទស្ដីពី "***ការវិវត្តន៍រាជរដ្ឋាភិបាលកម្ពុជាឆ្នាំ១៩៩៣ ដល់បច្ចុប្បន្ន*** " រួចមកក្រុមរបស់ យើងខ្ញុំបានយល់ដឹងជាច្រើននៅក្នុងប្រទេសកម្ពុជាថាមានការផ្លាស់ប្ដូររបបនយោបាយនីមួយៗទៅតាមនីតិវិធីជាច្រើនទៅតាមការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ការបោះឆ្នោត ដោយស្មើគ្នា ដោយចំពោះ ដោយសម្ងាត់និងដោយផ្ទាល់។ ការប្រព្រឹត្តទៅដោយមានភាពសុក្រឹត្យយុត្តិធម៌ ដោយសន្លឹកឆ្នោតមួយបោះបានតែម្នាក់គត់។ កម្ពុជា ជាព្រះរាជាណាចក្រដែលប្រកាន់យករបបប្រជាធិបតេយ្យសេរីពហុបក្ស។

របបប្រជាធិបតេយ្យសេរីពហុបក្សកើតឡើងទៅតាមការបោះឆ្នោត។ ប្រទេសកម្ពុជាចាប់តាំងពីឆ្នាំ ១៩៤៧ មកដល់ពេលបច្ចុប្បន្នរបបនយោបាយមានការផ្លាស់ប្ដូរជាច្រើនលើកកន្លងមកនេះ។ ការប្រែប្រួលរហូតមកដល់ឆ្នាំ១៩៩៣នេះការបោះឆ្នោតមានចំនួន៦លើករួចមកហើយដំណាក់កាលនីមួយៗមានដូចជា៖ ដំណាក់កាលទី១ ចាប់ពីឆ្នាំ ១៩៩៣ ដល់ឆ្នាំ ១៩៩៨ ដំណាក់កាលទី២ ចាប់ពីឆ្នាំ ១៩៩៨ ដល់ឆ្នាំ ២០០៣ ដំណាក់កាល់ទី៣ ចាប់ពីឆ្នាំ ២០០៣ ដល់ឆ្នាំ ២០០៨ ដំណាក់កាលទី៤ ចាប់ពីឆ្នាំ ២០០៨ ដល់ឆ្នាំ២០១៣ ដំណាក់កាលទី៥ ចាប់ពីឆ្នាំ២០១៣ ដល់ឆ្នាំ២០១៨ ដំណាក់កាលទី៦ចាប់ពីឆ្នាំ ២០១៨ ដល់ឆ្នាំ ២០២៣។ នៅឆ្នាំ ១៩៩៣ នាយករដ្ឋមន្ត្រីមាន២រូប ដែលប្រទេសកម្ពុជាជាលើកដំបូងការដឹកនាំ គ្រប់គ្រងប្រទេសមានក្បាលម៉ាស៊ីន២ ក្នុងពេលតែមួយជាប្រវត្តិសាស្ត្រមិនធ្លាប់មានឡើយ។ មកដល់ឆ្នាំ១៩៩៨ ដល់ឆ្នាំ ២០០៣ ការបោះឆ្នោតមាននាយករដ្ឋមន្ត្រីតែមួយរូប។ នៅឆ្នាំ ២០០៣ កើតមាននៅបញ្ហាជាប់គាំងមួយដែលគណបក្សប្រឆាំងមិនចូលរួមក្នុងសភាដែលជាបញ្ហាសម្រាប់ការបង្កើតរដ្ឋាភិបាលស្របច្បាប់។

រហូតមកឆ្នាំ ២០០៤ ក៏គេបានបង្កើតច្បាប់រដ្ឋធម្មនុញ្ញបន្ថែមសម្រាប់បង្កើតរដ្ឋាភិបាលទោះបីជាគ្មានវត្តមានគណបក្សប្រឆាំងក៏ដោយគេអាចបង្កើតរដ្ឋាភិបាលស្របច្បាប់បានអនុវត្តទៅតាមរូបមន្ត ៥០%+១ ។ មកដល់ពេលនេះ ក៏លែងមានការកកស្ទះទៀត។ ដូចនេះរដ្ឋាភិបាលបច្ចុប្បន្ន ឆ្នាំ២០១៨ ការបោះឆ្នោតប្រព្រឹត្តទៅបានដោយរលូនមិនមានការរំខានអ្វីឡើយការបោះឆ្នោតទៅតាមពេលវេលាដែលបានកំណត់ច្បាស់លាស់។ នៅឆ្នាំនេះការអវត្តមានគណៈបក្សប្រឆាំងរបស់គណបក្សសង្គ្រោះជាតិខណៈនោះមានតែគណបក្សប្រជាជនកម្ពុជាទទួលបានកៅអីនៅក្នុងជួររដ្ឋាភិបាល ១២៥ អាសនៈ ដែលមានចំនួនកៅអី ១២៥ ផងដែរ។ ការជោគជ័យក្នុងការបោះឆ្នោតនេះ គឺគ្មានការជំទាស់ពីសំណាក់គណបក្សណាមួយឡើយ។

មានតែការអបអរសាទរនៅលទ្ធផលដែលបាននេះ ដោយការពេញចិត្តពីគណបក្សចាញ់ឆ្នោតនីមួយៗទើបការបង្កើតរដ្ឋាភិបាលដោយសន្តិវិធី សុក្រឹត្យ យុត្តិធម៌ មិនមានការគំរាមកំហែងពីគណបក្សណាមួយឡើយ។

ក្រោយពីបានស្រាវជ្រាវអត្ថបទខាងលើរួចមក ប្រទេសជាតិយើងគួរមានការពង្រឹងនូវយន្តការក្នុងការបោះឆ្នោតឲ្យមានភាពយុត្តិធម៌ ហេតុទើបធ្វើឲ្យការគ្រប់គ្រងដឹកនាំមានការរីកចម្រើនលើគ្រប់វិស័យនានានៅក្នុងប្រទេសជាតិមានដូចខាងក្រោមនេះ៖

- នៅពេលប្រព័ន្ធបោះឆ្នោតនៅកម្ពុជាមានការរៀបចំបានល្អប្រសើរ គឺជួយឲ្យការដឹកនាំប្រទេសមានភាពរីកចម្រើនបានឆាប់រហ័សគ្មានការកកស្ទះ។
- មេដឹកនាំពោរពេញដោយសមត្ថភាព ចំណេះដឹង ភាពឆ្លាតវៃយក្នុងការដោះស្រាយបញ្ហានានាដែលកើតឡើងនៅចំពោះមុខរបស់ខ្លួនដោយសន្តិវិធី។
- សូមកុំមានការគៀបសង្កត់ប្រជាពលរដ្ឋនៅក្នុងសហគមន៍ គ្រប់ទីស្ថាននានាដែលពួកគេរស់នៅឡើយ។
- សូមឲ្យការដឹកនាំប្រកបដោយទស្សពិរាជធម៌ គ្មានការលំអៀង មានភាពទទួលខុសត្រូវលើអ្វីដែលបានប្រព្រឹត្ត។
- មេដឹកនាំត្រូវតែជាអ្នកដែលមានភាពក្លាហាន ប៉ិនប្រសប់ ការមិនប្រព្រឹត្តអំពើខុសនិងច្បាប់ដែលបានចែងនៅក្នុងរដ្ឋធម្មនុញ្ញឆ្នាំ ១៩៩៣។
- សូមឲ្យមានការរៀបចំការបោះឆ្នោតនៅកម្ពុជាកាន់តែមានភាពសុក្រឹត្យយុត្តិធម៌ទៅឡើង។
- នៅពេលបានក្លាយទៅជាថ្នាក់ដឹកនាំកំពូលប្រទេសជាតិ ហើយសូមជួយធ្វើជាសសរទ្រូងប្រទេសឲ្យមានភាពល្អប្រសើរកុំឲ្យកើតមាននូវអំពើ អសន្តិសុខ អនាធិបតេយ្យ ភាពក្រីក្រ កើតមានដោយប្រការណាមួយឡើយ។
- ធ្វើឲ្យប្រជាពលរដ្ឋនៅក្នុងប្រទេស មានការស្រឡាញ់ គាំទ្រ បានគ្រប់ពេលវេលាមិនថានៅក្នុងស្ថានភាពណាក៏ដោយ មិនត្រូវរត់ចោលប្រជាពលរដ្ឋរបស់ខ្លួនជាដាច់ខាត។
- សូមជួយពង្រឹងវិស័យអប់រំ ក៏ដូចជាផ្តល់ឱកាសល្អៗឲ្យដល់និស្សិតដែលចង់បន្តការសិក្សាដែលពួកគេគ្មានលទ្ធភាព ក្នុងការរៀនសូត្រ ឬ នៅតំបន់ដាច់ស្រយាលមួយចំនួននៅឆ្ងាយពីខេត្ត ក្រុង ដែលពួកគេរស់នៅទីប្រជុំជន ឬ សាធារណៈនៅក្នុងប្រទេសកម្ពុជានេះ។

- សូមជួយកសាងស្ពាន ផ្លូវថ្នល់ សាលារៀន មន្ទីរពេទ្យឲ្យបាននៅក្បែរពួកគាត់នៅក្នុងតំបន់ឆ្ងាយពីក្រុង នៅតាមភូមិដ្ឋាននានាដែលពួកគាត់កំពុងរស់នៅ ប្រសិនបើផ្លូវមិនល្អ ពិបាកក្នុងការធ្វើដំណើរទៅទីជិត ឬ ឆ្ងាយផងដែរ។

# ឯកសារយោង

## ❖ ច្បាប់ និងបទដ្ឋានគតិយុត្ត

-រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ ១៩៩៣

-ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ លេខ១៩៤/០០២/២០១៨ កបធ.ច ចុះថ្ងៃទី១៥ ខែ មិថុនា ឆ្នាំ ២០១៨។

-ច្បាប់ធម្មនុញ្ញបន្ថែមសំដៅ ធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ ព្រះរាជក្រម លេខ នស/រកម/០៧០៤/០០១ អនុម័តកាលពីថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០០៤

-បទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា

-ច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ព្រះរាជក្រម លេខ នស/រកម/០៣១៥/០០៣ ក្នុងសេចក្តីសម្រេចលេខ ១៥៤/០០២/២០១៥ កបធ.ច ចុះថ្ងៃទី២៤ ខែ មីនា ឆ្នាំ ២០១៥

-ច្បាប់ស្តីពីការកំណត់ចំនួនអាសនៈរដ្ឋសភា នីតិកាលទី៣

## ❖ សៀវភៅ និងឯកសារពាក់ព័ន្ធនានា

- សៀវភៅ នីតិរដ្ឋធម្មនុញ្ញ ដោយសាស្ត្រាចារ្យ សុខ ចិន្តា និង សុខ យ៉ាន។
- សៀវភៅរដ្ឋាភិបាលកម្ពុជាពីឆ្នាំ ១៩៤៥ ដល់ឆ្នាំ ២០១០ បោះពុម្ពលើកទី២ ឯកសារស្រាវជ្រាវដោយ ពុយ គា។
- គុណតម្លៃរដ្ឋធម្មនុញ្ញកម្ពុជា ទស្សនៈទានចម្រុះក្នុងសន្និសិទ្ធិរំលឹកខួប២០ឆ្នាំ ចងក្រងនិពន្ធបោះពុម្ពផ្សាយដោយ ឯកឧត្តមកិត្តិនីតកោសលបណ្ឌិត អ៊ឹម ឈុនលឹម ក្រុមប្រឹក្សាឯកទេសរដ្ឋធម្មនុញ្ញ ឯកឧត្តមបណ្ឌិត ហោ ប៉ែន និង ឯកឧត្តម តាំង រតនា ជំនួយការឯកទេស ឯកឧត្តមបណ្ឌិត ព្រហ្ម វិចិត្រ អក្ខរា និង អ្នកស្រី ប៉ុក ភារុន។
- សៀវភៅរដ្ឋាភិបាលកម្ពុជានីមួយៗក្នុងរយៈពេល៦ ទសវត្សរ៍ចុងក្រោយ រៀបរៀងដោយ ពុយ គា។
- សៀវភៅសេចក្តីផ្តើម នីតិរដ្ឋធម្មនុញ្ញ រៀបរៀង និង ចងក្រងដោយ បណ្ឌិត ឈុន ណារ៉េត។
- សៀវភៅស្ថាប័ននយោបាយព្រះរាជាណាចក្រកម្ពុជាបោះពុម្ពលើកទី១ សាស្ត្រាចារ្យ ជុំ អ៊ីម។
- សៀវភៅសារណាបញ្ចប់ការសិក្សា ប្រជាធិបតេយ្យ និងការបែងចែកអំណាចនៅកម្ពុជាពីឆ្នាំ (១៩៩៣-២០០៩) តាក់តែងឡើងដោយ និស្សិត ឈ្មោះ គីម វិស្សុត និង លោក គាន សុចិន្តា។
- អភ័យឯកសិទ្ធិរដ្ឋសភានៅកម្ពុជា(ករណីសិក្សាប្រៀបធៀបប្រទេសជប៉ុន) ស្រាវជ្រាវដោយនិស្សិតឈ្មោះ ក. ធូ ផនេច និង រ៉ វ៉ ដារិទ្ធ ឆ្នាំសរសេរសារណា ២០១៦។
- ដំណើរការប្រព្រឹត្តទៅរបស់រដ្ឋសភានីតិកាលទី៤ តាក់តែងឡើងដោយនិស្សិតឈ្មោះ កែវ ឈនវីដូ ឆ្នាំសរសេរបាយការណ៍២០១២។
- ដកស្រង់ចេញពី you tube ឈ្មោះថ្នាក់ដឹកនាំតាមក្រសួងនិងស្ថាប័ននានានា ក្នុងព្រះរាជាណាចក្រកម្ពុជា AmazingpovidPro។

-គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត National Election Comm

- https://km.wikipedia.org/wiki/%E1%9E%80%E1%9E%B6%E1%9E%9A%E1%9E%8A%E1%9F%84%E1%9F%87%E1%9E%9F%E1%9F%92%E1%9E%9A%E1%9E%B6%E1%9E%99%E1%9E%91%E1%9F%86%E1%9E%93%E1%9E%B6%E1%9E%9F%E1%9F%8B%E1%9E%80%E1%9F%92%E1%9E%93%E1%9E%BB%E1%9E%84%E1%9E%94%E1%9F%92%E1%9E%9A%E1%9E%96%E1%9F%90%E1%9E%93%E1%9F%92%E1%9E%92%E1%9E%8F%E1%9E%BB%E1%9E%9B%E1%9E%B6%E1%9E%80%E1%9E%B6%E1%9E%9A
- https://www.rfa.org/khmer/news/analysis/analysis-will-new-government-deadlock-08022013035650.html
- https://www.rfi.fr/km/cambodia/national-assembly-leader-06-09-2018
- https://www.cambodiadaily.com/2021/10/14/16/28/57203/
- https://kleykley.sabay.com.kh/article/10835

# ឧបសម្ព័ន្ធ

# រដ្ឋធម្មនុញ្ញ

# នៃ

# ព្រះរាជាណាចក្រកម្ពុជា

**រដ្ឋសភា**

# ជំពូកទី ១
# អំពីអធិបតេយ្យ

**មាត្រា ១.-**

*ប្រទេសកម្ពុជា ជាព្រះរាជាណាចក្រ ដែលព្រះមហាក្សត្រ ទ្រង់ប្រតិបត្តិតាមរដ្ឋធម្មនុញ្ញ និងតាមលទ្ធិប្រជាធិបតេយ្យ សេរីពហុបក្ស ។*

*ព្រះរាជាណាចក្រកម្ពុជា ជារដ្ឋឯករាជ្យ អធិបតេយ្យ សន្តិភាព អព្យាក្រឹត អចិន្ត្រៃយ៍ មិនចូលបក្សសម្ព័ន្ធ ។*

**មាត្រា ២.-**

*បូរណភាពទឹកដីរបស់ព្រះរាជាណាចក្រកម្ពុជាមិនអាចរំលោភបាន ដាច់ខាត ក្នុងព្រំដែនរបស់ខ្លួន ដែលមានកំណត់ក្នុងផែនទីខ្នាត ១/១០០.០០០ ធ្វើនៅចន្លោះឆ្នាំ ១៩៣៣-១៩៥៣ ហើយដែលត្រូវបានទទួលស្គាល់ជាអន្តរជាតិ នៅចន្លោះឆ្នាំ ១៩៦៣-១៩៦៩ ។*

**មាត្រា ៣.-**

*ព្រះរាជាណាចក្រកម្ពុជា ជារដ្ឋដែលមិនអាចបំបែកបាន ។*

**មាត្រា ៤.-**

*បាវចនានៃព្រះរាជាណាចក្រកម្ពុជាគឺៈ ជាតិ សាសនា ព្រះមហាក្សត្រ ។*

**មាត្រា ៥.-**

*ភាសា និងអក្សរដែលប្រើជាផ្លូវការគឺ ភាសា និងអក្សរខ្មែរ ។*

**មាត្រា ៦.-**

ភ្នំពេញជារាជធានីនៃព្រះរាជាណាចក្រកម្ពុជា ។

ទង់ជាតិ ភ្លេងជាតិ និងសញ្ញាជាតិ មានកំណត់នៅក្នុង ឧបសម្ព័ន្ធ ១,២ និង ៣ ។

## ជំពូកទី ២
## អំពីព្រះមហាក្សត្រ

**មាត្រា ៧.-**

ព្រះមហាក្សត្រកម្ពុជា ទ្រង់គ្រងរាជ្យសម្បត្តិ ប៉ុន្តែទ្រង់មិនកាន់អំណាចឡើយ ។

ព្រះមហាក្សត្រ ទ្រង់ជាព្រះប្រមុខរដ្ឋមួយជីវិត ។

អង្គព្រះមហាក្សត្រមិនអាចនរណារំលោភបំពានបានឡើយ ។

**មាត្រា ៨.-**

ព្រះមហាក្សត្រព្រះអង្គទ្រង់ជានិមិត្តរូបនៃឯកភាពជាតិ និងនិរន្តរភាពជាតិ ។

ព្រះមហាក្សត្រ ទ្រង់ជាអ្នកធានាឯករាជ្យជាតិ អធិបតេយ្យ និងបូរណភាពទឹកដីនៃព្រះរាជាណាចក្រកម្ពុជា ទ្រង់ជាអ្នកធានាការគោរពសិទ្ធិ និងសេរីភាពរបស់ប្រជាពលរដ្ឋ និងការគោរពសន្ធិសញ្ញាអន្តរជាតិ ។

**មាត្រា ៩.-**

ព្រះមហាក្សត្រទ្រង់មានតួនាទីខ្ពង់ខ្ពស់ជាអាជ្ញាកណ្តាល

**មាត្រា ២៥.-**

ព្រះមហាក្សត្រទ្រង់ទទួលសារតាំងឯកអគ្គរដ្ឋទូត ឬប្រេសិតវិសាមញ្ញ និងពេញសមត្ថភាពនៃប្រទេសក្រៅមកប្រចាំព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ២៦.- ថ្មី**

ព្រះមហាក្សត្រទ្រង់ឡាយព្រះហស្តលេខាលើសន្ធិសញ្ញា និងអនុសញ្ញាអន្តរជាតិ ហើយទ្រង់ប្រទានសច្ចាប័នលើសន្ធិសញ្ញា និងអនុសញ្ញាទាំងនេះ ក្រោយបានទទួលការអនុម័តយល់ព្រមពីរដ្ឋសភា និងព្រឹទ្ធសភា ។

**មាត្រា ២៧.-**

ព្រះមហាក្សត្រទ្រង់មានព្រះរាជសិទ្ធិបន្ធូរបន្ថយទោសនិងលើកលែងទោស ។

**មាត្រា ២៨.- ថ្មី**

ព្រះមហាក្សត្រទ្រង់ឡាយព្រះហស្តលេខាលើព្រះរាជក្រមប្រកាសឱ្យប្រើរដ្ឋធម្មនុញ្ញ ច្បាប់ដែលរដ្ឋសភាបានអនុម័ត និងព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់រួចហើយ និងទ្រង់ឡាយព្រះហស្តលេខាលើព្រះរាជក្រឹត្យតាមសេចក្តីស្នើសុំពីគណៈរដ្ឋមន្ត្រី ។

ក្នុងពេលដែលព្រះមហាក្សត្រប្រឈួន ហើយត្រូវព្យាបាល ព្រះរោគនៅបរទេស ក្នុងពេលនោះព្រះមហាក្សត្រមានសិទ្ធិផ្ទេរអំណាចឡាយ

កាតព្វកិច្ចការពារមាតុភូមិត្រូវអនុវត្តតាមបញ្ញត្តិច្បាប់ ។

**មាត្រា ៥០.-**

ប្រជាពលរដ្ឋខ្មែរទាំងពីរភេទត្រូវគោរពគោលការណ៍ អធិប-តេយ្យជាតិ និងលទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស ។

ប្រជាពលរដ្ឋខ្មែរទាំងពីរភេទត្រូវគោរពទ្រព្យសម្បត្តិសាធារណៈ និងកម្មសិទ្ធិស្របច្បាប់របស់ឯកជន ។

## ជំពូកទី ៤
## អំពីរបបនយោបាយ

**មាត្រា ៥១.- ថ្មី**

ព្រះរាជាណាចក្រកម្ពុជា អនុវត្តនយោបាយប្រជាធិបតេយ្យ សេរីពហុបក្ស ។

ប្រជាពលរដ្ឋខ្មែរជាម្ចាស់វាសនានៃប្រទេសជាតិរបស់ខ្លួន ។

អំណាចទាំងអស់ជារបស់ប្រជាពលរដ្ឋ ។

ប្រជាពលរដ្ឋប្រើអំណាចរបស់ខ្លួន តាមរយៈរដ្ឋសភា ព្រឹទ្ធសភា រាជរដ្ឋាភិបាល និងសាលាជំរះក្តី ។

អំណាចបែងចែកដាច់ពីគ្នា រវាងអំណាចនីតិប្បញ្ញត្តិ អំណាចនីតិប្រតិបត្តិ និងអំណាចតុលាការ ។

**មាត្រា ៥២.-**

រាជរដ្ឋាភិបាលកម្ពុជា ប្តេជ្ញារក្សាការពារឯករាជ្យ អធិបតេយ្យ បូរណភាពទឹកដីនៃព្រះរាជាណាចក្រកម្ពុជា អនុវត្តនយោបាយ បង្រួបបង្រួម

ជាតិ ដើម្បីការពារឯកភាពជាតិ រក្សាការពារទំនៀមទម្លាប់ និងប្រពៃណីល្អ របស់ជាតិ ។ រាជរដ្ឋាភិបាលកម្ពុជា ត្រូវការពារនីត្យានុកូលភាព ធានាសណ្តាប់ធ្នាប់ និងសន្តិសុខសាធារណៈ ។ រដ្ឋយកចិត្តទុកដាក់ជាអាទិភាព ចំពោះជីវភាពរស់នៅ និងសុខុមាលភាពរបស់ប្រជាពលរដ្ឋ ។

**មាត្រា ៥៣.-**

ព្រះរាជាណាចក្រកម្ពុជាប្រកាន់ខ្ជាប់ជានិច្ចនូវនយោបាយអព្យាក្រឹតអចិន្ត្រៃយ៍ និងមិនចូលបក្សសម្ព័ន្ធ ។ ព្រះរាជាណាចក្រកម្ពុជា រួមរស់ដោយសន្តិសហវិជ្ជមានជាមួយប្រទេសជិតខាង និងប្រទេសដទៃទៀតទាំងអស់នៅលើសកលលោក ។

ព្រះរាជាណាចក្រកម្ពុជាមិនឈ្លានពានប្រទេសណាដាច់ខាត មិនជ្រៀតជ្រែកកិច្ចការផ្ទៃក្នុងនៃប្រទេសដទៃដោយផ្ទាល់ ឬដោយប្រយោល ទោះបីក្រោមរូបភាពណាក៏ដោយ ដោះស្រាយរាល់បញ្ហាដោយសន្តិវិធី និងគោរពផលប្រយោជន៍ផងគ្នាទៅវិញទៅមក ។

ព្រះរាជាណាចក្រកម្ពុជាមិនចងសម្ព័ន្ធយោធា ឬចូលក្នុងកិច្ចព្រមព្រៀងយោធាណាមួយ ដែលមិនស្របនឹងអព្យាក្រឹតភាពរបស់ខ្លួនឡើយ ។

ព្រះរាជាណាចក្រកម្ពុជាមិនអនុញ្ញាតឱ្យមានមូលដ្ឋានយោធាបរទេសនៅលើទឹកដីរបស់ខ្លួន ហើយក៏មិនអនុញ្ញាតឱ្យមានមូលដ្ឋានយោធារបស់ខ្លួននៅបរទេសដែរ លើកលែងតែក្នុងក្របខ័ណ្ឌ នៃសំណូមពររបស់អង្គការសហប្រជាជាតិ ។

**មាត្រា ៧៣.‑**

*រដ្ឋយកចិត្តទុកដាក់ចំពោះកុមារ និងមាតា ។ រដ្ឋរៀបចំឱ្យមាន ទារកដ្ឋាន និងជួយឧបត្ថម្ភនារីដែលមានកូនច្រើនក្នុងបន្ទុក ហើយឥតទីពឹង ។*

**មាត្រា ៧៤.‑**

*រដ្ឋជួយឧបត្ថម្ភជនពិការ និងដល់គ្រួសារយុទ្ធជន ដែលបាន បូជាជីវិតដើម្បីប្រទេសជាតិ ។*

**មាត្រា ៧៥.‑**

*រដ្ឋចាត់ចែងឱ្យមានរបបសន្តិសុខសង្គមដល់កម្មករ និងនិយោ‑ ជិត ។*

## ជំពូកទី ៧
## អំពីរដ្ឋសភា

**មាត្រា ៧៦.‑ ថ្មី**

*រដ្ឋសភាមានសមាជិកតំណាងរាស្ត្រយ៉ាងតិច ១២០ រូប ។*

*តំណាងរាស្ត្រត្រូវជ្រើសតាំងដោយការបោះឆ្នោតជាសកល ដោយ សេរី ដោយស្មើភាព ដោយចំពោះ និងតាមវិធីជ្រើសរើសឆ្នោតជាសម្ងាត់ ។*

*តំណាងរាស្ត្រអាចឈរឈ្មោះបោះឆ្នោតសាជាថ្មីបាន ។*

*អ្នកដែលមានសិទ្ធិឈរឈ្មោះជាបេក្ខជនតំណាងរាស្ត្រ គឺជាប្រជាពលរដ្ឋខ្មែរទាំងពីរភេទ ដែលមានសិទ្ធិបោះឆ្នោត មានអាយុយ៉ាង*

តិច ២៥ឆ្នាំ មានសញ្ជាតិជាខ្មែរតាំងពីកំណើត ។

បែបបទ និងការប្រព្រឹត្តទៅនៃការបោះឆ្នោត ត្រូវកំណត់ក្នុងច្បាប់បោះឆ្នោត ។

**មាត្រា ៧៧.-**

តំណាងរាស្ត្រក្នុងរដ្ឋសភា ជាតំណាងប្រជាជាតិខ្មែរទាំងមូល ពុំមែនគ្រាន់តែជាតំណាងប្រជាពលរដ្ឋក្នុងមណ្ឌលរបស់ខ្លួននោះទេ ។

អាណត្តិអាជ្ញាបញ្ជាទាំងឡាយ ត្រូវទុកជាមោឃៈ ។

**មាត្រា ៧៨.-**

នីតិកាលរបស់រដ្ឋសភាមានកំណត់ ៥ឆ្នាំ ហើយត្រូវផុតកំណត់ នៅពេលដែលរដ្ឋសភាថ្មីចូលកាន់តំណែង ។ រដ្ឋសភាមិនអាចត្រូវបានរំលាយមុនផុតអាណត្តិបានឡើយ វៀរលែងតែក្នុងករណីដែលរាជរដ្ឋាភិបាលត្រូវបានទម្លាក់ពីរដងក្នុងរយៈពេល ១២ខែ ។

ក្នុងករណីនេះ ព្រះមហាក្សត្រត្រូវរំលាយរដ្ឋសភា ក្រោយពីព្រះអង្គទ្រង់បានទទួលការស្នើពីនាយករដ្ឋមន្ត្រី និងបន្ទាប់ពីទ្រង់បានការយល់ព្រមពីប្រធានរដ្ឋសភា ។

ការបោះឆ្នោតដើម្បីជ្រើសរើសរដ្ឋសភាថ្មី នឹងប្រព្រឹត្តទៅក្នុងរយៈពេល ៦០ ថ្ងៃ យ៉ាងយូរ ចាប់តាំងពីថ្ងៃរំលាយរដ្ឋសភាមក ។

ក្នុងរយៈកាលនេះ រាជរដ្ឋាភិបាលមានតែភារកិច្ចដឹកនាំការងារប្រចាំថ្ងៃតែប៉ុណ្ណោះ ។

ក្នុងពេលមានសង្គ្រាម ឬក្នុងកាលៈទេសៈពិសេសដទៃទៀតដែល មិនអាចធ្វើការបោះឆ្នោតកើត រដ្ឋសភាអាចប្រកាសបន្តនីតិកាលរបស់ខ្លួន មួយដងបានមួយឆ្នាំ តាមសំណើរបស់ព្រះមហាក្សត្រ ។

ការប្រកាសបន្តនីតិកាលរបស់រដ្ឋសភា ត្រូវសម្រេចដោយមតិ យល់ព្រម ពីរភាគបីយ៉ាងតិច នៃចំនួនសមាជិករដ្ឋសភាទាំងមូល ។

**មាត្រា ៧៩**.-

អាណត្តិនៃសមាជិករដ្ឋសភា មានវិសមិតភាពជាមួយការ បំពេញមុខងារសាធារណៈជាសកម្ម និងជាមួយមុខងារជាសមាជិក នៃ ស្ថាប័នដទៃទៀត ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញនេះ វៀរលែងតែទៅបំពេញ មុខងារក្នុងគណៈរដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាល ។

ក្នុងករណីនេះ សមាជិករដ្ឋសភារូបនោះមានឋានៈជា សមាជិក រដ្ឋសភាធម្មតា ប៉ុន្តែមិនត្រូវមានមុខតំណែងអ្វីទាំងអស់ក្នុងគណៈកម្មាធិការ-អចិន្ត្រៃយ៍ និងក្នុងគណៈកម្មការផ្សេងៗនៃរដ្ឋសភា ។

**មាត្រា ៨០**.-

តំណាងរាស្ត្រមានអភ័យឯកសិទ្ធិសភា ។

តំណាងរាស្ត្ររូបណាក៏ដោយ មិនអាចត្រូវបានចោទប្រកាន់ ចាប់ ខ្លួន ឃាត់ខ្លួន ឬឃុំខ្លួន ដោយហេតុពីបានសំដែងយោបល់ ឬបញ្ចេញមតិ ក្នុងការបំពេញមុខងាររបស់ខ្លួនសោះឡើយ ។

ការចោទប្រកាន់ ការចាប់ខ្លួន ការឃាត់ខ្លួន ឬការឃុំខ្លួនសមាជិក ណាមួយនៃរដ្ឋសភានឹងអាចធ្វើទៅកើត លុះត្រាតែមានការយល់ព្រមពី

រដ្ឋសភា ឬពីគណៈកម្មាធិការអចិន្ត្រៃយ៍របស់រដ្ឋសភា ក្នុងចន្លោះសម័យប្រជុំនៃរដ្ឋសភា វៀរលែងតែក្នុងករណីបទល្មើសព្រហ្មទណ្ឌជាក់ស្តែង។ក្នុងករណីខាងក្រោយនេះ ក្រសួងមានសមត្ថកិច្ច ត្រូវធ្វើសេចក្តីរាយការណ៍ ជូនរដ្ឋសភា ឬជូនគណៈកម្មាធិការអចិន្ត្រៃយ៍របស់រដ្ឋសភាជាបន្ទាន់ដើម្បីសម្រេច ។

សេចក្តីសម្រេចរបស់គណៈកម្មាធិការអចិន្ត្រៃយ៍របស់រដ្ឋសភា ត្រូវដាក់ជូនសម័យប្រជុំរដ្ឋសភាខាងមុខ ដើម្បីអនុម័តតាមមតិភាគច្រើនពីរភាគបី នៃសមាជិករដ្ឋសភាទាំងមូល ។

ក្នុងករណីទាំងអស់ខាងលើនេះ ការឃុំខ្លួន ការចោទប្រកាន់តំណាងរាស្ត្រណាមួយត្រូវផ្អាក ប្រសិនបើរដ្ឋសភាបានបញ្ចេញមតិឱ្យផ្អាកតាមមតិភាគច្រើនបីភាគបួន នៃចំនួនសមាជិករដ្ឋសភាទាំងមូល ។

**មាត្រា ៨១.-**

រដ្ឋសភាមានថវិកាស្វយ័ត សម្រាប់ដំណើរការ ។

តំណាងរាស្ត្រត្រូវទទួលប្រាក់បំណាច់ ។

**មាត្រា ៨២.- ថ្មី**

រដ្ឋសភាបើកសម័យប្រជុំដំបូង ហុកសិបថ្ងៃយ៉ាងយូរក្រោយពេលបោះឆ្នោត តាមការកោះប្រជុំរបស់ព្រះមហាក្សត្រ ។

មុនចាប់ផ្តើមការងាររបស់ខ្លួន រដ្ឋសភាត្រូវប្រកាស សុពលភាពនៃអាណត្តិរបស់សមាជិកនីមួយៗ ត្រូវបោះឆ្នោតជ្រើសរើសដាច់ដោយឡែកពីគ្នានូវប្រធាន អនុប្រធានរដ្ឋសភា និងសមាជិកទាំងអស់នៃគណៈកម្មការ

**មាត្រា ៨៩.-**

តាមការស្នើសុំពីសមាជិកចំនួនមួយភាគដប់យ៉ាងតិច រដ្ឋសភាអាចអញ្ជើញឥស្សរជនដ៏ឧត្តមណាមួយមកបំភ្លឺរដ្ឋសភា អំពីបញ្ហាដែលមានសារៈសំខាន់ពិសេស ។

**មាត្រា ៩០.- ថ្មី (ពីរ)**

រដ្ឋសភាជាអង្គការដែលមានអំណាចនីតិប្បញ្ញត្តិ ហើយបំពេញភារកិច្ចរបស់ខ្លួន ដូចបានកំណត់ក្នុងរដ្ឋធម្មនុញ្ញ និងច្បាប់ជាធរមាន ។

រដ្ឋសភាអនុម័តថវិកាជាតិ ផែនការរដ្ឋ ការឱ្យរដ្ឋខ្ចីប្រាក់ពីគេ ការឱ្យរដ្ឋឱ្យប្រាក់គេខ្ចី ការសន្យានានាផ្នែកហិរញ្ញវត្ថុ និងការបង្កើត កែប្រែ ឬលុបចោលពន្ធដារ ។

រដ្ឋសភាឱ្យសេចក្ដីយល់ព្រមចំពោះគណនីរដ្ឋបាល ។

រដ្ឋសភាអនុម័តច្បាប់ស្ដីពីការលើកលែងទោសជាទូទៅ ។

រដ្ឋសភាអនុម័តយល់ព្រម ឬលុបចោលសន្ធិសញ្ញា ឬអនុសញ្ញាអន្តរជាតិ ។

រដ្ឋសភាអនុម័តច្បាប់ស្ដីពីការប្រកាសសង្គ្រាម ។

ការអនុម័តខាងលើនេះ ប្រព្រឹត្តទៅដោយមតិភាគច្រើនដាច់ខាត នៃចំនួនសមាជិករដ្ឋសភាទាំងមូល ។

រដ្ឋសភាបោះឆ្នោតទុកចិត្តដល់រាជរដ្ឋាភិបាល តាមមតិភាគច្រើនដាច់ខាតនៃចំនួនសមាជិករដ្ឋសភាទាំងមូល ។

# ជំពូកទី ១០ ថ្មី
# អំពីរាជរដ្ឋាភិបាល

**មាត្រា ១១៨.- ថ្មី** (**មាត្រា ៩៩ ចាស់**)

*គណៈរដ្ឋមន្ត្រីជារាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ។*

*គណៈរដ្ឋមន្ត្រី ត្រូវបានដឹកនាំដោយនាយករដ្ឋមន្ត្រីមួយរូប អមដោយឧបនាយករដ្ឋមន្ត្រី ព្រមទាំងមានទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី និងរដ្ឋលេខាធិការ ជាសមាជិក ។*

**មាត្រា ១១៩.- ថ្មី** (**មាត្រា ១០០ ចាស់**)

*តាមសេចក្តីស្នើពីប្រធាន ដោយមានមតិឯកភាពពី អនុប្រធានទាំងពីរនៃរដ្ឋសភា ព្រះមហាក្សត្រទ្រង់ចាត់តាំងវរជនមួយរូប ក្នុងចំណោមតំណាងរាស្ត្រនៃគណបក្សដែលឈ្នះឆ្នោត ឱ្យបង្កើតរាជរដ្ឋាភិបាល ។ វរជនដែលត្រូវបានចាត់តាំងនេះ នាំសហការីដែលជាតំណាងរាស្ត្រ ឬជាសមាជិកគណបក្សតំណាងនៅក្នុងរដ្ឋសភា ដែលផ្តួវផ្តងឱ្យកាន់តំណែងផ្សេងៗក្នុងរាជរដ្ឋាភិបាលទៅសុំសេចក្តីទុកចិត្តពីរដ្ឋសភា ។ កាលបើរដ្ឋសភាបានបោះឆ្នោតទុកចិត្តហើយនោះ ព្រះមហាក្សត្រទ្រង់ចេញព្រះរាជក្រឹត្យតែងតាំងគណៈរដ្ឋមន្ត្រីទាំងមូល ។*

*មុនចូលកាន់តំណែង គណៈរដ្ឋមន្ត្រី ត្រូវធ្វើសច្ចាប្រណិធានដូចមានខ្លឹមសារចែងក្នុងឧបសម្ព័ន្ធទី ៦ ។*

**មាត្រា ១២៤.- ថ្មី (មាត្រា ១០៥ ចាស់)**

*នាយករដ្ឋមន្ត្រីអាចរំលែកអំណាចរបស់ខ្លួនឱ្យទៅឧបនាយករដ្ឋមន្ត្រី ឬសមាជិកណាមួយនៃរាជរដ្ឋាភិបាលបាន ។*

**មាត្រា ១២៥.- ថ្មី (មាត្រា ១០៦ ចាស់)**

*បើតំណែងនាយករដ្ឋមន្ត្រីនៅទំនេរជាស្ថាពរនោះ ត្រូវតែងតាំងគណៈរដ្ឋមន្ត្រីមួយជាថ្មី ក្នុងល័ក្ខខ័ណ្ឌដែលមានចែងក្នុងរដ្ឋធម្មនុញ្ញនេះ ។ បើការទំនេរនេះ ជាការទំនេរមួយកាលមួយគ្រាទេ ត្រូវចាត់តាំងនាយករដ្ឋមន្ត្រីស្ដីទីជាបណ្ដោះអាសន្ន ។*

**មាត្រា ១២៦.- ថ្មី (មាត្រា ១០៧ ចាស់)**

*សមាជិកមួយរូបៗ នៃរាជរដ្ឋាភិបាល ត្រូវទទួលទណ្ឌកម្ម ពីបទឧក្រិដ្ឋ ឬបទមជ្ឈិម ដែលខ្លួនបានប្រព្រឹត្តក្នុងការបំពេញការងាររបស់ខ្លួន ។*

*ក្នុងករណីនេះ និងក្នុងករណីធ្វើខុសជាទម្ងន់ក្នុងការបំពេញការងាររបស់ខ្លួន រដ្ឋសភាអាចសម្រេចប្ដឹងទៅតុលាការមានសមត្ថកិច្ច ។*

*រដ្ឋសភាសម្រេចក្នុងរឿងនេះ ដោយវិធីបោះឆ្នោតជាសម្ងាត់តាមមតិភាគច្រើនដាច់ខាតនៃសមាជិករដ្ឋសភាទាំងមូល ។*

**មាត្រា ១២៧.- ថ្មី (មាត្រា ១០៨ ចាស់)**

*ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី នឹងត្រូវកំណត់ក្នុងច្បាប់មួយ ។*

## ព្រះរាជក្រម

នស/រកម/០៧០៤/០០១

## យើង

## ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ
## រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍
## និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ
## ព្រះចៅក្រុងកម្ពុជាធិបតី

-បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់សម័យប្រជុំពេញអង្គលើកទី ១ នីតិកាលទី ៣ នៃរដ្ឋសភា នាថ្ងៃទី ៨ ខែ កក្កដា ឆ្នាំ ២០០៤

-បានទ្រង់យល់សម័យប្រជុំពេញអង្គលើកទី ៩ នីតិកាលទី ១ នៃព្រឹទ្ធសភា នាថ្ងៃទី ១២ ខែ កក្កដា ឆ្នាំ ២០០៤

-យោងតាមសំណើ ចុះថ្ងៃទី ១២ ខែ កក្កដា ឆ្នាំ ២០០៤ របស់ ព្រឹទ្ធសមាជិករដ្ឋសភានីតិកាលទី ៣

## ប្រកាសឱ្យប្រើ

ច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតី នៃស្ថាប័នជាតិ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី០៨ ខែ កក្កដា ឆ្នាំ ២០០៤ នាសម័យប្រជុំពេញអង្គលើកទី ១ នីតិកាលទី ៣ ហើយដែល ព្រឹទ្ធសភាបាន

ឱ្យយោបល់យល់ព្រម កាលពីថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០០៤ នាសម័យប្រជុំពេញអង្គលើកទី ៩ នីតិកាលទី ១ ហើយដែលមានសេចក្តី ទាំងស្រុងដូចតទៅ ៖

## ច្បាប់ធម្មនុញ្ញបន្ថែម
## សំដៅ
## ធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ

**មាត្រា ១.-**

ច្បាប់ធម្មនុញ្ញនេះ មានគោលដៅធានាក្នុងគ្រប់កាលៈទេសៈនូវដំណើរការល្អប្រសើរនៃស្ថាប័នជាតិ ដោយគោរពទៅតាមគោលការណ៍ជាមូលដ្ឋាន នៃលទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស សមស្របតាមតំរូវការនៃភាពចាំបាច់ ។

**មាត្រា ២.-**

នៅដើមនីតិកាលថ្មីនីមួយៗរដ្ឋសភា ក្រោមអធិបតីភាពព្រឹទ្ធសមាជិករដ្ឋសភា មុននឹងផ្តើមការងាររបស់ខ្លួន និងក្រោយពេលសម្រេច អំពីសុពលភាពនៃអាណត្តិរបស់សមាជិកម្នាក់ៗ អាចចាប់ផ្តើមអនុម័តអត្ថបទដែលមានចារិកជារដ្ឋធម្មនុញ្ញ ឬច្បាប់ ដើម្បីអនុវត្តបាននូវគោលដៅដូចមានចែងក្នុងមាត្រា ១ ។

អត្ថបទទាំងនេះ ក្រោយពីបានត្រូវទទួលការបោះឆ្នោតអនុម័តដោយរដ្ឋសភារួចហើយ ត្រូវតែបានទទួលជាបន្ទាន់នូវចំណាត់ការ ដោយរួសរាន់ពីសំណាក់ព្រឹទ្ធសមាជិករដ្ឋសភា តាមនីតិវិធីកំណត់សម្រាប់អត្ថបទទាំងនោះ រហូតដល់ពេលដែលត្រូវបានប្រកាសឱ្យចូលជាធរមាន ។

**មាត្រា ៣.-**

ក្នុងករណីដែលឃើញថា នីតិវិធីនៃមាត្រា៨២ និង១១៩ ថ្មី នៃ រដ្ឋ-ធម្មនុញ្ញមិនអាចសម្រេចបាន រដ្ឋសភា តាមសំណើរបស់គណបក្ស ដែលមានអាសនៈច្រើនជាងគេនៅក្នុងរដ្ឋសភា អាចដំណើរការ ការបោះឆ្នោតជាកញ្ចប់ ដើម្បីជ្រើសតាំងប្រធាន អនុប្រធាន រដ្ឋសភា ក៏ដូចជាប្រធាន និងអនុប្រធានគណៈកម្មការ ក្នុងពេលជាមួយគ្នានឹង ការផ្តល់សេចក្តីទុកចិត្តចំពោះរាជរដ្ឋាភិបាល ។

**មាត្រា ៤.-**

ការរៀបចំបញ្ជីរាយនាមបេក្ខជន ដើម្បីបោះឆ្នោតជ្រើសតាំង និងផ្តល់សេចក្តីទុកចិត្ត ត្រូវអនុវត្តដូចតទៅ ៖

-បញ្ជីរាយនាមបេក្ខជនប្រធាន អនុប្រធាននៃរដ្ឋសភា ក៏ដូចជាប្រធាន និងអនុប្រធានគណៈកម្មការជំនាញទាំងអស់នៃរដ្ឋសភា ត្រូវរៀបចំនិងស្នើដោយគណបក្សនយោបាយ ដែលព្រមព្រៀងគ្នា ដើម្បីបង្កើតរាជ-រដ្ឋាភិបាលចំរុះ ហើយត្រូវផ្ញើជូនព្រឹទ្ធសមាជិករដ្ឋសភា ។

-តាមសេចក្តីស្នើពីគណបក្សនយោបាយដែលមានចំនួន អាសនៈច្រើនជាងគេនៅក្នុងរដ្ឋសភា តាមរយៈព្រឹទ្ធសមាជិករដ្ឋសភា ព្រះមហាក្សត្រទ្រង់ចាត់តាំងវរជនមួយរូបក្នុងចំណោមតំណាងរាស្រ្ត នៃគណបក្សនយោ-បាយ ដែលឈ្នះឆ្នោតឱ្យបង្កើតរាជរដ្ឋាភិបាល ។

វរជនដែលត្រូវបានចាត់តាំងនេះ ត្រូវរៀបចំផ្គូរផ្គងតំណែងផ្សេងៗក្នុងរាជរដ្ឋាភិបាល រួចផ្ញើបញ្ជីរាយនាមសមាជិកទាំងអស់ នៃរាជរដ្ឋាភិបាលជូនព្រឹទ្ធសមាជិករដ្ឋសភា ។

-ព្រឹទ្ធសមាជិករដ្ឋសភាត្រូវរៀបចំបញ្ជីរាយនាមជាកញ្ចប់មួយនូវបេក្ខជន ប្រធាន អនុប្រធាននៃរដ្ឋសភា ក៏ដូចជាប្រធាន និង អនុប្រធាន

គណៈកម្មការជំនាញទាំងអស់នៃរដ្ឋសភា ព្រមទាំងបេក្ខជននាយករដ្ឋមន្ត្រី និងសមាជិកទាំងអស់នៃរាជរដ្ឋាភិបាល ដើម្បីដាក់ជូនរដ្ឋសភាបោះឆ្នោត ។

**មាត្រា ៥.-**

នៅក្នុងដំណើរការនៃការបោះឆ្នោតជាកញ្ចប់ មិនអាចជជែកពិភាក្សាអ្វីបានឡើយ ហើយក៏មិនអាចមានការពន្យល់ អំពីការបោះឆ្នោតនេះ ក្រោយការប្រកាសលទ្ធផលនៃការបោះឆ្នោតជាកញ្ចប់នេះដែរ ។

សមាជិករដ្ឋសភា ត្រូវធ្វើការបោះឆ្នោតដោយបញ្ជាក់ថាព្រម ឬមិនព្រម ចំពោះបញ្ជីរាយនាមជាកញ្ចប់មួយ ដែលព្រឹទ្ធសមាជិក រដ្ឋសភាបានដាក់ជូន ។ ការបោះឆ្នោតនេះ ត្រូវធ្វើឡើងដោយវិធីលើកដៃ ។

**មាត្រា ៦.- ថ្មី នៃច្បាប់ធម្មនុញ្ញបន្ថែម**

ការបោះឆ្នោតជាកញ្ចប់ខាងលើនេះ ត្រូវយកតាមមតិភាគច្រើនដាច់ខាតនៃចំនួនសមាជិករដ្ឋសភាទាំងមូល ។

ក្នុងករណីការបោះឆ្នោតជុំទីមួយមិនបានសម្រេច នីតិវិធីដដែលនេះនឹងត្រូវអនុវត្តចំពោះការបោះឆ្នោតជុំក្រោយៗ ទៀត ។

**មាត្រា ៧.-**

ច្បាប់ធម្មនុញ្ញបន្ថែមនេះ ត្រូវបានប្រកាសជាការប្រញាប់ និងយកមកអនុវត្ត ចាប់តាំងពីដើមនីតិកាលបច្ចុប្បន្ននេះទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤

ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់

នរល.០៤.០៧.១១៧

**ប្រមុខរដ្ឋស្តីទី**

**ហត្ថលេខា និងព្រះរាជលញ្ឆករ**

**ញឹក ប៊ុនឆៃ**

## ច្បាប់ធម្មនុញ្ញ
## ស្តីពី
## វិសោធនកម្ម
## មាត្រា ៨២ មាត្រា ៨៨ថ្មី មាត្រា ៩០ថ្មី មាត្រា ៩៨ មាត្រា ១០៦ថ្មី មាត្រា ១១១ថ្មី(មួយ) មាត្រា ១១៨ថ្មី នៃរដ្ឋធម្មនុញ្ញ និងមាត្រា ៦ នៃច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ

**មាត្រាតែមួយ.-**

*មាត្រា ៨២ មាត្រា ៨៨ថ្មី មាត្រា ៩០ថ្មី មាត្រា ៩៨ មាត្រា ១០៦ថ្មី មាត្រា ១១១ ថ្មី(មួយ) មាត្រា ១១៨ថ្មី នៃរដ្ឋធម្មនុញ្ញ និង មាត្រា៦ នៃច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ ត្រូវបានកែប្រែដូចតទៅ :*

**មាត្រា ៨២.- ថ្មី**

*រដ្ឋសភាបើកសម័យប្រជុំដំបូង ហុកសិបថ្ងៃយ៉ាងយូរក្រោយពេលបោះឆ្នោតតាមការកោះប្រជុំរបស់ព្រះមហាក្សត្រ។*

*មុននឹងចាប់ផ្តើមការងាររបស់ខ្លួន រដ្ឋសភាត្រូវប្រកាស សុពលភាព នៃអាណត្តិរបស់សមាជិកនីមួយៗ ត្រូវបោះឆ្នោតជ្រើសរើស ដាច់ដោយឡែកពីគ្នា នូវប្រធាន អនុប្រធានរដ្ឋសភា និង សមាជិក ទាំងអស់នៃគណៈកម្មការនានារបស់រដ្ឋសភា ដោយមតិភាគច្រើនដាច់ខាត នៃចំនួនសមាជិករដ្ឋសភាទាំងមូល ។*

*រដ្ឋសភាត្រូវអនុម័តបទបញ្ជាផ្ទៃក្នុង ដោយមតិភាគច្រើនដាច់ខាត នៃចំនួនសមាជិករដ្ឋសភាទាំងមូល ។*

*តំណាងរាស្ត្រទាំងអស់ ត្រូវធ្វើសច្ចាប្រណិធានមុនចូលកាន់តំណែង ដូចមានខ្លឹមសារចែងក្នុងឧបសម្ព័ន្ធទី៥ នៃរដ្ឋធម្មនុញ្ញ ។*

**មាត្រា ៨៨.- ថ្មី(ពីរ)**

*កាប្រជុំរដ្ឋសភាត្រូវធ្វើជាសាធារណៈ ។*

*រដ្ឋសភាអាចប្រជុំជាសម្ងាត់បានតាមការស្នើសុំពីប្រធាន ឬពីសមាជិក ចំនួនមួយភាគដប់យ៉ាងតិច ពីព្រះមហាក្សត្រ ឬពីនាយករដ្ឋមន្ត្រី ។*

*ការប្រជុំរដ្ឋសភា នឹងយកជាការបានលុះត្រាតែមាន :*

*ក-កូរ៉ុមលើសពី ពីរភាគបី នៃចំនួនសមាជិករដ្ឋសភាទាំងមូល សម្រាប់ការអនុម័តទាំងឡាយណាដែលតម្រូវឱ្យយកមតិភាគច្រើន ពីរភាគបី នៃចំនួនសមាជិករដ្ឋសភាទាំងមូល ។*

*ខ-កូរ៉ុមលើសពីពាក់កណ្ដាល នៃចំនួនសមាជិករដ្ឋសភាទាំងមូល សម្រាប់ការអនុម័តទាំងឡាយណាដែលតម្រូវឱ្យយកមតិភាគច្រើនដាច់ខាត នៃចំនួនសមាជិករដ្ឋសភាទាំងមូល ។*

**មាត្រា ៩០.- ថ្មី(ពីរ)**

*រដ្ឋសភាជាអង្គការ ដែលមានអំណាចនីតិប្បញ្ញត្តិ ហើយបំពេញការកិច្ចរបស់ខ្លួនដូចបានកំណត់ក្នុងរដ្ឋធម្មនុញ្ញ និងច្បាប់ជាធរមាន ។*

*រដ្ឋសភាអនុម័តថវិកាជាតិ ផែនការរដ្ឋ ការឱ្យរដ្ឋខ្ចីប្រាក់ពីគេ ការឱ្យរដ្ឋឱ្យប្រាក់គេខ្ចី ការសន្យានានាផ្នែកហិរញ្ញវត្ថុ និងការបង្កើត កែប្រែ*

ឬ លុបចោលពន្ធដារ ។

រដ្ឋសភាឱ្យសេចក្ដីយល់ព្រមចំពោះគណនីរដ្ឋបាល ។

រដ្ឋសភាអនុម័តច្បាប់ស្ដីពីការលើកលែងទោសជាទូទៅ ។

រដ្ឋសភាអនុម័តយល់ព្រម ឬលុបចោលសន្ធិសញ្ញា ឬអនុសញ្ញាអន្តរជាតិ។

រដ្ឋសភាអនុម័តច្បាប់ស្ដីពីការប្រកាសសង្គ្រាម ។

ការអនុម័តខាងលើនេះប្រព្រឹត្តទៅដោយមតិភាគច្រើនដាច់ខាតនៃចំនួនសមាជិករដ្ឋសភាទាំងមូល ។

រដ្ឋសភាបោះឆ្នោតទុកចិត្តដល់រាជរដ្ឋាភិបាល តាមមតិភាគច្រើនដាច់ខាត នៃចំនួនសមាជិករដ្ឋសភាទាំងមូល ។

## មាត្រា ៩៨._ ថ្មី

រដ្ឋសភាអាចទម្លាក់សមាជិកគណៈរដ្ឋមន្ត្រី ឬទម្លាក់រាជរដ្ឋាភិបាលពីតំណែងដោយអនុម័តញត្តិបន្ទោស តាមសំឡេងឆ្នោតភាគច្រើនដាច់ខាត នៃចំនួនសមាជិករដ្ឋសភាទាំងមូល ។

ញត្តិបន្ទោសរាជរដ្ឋាភិបាល ត្រូវបានលើកឡើងជូនរដ្ឋសភាដោយតំណាងរាស្ត្រចំនួនសាមសិបនាក់ ទើបរដ្ឋសភាអាចលើក មកពិភាក្សាបាន ។

## មាត្រា ១០៦._ ថ្មី( មួយ )

ព្រឹទ្ធសភាបើកសម័យប្រជុំដំបូង ហុកសិបថ្ងៃយ៉ាងយូរ ក្រោយពេលបោះឆ្នោតតាមការកោះប្រជុំរបស់ព្រះមហាក្សត្រ ។

មុនចាប់ផ្ដើមការងាររបស់ខ្លួន ព្រឹទ្ធសភាត្រូវប្រកាស សុពលភាពនៃអាណត្តិរបស់សមាជិកនីមួយៗ និងត្រូវបោះឆ្នោតជ្រើសរើសដាច់ដោយឡែកពីគ្នា នូវប្រធាន អនុប្រធានព្រឹទ្ធសភា និងសមាជិកទាំងអស់នៃគណៈ-កម្មការនានារបស់ព្រឹទ្ធសភា ដោយមតិភាគច្រើនដាច់ខាតនៃចំនួនសមាជិកព្រឹទ្ធសភាទាំងមូល ។

សមាជិកព្រឹទ្ធសភាទាំងអស់ ត្រូវធ្វើសច្ចាប្រណិធានមុនចូលកាន់តំណែង ដូចមានខ្លឹមសារចែងក្នុងឧបសម្ព័ន្ធទី ៧ នៃរដ្ឋធម្មនុញ្ញ ។

**មាត្រា ១១១.- ថ្មី(ពីរ)**

ការប្រជុំព្រឹទ្ធសភាត្រូវធ្វើជាសាធារណៈ ។

ព្រឹទ្ធសភាអាចប្រជុំជាសម្ងាត់បានតាមការស្នើសុំពីប្រធាន ឬពីសមាជិកចំនួនមួយភាគដប់យ៉ាងតិច ពីព្រះមហាក្សត្រ ពីនាយករដ្ឋមន្ត្រី ឬពីប្រធានរដ្ឋសភា ។

ការប្រជុំព្រឹទ្ធសភានឹងយកជាការបាន លុះត្រាតែមាន :

ក-កូរ៉ុមលើសពី ពីរភាគបី នៃចំនួនសមាជិកព្រឹទ្ធសភាទាំងមូល សម្រាប់ការអនុម័តទាំងឡាយណា ដែលតម្រូវឱ្យយកមតិភាគច្រើនពីរភាគបី នៃចំនួនសមាជិកព្រឹទ្ធសភាទាំងមូល ។

ខ-កូរ៉ុមលើសពីពាក់កណ្ដាលនៃចំនួនសមាជិកព្រឹទ្ធ-សភាទាំងមូល សម្រាប់ការអនុម័តទាំងឡាយណា ដែលតម្រូវឱ្យយកមតិភាគច្រើនដោយប្រៀប ឬយកមតិភាគច្រើនដាច់ខាតនៃចំនួនសមាជិកព្រឹទ្ធសភាទាំងមូល ។

ចំនួនសំឡេងដែលតម្រូវសម្រាប់រដ្ឋសភាអនុម័តយល់ព្រម

*ហើយដែលមានកំណត់ក្នុងរដ្ឋធម្មនុញ្ញ ត្រូវយកមកប្រើសម្រាប់ព្រឹទ្ធសភាផងដែរ ។*

**មាត្រា ១១៤.- ថ្មី(មួយ)**

*ព្រឹទ្ធសភាបង្កើតគណៈកម្មការផ្សេងៗ ដែលចាំបាច់ ។ ការរៀបចំ និងការប្រព្រឹត្តទៅនៃព្រឹទ្ធសភានឹងកំណត់ក្នុងបទបញ្ជាផ្ទៃក្នុង របស់ព្រឹទ្ធសភា ។ បទបញ្ជាផ្ទៃក្នុងនេះត្រូវអនុម័តយល់ព្រម ដោយសំឡេងភាគច្រើនដាច់ខាត នៃចំនួនសមាជិកព្រឹទ្ធសភាទាំងមូល ។*

**មាត្រា ៦.- ថ្មី នៃច្បាប់ធម្មនុញ្ញបន្ថែម**

*ការបោះឆ្នោតជាកញ្ចប់ខាងលើនេះ ត្រូវយកតាមមតិភាគច្រើនដាច់ខាតនៃចំនួនសមាជិករដ្ឋសភាទាំងមូល ។*

*ក្នុងករណីការបោះឆ្នោតជុំទីមួយមិនបានសម្រេចនីតិវិធីដដែលនេះ នឹងត្រូវអនុវត្តចំពោះការបោះឆ្នោតជុំក្រោយៗទៀត ។*

*ធ្វើនៅព្រះបរមរាជវាំងរាជធានីភ្នំពេញថ្ងៃទី ៩ ខែមីនា ឆ្នាំ២០០៦*

*ពរល.០៦០៣.១២៤* **ព្រះហស្ថលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

*បានយកសេចក្តីក្រាបបង្គំទូលថ្វាយ*

*សូមឡាយព្រហស្តលេខាព្រះមហាក្សត្រ*

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា**

**ហ៊ុន សែន**